

# ការបណ្តេញចេញ និងការតស៊ូក្នុងប្រទេសកម្ពុជា

## ស្ត្រីប្រាំនាក់ប្រាប់រឿងរបស់ខ្លួន

AMNESTY INTERNATIONAL



# ការបណ្តេញចេញ និងការតស៊ូក្នុងប្រទេសកម្ពុជា

## ស្ត្រីប្រាំនាក់ប្រាប់រឿងរបស់ខ្លួន

AMNESTY INTERNATIONAL

**amnesty.org/demand-dignity**

បទសម្ភាសន៍ សម្រាប់របាយការណ៍ផ្សព្វផ្សាយនេះ ត្រូវបានធ្វើនៅចន្លោះខែ កុម្ភៈ និងខែកញ្ញា ២០១១។ ប្រភពឯកសារទាំងអស់មាន នៅអង្គការលើកលែងទោសអន្តរជាតិ (Amnesty International)

ឯកសារនេះ គឺជាយុទ្ធនាការទាមទារភាពថ្លៃថ្នូររបស់អង្គការលើកលែងទោសអន្តរជាតិ ដែលបាន ផ្តោតការយកចិត្តទុកដាក់ លើការរំលោភសិទ្ធិមនុស្ស មកលើប្រជាពលរដ្ឋដែលកំពុងរស់ នៅក្នុងទីតាំងលំនៅឋានថ្មី ក្រៅផ្លូវការ ឬតំបន់ ជនក្រីក្រ។

យើងខ្ញុំ អំពាវនាវដល់ រដ្ឋាភិបាលទាំងឡាយ សូមអោយ បញ្ឈប់ការបណ្តេញចេញដោយបង្ខំ អោយធានាដល់ការទទួល បានសេវាសាធារណៈ ដោយស្មើភាពគ្នា និងជំរុញការចូលរួមសកម្ម របស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងទីតាំង លំនៅឋានថ្មីក្រៅផ្លូវការ នៅក្នុងសេចក្តីសម្រេចចិត្ត និងដំណើរការ ដែលប៉ះពាល់ជីវភាពរស់នៅ របស់ពួកគាត់។

ចំពោះអនុសាសន៍ ដែលទាក់ទងទៅនឹងឯកសារនេះ សូមអានរបាយការណ៍*ការបណ្តេញចេញ និងការតស៊ូក្នុងប្រទេសកម្ពុជា ៖ ស្ត្រីប្រាំនាក់ប្រាប់រឿងរបស់ខ្លួន — អនុសាសន៍លេខ* (Index: ASA 23/007/2011)។ សម្រាប់កិច្ចការរបស់អង្គការលើកលែងទោសអន្តរជាតិ នៅក្នុងប្រទេសកម្ពុជា សូមមើលរបាយការណ៍ សិទ្ធិមនុស្សត្រូវគេរំលោភ ៖ ការបណ្តេញចេញដោយបង្ខំនៅព្រះរាជាណាចក្រកម្ពុជា (Index: ASA 23/002/2008).

អង្គការលើកលែងទោសអន្តរជាតិ ក៏បានផលិតភាពយន្តឯកសារជាបន្តបន្ទាប់ ដែលពិពណ៌នាស្តីពីស្ត្រីក្នុងរបាយការណ៍នេះ។ សូមចូលគេហទំព័រ www.amnesty.org ដើម្បីមើលភាពយន្តឯកសារ ទាំងស្រុង អំពីរឿងរ៉ាវនៃការបណ្តេញចេញ និងការតស៊ូក្នុងប្រទេសកម្ពុជា និងឯកសារដាច់ដោយ ឡែកពីគ្នាចំនួនប្រាំ ដោយផ្តោតលើស្ត្រីនីមួយៗ

រូបថតក្រប៖ ទិន ហៀប ពកូន រឿន សាវង្ស
រូបថតទាំងអស់©រក្សាសិទ្ធិដោយអង្គការលើកលែងទោសអន្តរជាតិ លើកលែងមានការបញ្ជាក់

# មាតិកា

ផែនទី 4
បុព្វកថា 6
សម្ដីផ្ទាល់របស់ពួកគេ 8



ម៉ៃ 10



សុផល 20



ហុង 30



ហៀប 40



វ៉ាន់នី 50

កំណត់សំគាល់ចុងក្រោយ 60
សម្ដីចុងក្រោយ 62

# ផែនទី




យកលំនាំតាមផែនទីអ.ស.ប លេខ 3860 rev. ចុះថ្ងៃទី៤ មករា ២០០៤




យកលំនាំតាមផែនទីអង្គការសមាគមធាងត្នោត

# បុព្វកថា

ជាងពីរទសវត្សរ៍កន្លងទៅនេះ ប្រទេសកម្ពុជាបានងើបចេញពីជម្លោះប្រដាប់អាវុធ វិបត្តិសេដ្ឋកិច្ចនិងភាពនៅឯកោ។ ការផ្លាស់ប្តូរទាំងនេះ បាននាំមកនូវឱកាសផង និងការប្រឈមផងដែរសម្រាប់ស្ត្រីកម្ពុជា។ ខណៈពេលដែលស្ត្រីនៅតែជាសសរទ្រូងក្នុងគ្រួសារនិងជាមេផ្ទះ ស្ត្រីមួយចំនួនបានទទួលដំណែងជាសហគ្រិន ជាអ្នកជំនាញការ អ្នកនយោបាយ សកម្មជន វិចិត្រករ និងជាអ្នកដឹកនាំសហគមន៍គួរជាទីមោទនាបំផុតរបស់ប្រទេសជាតិ។

ក៏ប៉ុន្តែ ស្ត្រីជាច្រើនដែលចង់ចាប់យកឱកាសថ្មីទាំងនេះ និងចង់គេចឲ្យផុតពីហានិភ័យនៃភាពក្រីក្រ ការរំលោភបំពាន និងការកេងប្រវ័ញ្ច ត្រូវបានគេរារាំងដោយការគំរាមកំហែងបណ្តេញចេញដោយបង្ខំពីលំនៅឋាន និងដីធ្លីរបស់ខ្លួន។ ការបណ្តេញចេញដោយបង្ខំគឺជាការជម្លៀសប្រជាពលរដ្ឋ ផ្ទុយនឹងឆន្ទៈរបស់ពួកគាត់ ឲ្យចាកចេញពីលំនៅឋានឬដីធ្លី ដែលពួកគាត់កាន់កាប់ ដោយគ្មានការការពារផ្លូវច្បាប់និងការការពារផ្សេងៗ ដែលតម្រូវក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ការបណ្តេញចេញដោយបង្ខំ រំលោភសិទ្ធិមានលំនៅឋានសមរម្យរបស់បុគ្គល និងត្រូវបានហាមឃាត់ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលកម្ពុជាជារដ្ឋភាគី។

ស្ថាប័នឃ្លាំមើលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិមួយចំនួន និងអង្គការ ក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ រួមទាំងអង្គការលើកលែងទោសអន្តរជាតិ បានបង្ហាញពីការបរាជ័យជាប្រព័ន្ធរបស់អាជ្ញាធរកម្ពុជា ដែលខកខានមិនបានការពារប្រជាពលរដ្ឋពីការបណ្តេញចេញដោយបង្ខំទេ។ ការបណ្តេញចេញដោយបង្ខំ ដែលជ្រកក្រោមផ្លាកអភិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលនេះ កំពុងកើតឡើងជាទម្លាប់ទៅហើយ នៅពាសពេញផ្ទៃប្រទេសកម្ពុជា ដោយពួកមេដឹកនាំថ្នាក់មូលដ្ឋាន និងវិនិយោគិនបរទេស ស្វែងបណ្តាក់ទុនរកស៊ីនៅលើទីផ្សារដីធ្លីជាឯកជនភាវូនីយកម្ម និងចាប់ត្រួតត្រាធនធានធម្មជាតិរបស់ប្រទេសនេះ។ អាជ្ញាធររាជរដ្ឋាភិបាល បានចូលរួមជួយយ៉ាងសកម្មក្នុងការបណ្តេញចេញដោយបង្ខំ ឬខកខានធ្វើសកម្មភាពខណៈពេលដែលមានច្បាប់សម្រាប់អនុវត្តហើយក្តី ឬក៏មិនអើពើធ្វើដឹងធ្វើឮតែម្តង។

ការបោះពុម្ពផ្សាយរបាយការណ៍នេះ ប្រាប់រឿងរ៉ាវរបស់ស្ត្រីខ្មែរបួនរូប ឈ្មោះម៉ៃ សុផល ហៀប និងវ៉ាន់នី ដោយស្ត្រីទាំងនោះបានប្រឈមមុខ ឬតស៊ូនឹងការបណ្តេញចេញដោយបង្ខំពីលំនៅឋាននិងដីធ្លីរបស់ខ្លួន។ របាយការណ៍ក៏ប្រាប់រឿងរបស់នាងហុង ជាស្ត្រីជនជាតិដើមភាគតិច ដែលបានបាត់បង់ព្រៃឈើ ដែលអ្នកស្រុករបស់គាត់ បានអាស្រ័យផលតាមប្រពៃណីដើម្បីចិញ្ចឹមជីវិតផងដែរ។ ម៉ៃមានផ្ទៃពោះប្រាំខែ នៅពេលគាត់ឈរមើលផ្ទះ និងទ្រព្យសម្បត្តិរបស់គាត់ ត្រូវលេបត្របាក់ដោយអណ្តាតភ្លើង។ ពីរបីថ្ងៃក្រោយមក គេបានចាប់គាត់ដាក់គុកអស់ ៨ ខែ ដោយសារតែគាត់ព្យាយាមការពារសិទ្ធិលំនៅឋានរបស់ខ្លួន។

សហគមន៍ក្នុងទីក្រុងគួរជាទីមោទនារបស់សុផល បានតស៊ូនឹងការបណ្តេញចេញ អស់រយៈបីឆ្នាំ។ នៅរាត្រីមួយ សហគមន៍នោះត្រូវបានឡោមព័ទ្ធ និងរងការវាយលុកហែកហួរដោយកងនគរបាលនិងកម្មករក្រុមហ៊ុនជាច្រើនរាប់រយនាក់ ដែលចូលបំផ្លាញភូមិឋានមួយ ត្រឹមតែរយៈពេលពីរបីម៉ោងប៉ុណ្ណោះ។

ហុងគឺជាជនជាតិគួយ ដែលជាជនជាតិដើមភាគតិចមួយក្នុងចំណោមជនជាតិដើមទាំងអស់ក្នុងប្រទេសកម្ពុជា រស់នៅក្នុងព្រៃឡង់អស់ជាច្រើនជំនាន់។ ចំពោះហុងនិងសហគមន៍របស់គាត់ ព្រៃឈើផ្តល់ជាលំនៅឋាន និងមុខរបរចិញ្ចឹមជីវិតរបស់ពួកគេ។ ពេលនេះ ដោយសារតែការបំផ្លិចបំផ្លាញព្រៃឈើ ហុងបានដឹកនាំសហគមន៍របស់គាត់ ធ្វើការតស៊ូការពារដីធ្លី និងធនធានធម្មជាតិរបស់ពួកគេ។

ប្ដីរបស់ហៀបត្រូវបានគេចាប់ខ្លួន ហើយដាក់ពន្ធនាគារពីបទចោទប្រកាន់ដោយគ្មានហេតុផលនៅថ្ងៃតែមួយ នៅពេលដែលអាជ្ញាធរនិងពាណិជ្ជករម្នាក់ បានរឹបអូសយកដីកសិកម្មទាំងអស់នៅក្នុងភូមិរបស់គាត់។ ដោយគ្មានដីធ្លីនិងអវត្តមានប្ដីផងនោះ គាត់ក៏ធ្លាក់ខ្លួនរស់នៅតែម្នាក់ឯង ដោយខិតខំរកស៊ីចិញ្ចឹមខ្លួនផងនិងកូនតូចៗបួននាក់ផង។

វ៉ាន់នី គឺជាតួអង្គម្នាក់ដែលចេញមុខដឹកនាំការតស៊ូប្រឆាំងនឹងការបណ្ដេញចេញដ៏ធំបំផុត ចាប់តាំងពីយុគសម័យខ្មែរក្រហមមកម្លេះ។ ផ្ទះរបស់គាត់ដែលស្ថិតនៅមាត់ច្រាំងបឹងកក់ ដែលស្ថិតនៅចំកណ្ដាលរាជធានីភ្នំពេញ កំពុងតែរងការគំរាមកំហែង។ វ៉ាន់នីកំពុងធ្វើកិច្ចការគ្រប់យ៉ាង ទៅតាមដែលគាត់អាចធ្វើបាន ដើម្បីការពារជម្រករបស់គាត់ និងការតស៊ូរបស់គាត់ទទួលបានសំណង។ នៅក្នុងខែសីហា នាយករដ្ឋមន្ត្រីបានចុះហត្ថលេខាលើបទបញ្ជាផ្ដល់តំបន់មួយកន្លែង ក្នុងតំបន់អភិវឌ្ឍន៍បឹងកក់ ដើម្បីប្រគល់ឲ្យអ្នករស់នៅបឹងកក់ដែលនៅសេសសល់ សម្រាប់សង់លំនៅឋាននៅនឹងកន្លែង។ នៅពេលជាមួយគ្នានេះដែរ គេមិនទាន់ដឹងច្បាស់ថានឹងមានដំណើរការពិតប្រាកដដូចម្ដេចនៅឡើយទេ មានអ្នកភូមិខ្លះត្រូវបានគេកាត់ចេញ យ៉ាងណាក៏នេះជាជោគជ័យធំមួយសម្រាប់សហគមន៍ផងដែរ។

មិនមែនមានស្ត្រីតែប្រាំនាក់នេះទេ ដែលស្ថិតក្នុងរឿងរ៉ាវនៃការតស៊ូដ៏ក្លាហាន ការលំបាក និងទុក្ខវេទនា។ ការបណ្ដេញចេញដោយបង្ខំ ឬការជម្លៀសចេញពីផ្ទះ និងសហគមន៍មួយ គឺជាបទពិសោធន៍មួយដ៏មហាសែនឈឺចាប់។ ការបំផ្លិចបំផ្លាញលំនៅឋានរបស់អ្នកណាម្នាក់ ឬដីធ្លីសម្រាប់ដាំដំណាំកសិកម្ម ឬសម្រាប់ប្រភពបង្កើតការចញ្ចឹមជីវិតដទៃទៀត មានផលពិបាកដ៏មហន្តរាយសម្រាប់បុរសនិងស្ត្រី ប៉ុន្តែជាញឹកញាយ វាមានផលប៉ះពាល់ជាពិសេសមកលើស្ត្រីភេទ។

ជាញឹកញាប់ការបណ្ដេញចេញ នាំអោយមានការបែកបាក់បណ្ដាញនៅ ក្នុងសហគមន៍ និងប្រព័ន្ធគាំទ្រក្រៅផ្លូវការ ដែលស្ត្រីទាំងនោះពឹងពាក់សម្រាប់ជីវិតប្រចាំថ្ងៃការ បណ្ដេញចេញជារឿយៗទប់បង្អាក់ការអប់រំរបស់កុមារ និងកាត់បន្ថយការទទួលបានសេវាសុខភាព និងធ្វើឲ្យទ្រុឌទ្រោមសុខភាពផ្លូវកាយនិងចិត្តរបស់គ្រួសារ។ ដោយសារជនរងគ្រោះពីការបណ្ដេញចេញដោយបង្ខំជាច្រើនត្រូវបានគេឲ្យទៅតាំងទីលំនៅក្នុងតំបន់ឆ្ងាយពីទីប្រជុំជនទីក្រុងនិងឱកាសការងារ បុរសជាប្ដីបានចាកចេញពីក្រុមគ្រួសារអស់រយៈពេលយ៉ាងយូរ ដោយទុកឲ្យប្រពន្ធរបស់ពួកគេនៅដោះស្រាយទទួលខុសត្រូវជីវភាពប្រចាំថ្ងៃនិងសេចក្ដីត្រូវការរបស់គ្រួសារ។

ក៏ប៉ុន្តែ ស្ត្រីទាំងនេះបានបង្កើតយុទ្ធសាស្ត្រក្នុងការដោះស្រាយសម្រាប់ខ្លួនឯង និងដើរតួនាទីជាអ្នកថែរទាំបឋមសម្រាប់គ្រួសាររបស់ខ្លួន។ ស្ត្រីដែលរឿងរបស់ពួកគាត់ត្រូវបានគេនិយាយប្រាប់នៅទីនេះ បានប្រឈមមុខនឹងការបណ្ដេញចេញដោយបង្ខំ ឬកំពុងបន្តការតស៊ូប្រយុទ្ធនឹងការបណ្ដេញចេញ និងឲ្យភៀសចេញពីដីរបស់ខ្លួន ដោយលាយលំនឹងការភ័យខ្លាច និងសេចក្ដីក្លាហាន កំហឹង និងការប្ដេជ្ញាដ៏ស្ងប់ស្ងាត់។








# សម្ដីផ្ទាល់របស់ពួកគេ

# ម៉ៃ

"ផ្ទះសម្បែង ទ្រព្យសម្បត្តិ អត្តសញ្ញាណប័ណ្ណ
ខោអាវ រូបថតរបស់ខ្ញុំទាំងអស់
បានឆេះក្លាយជាផ្សែងអស់រលីង។
ខ្ញុំគ្មានសល់អីទៀតទេ។"



ហុងម៉ៃ និងកូនប្រុស ពីរនាក់ គឺ អាន ហ៊ើយនៅខាងឆ្វេងដៃ
និងអាន សំណាង ក្នុងភូមិតាមាន់ ខេត្តឧត្តរមានជ័យ



ក្នុងឆ្នាំ២០០៨ រដ្ឋាភិបាលកម្ពុជា បានផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុនបី សម្រាប់ធ្វើចំការកសិឧស្សាហកម្មដាំអំពៅក្នុងខេត្តឧត្តរមានជ័យ។ អាជ្ញាធរ មិនបានពិគ្រោះយោបល់ជាមួយក្រុមគ្រួសារក្នុងតំបន់នោះទេ ហើយចាប់ផ្តើមគំរាមកំហែង និងបំភិតបំភ័យពួកគេឲ្យចាកចេញពីលំនៅឋាននិងដីកសិកម្ម។ ក្នុងខែមេសា ឆ្នាំ២០០៨ កម្មករដែលគេថាជាបុគ្គលិកក្រុមហ៊ុន បានបំផ្លាញផ្ទះអស់ចំនួនប្រហែល ១៥០ ខ្នង។ ការដាក់សម្ពាធមកលើគ្រួសារបានបន្ត។ ក្នុងខែតុលា ២០០៩ ផ្ទះជាង ១០០ ខ្នង ត្រូវបានចូកឈូសឆាយរាបដល់ដី។ គ្រួសារជាច្រើនបានចាកចេញ ដោយសារស្ថានភាពដ៏មហាភ័យខ្លាច គ្រួសារខ្លះក្លាយជាជនឥតទីជម្រក ដោយសារការបណ្តេញចេញដោយបង្ខំ។ សមាជិកសហគមន៍មួយចំនួន ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារ។



មែមានផ្ទៃពោះប្រាំខែ ក្នុងខែតុលា ឆ្នាំ២០០៩ ជាពេលដែលគាត់ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារ។ គាត់បានធ្វើដំណើរចម្ងាយជាង ២៥០ គីឡូម៉ែត្រពីស្រុកកំណើតនៅតំបន់ដាច់ស្រយាលមួយក្នុងខេត្តឧត្តរមានជ័យ ឆ្ពោះមកកាន់ភ្នំពេញជារាជធានីប្រទេសកម្ពុជា ដើម្បីអង្វរសុំលោកនាយករដ្ឋមន្ត្រីហ៊ុន សែន ឲ្យជួយសហគមន៍របស់គាត់យកដីមកវិញ។ ដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់គាត់ គាត់ត្រូវបាន ចោទប្រកាន់ថាបានរំលោភលើច្បាប់ព្រៃឈើ និងដាក់គុកគាត់។

ពីរបីថ្ងៃមុនចាប់ខ្លួន មែបានឈរមើលដោយឥតសង្ឃឹមថានឹងមានគេជួយ នៅពេលដែលលំនៅឋានរបស់គាត់ និងផ្ទះ ១១៨ ខ្នងផ្សេងទៀត នៅក្នុងភូមិបុស ត្រូវបានឈូសឆាយ និងដុតក្លាយជាផេះលើដី ដោយមនុស្សប្រហែល ១៥០ នាក់ ដែលក្នុងនោះមានកងកម្លាំងប៉ូលិស អាវុធហត្ថ មន្ត្រីរដ្ឋបាលព្រៃឈើ និងអ្នកភូមិឯទៀតដែលគេជឿថាជាកម្មកររបស់ក្រុមហ៊ុន។

ក្នុងឆ្នាំ២០០៨ ក្រុមហ៊ុនស្ករអង្គរ បានទទួលសម្បទានដីសេដ្ឋកិច្ច ជាង ៦,៥០០ ហិកតា ដែលកាត់ចូលដីភូមិរបស់មែ។ ទាំងក្រុមហ៊ុននិងអាជ្ញាធរ ខកខានមិនបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ដល់គ្រួសារដែលកំពុងរស់ក្នុងតំបន់នោះ អំពីសម្បទានដី ឬអំពីសិទ្ធិលំនៅឋាន និងដីធ្លីរបស់ពួកគេទេ។ គេមិនបានពិគ្រោះយោបល់ជាមួយគ្រួសារស្តីពីផែនការរបស់ក្រុម ហ៊ុន ឬអំពីផលប៉ះពាល់មកលើប្រជាពលរដ្ឋទាំងនោះយ៉ាងណានោះទេ។ ដោយមិនខ្វល់នឹងការតវ៉ាទាមទាររបស់អ្នកស្រុក ពួកកម្មករក្រុមហ៊ុន ដែលតាមរាយការណ៍ថា បានចាប់ផ្តើមឈូសឆាយវាលស្រែរបស់អ្នកភូមិ រួមទាំងដីរបស់មែផងដើម្បីដាំអំពៅ ក្រោយពេលទទួលបានសម្បទានដីភ្លាមៗ។ មែ បានពន្យល់រៀបរាប់ថា កម្មករទាំងនោះបានច្រូតកាត់ស្រូវយកទុកខ្លួនឯង ជាហេតុធ្វើឲ្យមែនិងសហគមន៍របស់គាត់ខ្វះស្បៀងអាហារ ទ្រទ្រង់ពួកគេពេញមួយឆ្នាំខាងមុខ។

សកម្មភាពបំផ្លិច បំផ្លាញភូមិបុសនៅក្នុង ខែតុលា ២០០៩ ដែល មែបានរស់នៅ។ ខ្សែវីដេអូនេះ បានពិព័ណនាអំពី នៃការបណ្តេញចេញ និងការតស៊ូក្នុងប្រទេស កម្ពុជា។ ខ្សែវីដេអូ ត្រូវបានថត ។មទូរស័ព្ទដៃដោយអង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ កម្មវិធីកសាងសន្តិភាពសហគមន៍


© កម្មវិធីកសាងសន្តិភាពសហគមន៍ (CPN)


© កម្មវិធីកសាងសន្តិភាពសហគមន៍ (CPN)


© កម្មវិធីកសាងសន្តិភាពសហគមន៍ (CPN)

ការរុះរើបំផ្លាញលំនៅឋានក្នុងភូមិ បានកើតជាលើកដំបូងក្នុងខែមេសា ឆ្នាំ២០០៨ ហើយវាចាប់ផ្តើមជាមួយនិងចលនាគំរាមកំហែង និងបំភិតបំភ័យដើម្បីបង្ខំក្រុម គ្រួសារដែលនៅសល់ឲ្យចាកចេញ។ អ្នកស្រុកបាននិយាយថា គេបានកៀប សង្កត់ពួកគាត់ឲ្យទទួលយកដីមួយកន្លែង លែចាត់ចែងដោយអាជ្ញាធរ។ ប្រសិនបើពួកគាត់មិនព្រមយកទេ គេប្រាប់ពួកគាត់ថាពួកគាត់នឹងមិនទទួលបានអ្វីទាំងអស់ និងត្រូវជាប់ពីបទព្រហ្មទណ្ឌទៀត។ អ្នកភូមិបានប្រកាសថា ទំហំដីដែលផ្តល់នោះតូចជាងដីដែល ក្រុមហ៊ុនយកពីពួកគាត់ ហើយដីខ្លះ ជាដីរបស់ភាគីទីបីថែមទៀតផង។ ទោះបីជាមានការកៀបសង្កត់ក៏ដោយ អ្នកភូមិស្ទើរទាំងអស់គ្នា បានច្រានចោលការផ្តល់ឲ្យនេះ។

## “ពួកខ្ញុំ រត់កាត់ព្រៃ ហែលឆ្លងកាត់ទឹក ដើម្បីមកប្តឹងសម្តេច ហ៊ុន សែន នៅភ្នំពេញ”

នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ កងអាវុធហត្ថ ប៉ូលិស មន្ត្រីរដ្ឋបាលព្រៃឈើ និងបុគ្គលផ្សេងទៀត បានដុតបំផ្លាញអ្វីៗដែលមាននៅក្នុងភូមិរបស់មែ។ មែបាននិយាយថា: “ផ្ទះសម្បែង ទ្រព្យសម្បត្តិ អត្តសញ្ញាណប័ណ្ណ ខោអាវ រូបថតរបស់ខ្ញុំទាំងអស់ បានឆេះក្លាយជាផ្សែងអស់រលីង។” “ខ្ញុំគ្មានសល់អីទៀតទេ”។

ប៉ូលិសបានភ្ជង់កាំភ្លើងតម្រង់អ្នកណាដែលហ៊ានការពារផ្ទះ និងទ្រព្យសម្បត្តិពួកគេ។ ដោយសារភ័យខ្លាចសុវត្ថិភាពផ្ទាល់ខ្លួន អ្នកស្រុកបានគេចខ្លួន និងស្វែងរកទីជម្រកនៅទីណាដែលពួកគាត់អាចរកបាន។

បីថ្ងៃក្រោយមក មែ ប្តីរបស់គាត់ ព្រមទាំងបុរស៦នាក់ទៀត ចាប់ផ្តើមចេញដំណើរដោយថ្មើរជើងយ៉ាង លំបាក ដើម្បីស្វែងរកជំនួយ។ មែបានពន្យល់រៀបរាប់ថា ៖ “ពួកខ្ញុំ រត់កាត់ព្រៃ ហែលឆ្លងកាត់ទឹក ដើម្បីមកប្តឹងសម្តេច ហ៊ុន សែន នៅភ្នំពេញ។ ពួកខ្ញុំបានគិតថាអាជ្ញាធរខេត្ត និងឃុំនៅពីក្រោយខ្នង។ ប្រសិនសម្តេចបានដឹង សូមឲ្យលោកជួយយើងផង”។ ទីបំផុត ក៏បានមកដល់ទីក្រុងភ្នំពេញ មែនិង ក្រុមរបស់គាត់ បដិសេធមិនឲ្យជួបនាយករដ្ឋមន្ត្រី ឬមន្ត្រីរាជរដ្ឋាភិបាលឡើយ។ ដោយសារខូចទឹកចិត្តនិងភាពនឿយហត់ ពួកគាត់បានចូលជ្រកក្នុងទីវត្តអារ៉ាមមួយនៅចំកណ្តាលទីក្រុងភ្នំពេញ។

នៅពេលយប់ មែឮសម្លេងប៉ូលិសមកដល់។ នៅពេលថ្ងៃ នៅទីកន្លែងបំផ្លិចបំផ្លាញក្នុងភូមិឯណោះវិញ ប៉ូលិសបានចាប់ខ្លួនសមាជិកសហគមន៍មួយចំនួន ដែលជាយុទ្ធសាស្ត្រចាប់បង្ខំអ្នកភូមិឲ្យចាកចេញ និងបំបិទមាត់អ្នកដែលតស៊ូ។

“ខ្ញុំភ័យតក់ស្លុតខ្លាំងណាស់។ ខ្ញុំមិនពាក់ស្បែកជើងទេ... គឺពាក់ តែអាវដៃខ្លីនិងសំពត់ខោ។ ខ្ញុំមានឈាមហូរចេញ។ គេមិនឲ្យខ្ញុំយកស្បែកជើងនិងខោអាវទេ។ ពួកគេបានទាញខ្ញុំចូលឡាន។”

ដោយសារភ័យខ្លាចថា ពួកខ្លួននឹងត្រូវចាប់ខ្លួន ដោយសារព្យាយាមទាក់ទាញអារម្មណ៍នាយករដ្ឋមន្ត្រីមកលើស្ថានភាពនេះ ប្ដីរបស់មៃនិងអ្នកបីនាក់ទៀត បានគេចខ្លួនបាន សម្រេច។ ប៉ុន្តែមៃដោយសារតែទម្ងន់មានផ្ទៃពោះ មិនអាចរត់គេចបាន។ គាត់និងបុរសបីនាក់ទៀត ត្រូវប៉ូលិសចាប់ខ្លួន។

គាត់និយាយថា ៖ “ខ្ញុំភ័យតក់ស្លុតខ្លាំងណាស់។ ខ្ញុំមិនពាក់ស្បែកជើងទេ... គឺពាក់ តែអាវដៃខ្លីនិងសំពត់ខោ។ ខ្ញុំមានឈាមហូរចេញ។ គេមិនឲ្យខ្ញុំយកស្បែកជើងនិងខោអាវទេ។ ពួកគេបានទាញខ្ញុំចូលឡាន។” បុរសបីនាក់ត្រូវបានដោះលែងភ្លាមក្រោយមក។ ប៉ុន្តែមៃត្រូវបានចោទប្រកាន់ថាជាមេខ្លោង និងត្រូវបានគេចាប់ខ្លួននិងដាក់ក្នុងពន្ធនាគារខេត្តសៀមរាប។ គាត់មិនបានឃើញ ឬដឹងដំណឹងពីប្ដីរបស់គាត់ ចាប់តាំងពីយប់នោះមក។


© អង្គការលើកលែងទោស អន្តរជាតិ



ឆ្វេង៖ មែ និងគ្រួសារ របស់គាត់ នៅផ្ទះថ្មី ក្នុងភូមិតាមាន់

## ពពោះក្នុងគុក

ដោយរងការចោទប្រកាន់ជាផ្លូវការក្នុងបទឧក្រិដ្ឋក្រោមច្បាប់ព្រៃឈើ ឆ្នាំ២០០២ មែជាប់ពន្ធនាគារអស់រយៈពេល ៨ ខែ។ ទោះបីក្តីព្រួយបារម្ភខ្លាចការរលូតកូន ដោយសារស្ថានភាពដ៏រន្ធត់ក្នុងគុក និងសុខភាពទ្រុឌទ្រោមយ៉ាងណាក៏ដោយ គត៏ក្នុងផ្ទៃពោះបានរីកចម្រើនគ្រប់ខែ។ គាត់និយាយថា ៖ “ពិតជាពិបាកខ្លាំងណាស់។ ខ្ញុំមានជំងឺនិងមានឈាមធ្លាក់មក។ ខ្ញុំឈឺខ្លាំងណាស់។ គ្មានអ្នកណាថែទាំខ្ញុំទេ។ កូនរបស់ខ្ញុំ គ្មានលុយមកសួរសុខទុក្ខខ្ញុំទេ”។

មែនិយាយថា ពេលគាត់ចេញធ្វើពលកម្ម ស្ថានភាពរបស់គាត់ខ្សោយយ៉ាងខ្លាំង ធ្វើឲ្យប្រធានគុក “មិន ហ៊ានទុក[គាត់]ក្នុងពន្ធនាគារទេ” ហើយគេបានយកគាត់ទៅកាន់មន្ទីរពេទ្យសាធារណៈ។ ខណៈពេលក្រោយមក គាត់ក៏នៅមិនទាន់ផ្តល់កំណើតកូននៅថ្ងៃនោះ ឆ្មាំគុកក៏បានយកគាត់ត្រឡប់មកគុកវិញ។ គេឲ្យគាត់ធ្វើពលកម្មអស់រយៈពេលបីថ្ងៃបីយប់នៅក្នុងពន្ធនាគារ។ ឆ្មាំគុកបានយកគាត់ទៅកាន់មន្ទីរពេទ្យ មុនពេលដែលគាត់សម្រាលកូនបន្តិច។ គាត់បាននិយាយថា ៖ “ខ្ញុំមានអារម្មណ៍មិនល្អទេ និងមិនសប្បាយចិត្តសោះ។ គ្មានប្តីនិងគ្មានគ្រួសារនៅជាមួយ ខ្ញុំមានអារម្មណ៍នៅឯកោដូចជាស្ត្រីមេម៉ាយអញ្ចឹង”។ ពីរបីម៉ោងក្រោយពេលសម្រាលកូនប្រុសរួច គេបានយកគាត់ត្រឡប់មកពន្ធនាគារវិញ។

> “ខ្ញុំមានជំងឺនិងមានឈាមធ្លាក់មក។ ខ្ញុំឈឺខ្លាំងណាស់។ គ្មានអ្នកណាថែទាំខ្ញុំទេ។ កូនរបស់ខ្ញុំ គ្មានលុយមកសួរសុខទុក្ខខ្ញុំទេ”

មែបានដាក់ឈ្មោះឲ្យកូនប្រុសឈ្មោះថា សំណាង ដោយសារគាត់គិតថាវាជាអច្ឆរិយៈមួយ ដែលកូនមានភ័ព្វសំណាងអាចនៅមានជីវិតពេលពពោះ។ រយៈពេលជិតពីរខែ គាត់ចិញ្ចឹមសំណាងនៅក្នុងបន្ទប់មួយក្នុងពន្ធនាគារ



© អង្គការលីកាដូ

ដែលមានស្ត្រីប្រាំពីរនាក់ទៀតនៅជាមួយ។ ដោយកង្វះខាតជីវជាតិ និងខ្សោយ គាត់បានថែទាំខ្លួនឯងផងនិងទារកផង តាមលទ្ធភាពដែលអាចធ្វើបាន។ បាយសម្រាប់ចិញ្ចឹមអ្នកទោសគឺកខ្វក់ និងស្ទើរតែមិនអាចហូបបាន។ មែមិនអាចផលិតទឹកដោះខ្លួនឯងបានគ្រប់គ្រាន់សម្រាប់ចិញ្ចឹមសំណាងទេ។ មានការលំបាកសំអាតបន្ទប់ និងខោអាវឲ្យបានស្អាតណាស់។ មែនិយាយថាសុខភាពកូន និងរូបគាត់មានសភាពអាក្រក់មែនទែន។

នៅទីបញ្ចប់ ក្នុងខែមិថុនា ឆ្នាំ២០១០ រយៈពេល៨ខែក្រោយពេលឃុំឃាំង មែត្រូវបាននាំខ្លួនចំពោះមុខចៅក្រមម្នាក់។ ជំនួសដោយការកាត់ក្តីគាត់អំពីបទកាប់ឆ្ការព្រៃខុសច្បាប់ ដែលជាមូលហេតុសម្រាប់ការចាប់ខ្លួនគាត់ តុលាការបានប្រាប់មែថា គេនឹងដោះលែងគាត់ប្រសិនគាត់ចុះហត្ថលេខាលើកិច្ចសន្យាមួយ យល់ព្រមដកពាក្យបណ្តឹងទាំងអស់ដែលថាជាដីរបស់គាត់នៅក្នុងភូមិបុស និងយល់ព្រម ទទួលសំណងជាដីជំនួសវិញ។ មែបានចុះហត្ថលេខាលើកិច្ចសន្យាមួយ ហើយបានធ្វើដំណើរទៅខេត្តឧត្តរមានជ័យវិញ។ គាត់មិនបានទទួលដីមួយដុំដែលគេបានសន្យានោះទេ។

## វិលត្រឡប់មកខេត្តឧត្តរមានជ័យវិញ



© អង្គការលើកលែងទោស អន្តរជាតិ

ម៉ែបានវិលត្រឡប់មកខេត្តដែលជាស្រុកកំណើតវិញ ដោយមានអារម្មណ៍រំជើបរំជួលច្របល់គ្នា។ គាត់សប្បាយចិត្ត ដោយដឹងថាកូនតូចៗមានសុវត្ថិភាព និងកំពុងរស់នៅផ្ទះឈើតូចមួយជាមួយកូនស្រីបង បង្អស់របស់គាត់ក្នុងភូមិតាមាន់។ កូនច្បងគេរបស់គាត់ជ្រើសយកការឆ្លងដែន កាត់ចូលព្រំដែនថៃដែលនៅជិតនោះ ដើម្បីស្វែងរកធ្វើការធ្វើ។ គាត់ទទួលដំណឹងដែរថា ប្ដីរបស់គាត់នៅក្នុងប្រទេសថៃ ប៉ុន្តែគ្មានអ្នកណាម្នាក់អាចបញ្ជាក់ថាគាត់នៅទីកន្លែងណានោះទេ។

កូនៗព្រមទាំងប្ដីរបស់គាត់ មិនបានផ្ញើរប្រាក់ឲ្យគាត់ទេ។ សព្វថ្ងៃ ម៉ែបានខិតខំតស៊ូចិញ្ចឹមគ្រួសាររបស់គាត់។ កូនប្រុសវ័យជំទង់របស់គាត់ដើរចាប់កង្កែប និងសត្វបង្កួយសម្រាប់ហូបនិងលក់ដូរ។ កូនស្រីអាយុ៧ឆ្នាំជួយម៉ែនិងក្រុមគ្រួសារ ដូចជារែកទឹកអណ្ដូងក្នុងភូមិនៅពេលយប់ ជាពេលទឹកអណ្ដូងមិនទាន់រីងស្ងួត។ សំណាង បានចម្រើនវ័យអាយុជាងមួយខួបហើយ ប៉ុន្តែម៉ែនៅតែបំបៅទឹកដោះវាទៀតដោយសារកង្វះខាតអាហារផ្សេងទៀតចិញ្ចឹមវា។ កូនស្រីម្នាក់របស់ម៉ែ ដែលបានទៅប្រទេសថៃ បានទុកកូនរបស់ខ្លួន ដែលមានអាយុពីរខែតិចជាងសំណាង។ ម៉ែត្រូវមើលថែទាំចៅរបស់គាត់។ គាត់ព្យាយាមចិញ្ចឹមគ្រួសារ ដោយហូបបាយតិចៗពីរដង ដែលឧបត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាលមួយ ឬ ដោយសារចិត្តអណិតអាសូររបស់អ្នកជិតខាងមួយ និងអ្វីក៏ដោយដែលពួកគាត់អាចរកបានប្រចាំថ្ងៃ។

ឥឡូវនេះ ម៉ែមានអាយុ ៤៨ ឆ្នាំ មានកូនប្រាំបីនាក់ អាយុចន្លោះពី ២៨ ឆ្នាំ និងជាងមួយខួប។ គាត់ពន្យល់រៀបរាប់ថា គាត់មិនចង់បានកូនច្រើនទេ ប៉ុន្តែដោយមិនបានរៀនសូត្រអំពីវិធីពន្យាកំណើត។ ទោះបីមានកូនច្រើនយ៉ាងណាក្ដី ពីមុនការបណ្ដេញចេញ គាត់បាននិយាយរំឭកអំពីពេលសម្បូរសប្បាយថា ៖ “គ្រួសារតែងតែមានអាហារគ្រប់គ្រាន់... មិនដែលដាច់អាហារហូបចុកទេ។ យើងអាចរកត្រី និងសាច់បាន។ យើងអាចដើរដកបេះផ្សិត [ប្អូនប្រភេទ] សម្រាប់ហូប និងលក់”។

ម៉ែមានកំណើត និងធំដឹងក្ដីនៅក្នុងភូមិបុស។ គ្រួសាររបស់គាត់អាចរស់នៅក្នុងតំបន់នោះក្នុងរបបខ្មែរក្រហម។ ម៉ែបានជួបជាមួយប្ដីរបស់គាត់ដែលជាទាហាន បន្ទាប់ពីរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩។

ឧត្តរមានជ័យគឺជាខេត្តសំបូរទៅដោយគ្រាប់មីន ដែលបានបន្សល់ទុកពីសម័យសង្គ្រាមស៊ីវិល (ចន្លោះឆ្នាំ១៩៧០ និង១៩៧៥) ដូចនេះ ប្រជាពលរដ្ឋក្នុងភូមិបុស មិនបានរីកចម្រើនច្រើនទេ ទើបតែឆ្នាំ១៩៩៨ នេះឯង ដែលមានការបោសសំអាតគ្រាប់មីនចេញពីដីដើម្បីសុវត្ថិភាព។ ខណៈពេលដែលចំនួនប្រជាពលរដ្ឋមានកំណើនដល់ជាង ២០០ គ្រួសារ អាជ្ញាធរមូលដ្ឋានបានផ្ដល់ដីស្រែចំនួន ៥ ហិកតាបន្ថែមទៀតដល់ក្រុមគ្រួសាររបស់ម៉ែ និងអ្នកភូមិផ្សេងទៀតនៅក្នុងភូមិនៅក្នុងឆ្នាំ២០០៣។ លំនៅឋានរបស់អ្នកភូមិមានលក្ខណៈសាមញ្ញ ក៏ប៉ុន្តែមានសុខដុមរមនា។ គាត់បានជីកអណ្ដូងមួយនៅក្បែរផ្ទះរបស់គាត់ សម្រាប់ផ្គត់ផ្គង់ទឹកឲ្យបានគ្រប់គ្រាន់។ មានបន្ទប់ទឹកដាច់ដោយឡែកមួយ សម្រាប់ប្រើជាឯកជន និងមានអនាម័យត្រឹមត្រូវ។ មិនមានភ្លើងអគ្គិសនីទេ។ គ្រួសាររបស់គាត់ប្រើចង្កៀងប្រេងកាត សម្រាប់បំភ្លឺនៅពេលយប់។ ទោះបីគាត់គ្មានលទ្ធភាពឲ្យកូនបានទៅរៀនសូត្រទាំងអស់គ្នាក្ដី កូនពីរនាក់របស់គាត់ ដែលបានចុះឈ្មោះចូលរៀន ត្រូវដើរទៅរៀនតាមផ្លូវដ៏សែនឆ្ងាយ។



© អង្គការលើកលែងទោស អន្តរជាតិ

រូបថតពីខាងឆ្វេង៖ ម៉ែលាងចាន។ ចាប់តាំងពី ការបណ្តេញចេញមក ម៉ែតស៊ូ ចិញ្ចឹមគ្រួសាររបស់ គាត់។ ពេលខ្លះ គាត់ហូបកង្កែប និងសត្វបង្កួយ។ ឥឡូវ គាត់រស់នៅ ផ្ទះកូនស្រីរបស់គាត់ ក្នុងភូមិតាមាន់។ ម៉ែចំអិនអាហារ ខណៈដែលពសំណាង





© អង្គការលើកលែងទោស អន្តរជាតិ



© អង្គការលើកលែងទោស អន្តរជាតិ

## ទីវាលគ្មានមនុស្សរស់នៅ

សព្វថ្ងៃ ក្នុងភូមិរបស់ម៉ៃ គ្មានអ្វីនៅសេសសល់ទៀតទេ។ ផ្ទុយទៅវិញ កម្មករក្រុមហ៊ុនដែលបំពាក់ដោយអាវុធ បានចាំយាមចំការអំពៅ ដែលឡោមព័ទ្ធជុំវិញដោយទីវាលគ្មានមនុស្សរស់នៅ។ មួយទសវត្សរ៍កន្លងមកនេះ តំបន់នេះគ្របដណ្តប់ ទៅដោយព្រៃក្រាស់ខៀវស្រងាត់ បានទទួលរងការកាប់បំផ្លាញយកឈើហុបយ៉ាងធ្ងន់ធ្ងរ ទោះបីមានការហាមឃាត់ទូទាំងប្រទេសចាប់ពីឆ្នាំ២០០២ យ៉ាងណាក៏ដោយ។ តំបន់ស្ទើរទាំងមូល ត្រូវបានគេជីកកកាយ គាស់រម្លើងទាំងស្រុង និងក្លាយជាកម្មសិទ្ធិរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច។

រយៈពេលមួយទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលបានផ្តល់សម្បទានដីឲ្យវិនិយោគិនបរទេស និងខ្មែរ ដោយមិនបានធ្វើការវាយតម្លៃគ្រប់គ្រាន់ និងមិនបានបន្ធូរបន្ថយផលប៉ះពាល់លើសហគមន៍ដែលពួកគាត់រស់នៅ ឬពឹងអាស្រ័យលើដីធ្លីទាំងនោះ។ របាយការណ៍ឆ្នាំ២០០៧ របស់តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា បានរកឃើញថា សម្បទានដីសេដ្ឋកិច្ច "មានផលប៉ះពាល់ជាអវិជ្ជមានលើសិទ្ធិមនុស្ស និងជីវភាពរស់នៅរបស់សហគមន៍ជនបទ"។

ជារឿយៗ ការផ្តល់សម្បទានដីទាំងនេះ ឬការរំលោភមកលើដីលំនៅឋាន និងដីកសិកម្មរបស់ប្រជាពលរដ្ឋ ដោយគ្រាន់តែប្រឹក្សាយោបល់បន្តិចបន្តួច ឬគ្មានទាល់តែសោះ ជាមួយនឹងសហគមន៍មូលដ្ឋាន។ សម្រាប់ភាគច្រើននៃប្រជាពលរដ្ឋទាំងនោះ ដែលត្រូវបានគេបង្ខំឲ្យបោះបង់ដីរបស់ខ្លួនមួយផ្នែក ឬទាំងមូល ជាធម្មតាមិនទទួលបានសំណងគ្រប់គ្រាន់ សម្រាប់ពួកគាត់ស្វែងរកលំនៅឋានសមរម្យមួយ ឬសម្រាប់ប្រកបរបរចិញ្ចឹមជីវិត។ ជាញឹកញាប់ ប្រជាពលរដ្ឋទាំងនោះត្រូវបានបណ្តេញចេញដោយបង្ខំ។

ជាទូទៅ ជនដែលប៉ុនប៉ងចង់បានសម្បទានដីសេដ្ឋកិច្ច និងចង់បានចំណេញពីសម្បទានដីរបស់ខ្លួន តែងគេចវេះពីវិធីដោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព។ ខណៈពេលដែលទិន្នន័យពិតប្រាកដគឺមិនមានជាសាធារណៈ គេអាចប៉ាន់ស្មានបានថា សម្បទានដីសេដ្ឋកិច្ច មានទំហំគ្របដណ្តប់លើសពី ៥០ ភាគរយនៃផ្ទៃដីដាំដុះទាំងអស់របស់ប្រទេសកម្ពុជា។

គោលបំណងផ្លូវការចំពោះសម្បទានដីសេដ្ឋកិច្ច គឺការអភិវឌ្ឍន៍ចំការដំណាំកសិឧស្សាហកម្ម។ គេហទំព័ររបស់ក្រសួងកសិកម្ម បង្ហាញឲ្យឃើញថា នៅថ្ងៃទី ២៤ មករា ២០០៨ មានសម្បទានដីសេដ្ឋកិច្ចបី សម្រាប់រយៈពេល ៧០ ឆ្នាំ ត្រូវបានផ្តល់ឲ្យក្រុមហ៊ុនឯកជនក្នុងខេត្តឧត្តរមានជ័យ រួមទាំងផ្ទៃដីដែលព័ទ្ធជុំវិញភូមិបុសដែរ។ សម្បទានដីនីមួយៗសុទ្ធតែមានបំណងដូចៗគ្នា គឺសម្រាប់ដាំដំណាំចំការអំពៅ និងរោងចក្រកែច្នៃផលិតស្ករ។ ជាទូទៅ គេបង្កើតក្រុមហ៊ុនចម្រុះ ដោយមានម្ចាស់តែម្នាក់ និងដាក់ពាក្យស្នើសុំសម្បទានដីដែលជាប់ៗគ្នា។ គេធ្វើវិធីដូចនោះគឺដើម្បីគេចវេះពីច្បាប់ប្រទេសកម្ពុជា ដែលកំណត់ថាទំហំសម្បទានដីមិនត្រូវលើសពី ១០,០០០ ហិកតាទេ។

ស្របពេលនោះដែរ ម៉ៃស្ថិតក្នុងភាពទុគ៌តអស់រលីងពីខ្លួន ហើយគ្រួសាររបស់គាត់ខ្ចាត់ព្រាត់គ្នាថែមទៀត។ គាត់បានរៀបរាប់ថា ៖ "រាល់ថ្ងៃ គេគួរមើលយកចិត្តទុកដាក់ប្រជារាស្ត្រ។ ហេតុអ្វី ពួកគេ បណ្តោយឲ្យ [ក្រុមហ៊ុន] រំលោភយកដីរបស់ប្រជារាស្ត្រ ដូចនេះ?"។ ដោយគ្មានផ្ទះសម្បែងខ្លួនឯង គ្មានដីស្រែ គ្មានប្តី និងមានកូន៥នាក់មើលថែទាំ អ្វីៗគ្រប់យ៉ាងដែលគាត់អាចធ្វើបាននៅពេលនេះ គឺព្យាយាមរស់ពីមួយថ្ងៃទៅមួយថ្ងៃ។ "ខ្ញុំមិនដឹងជាសង្ឃឹមអីទៀតទេ។ អស់រលីងហើយ"។

*ហួយ ម៉ៃ បានផ្តល់ការសម្ភាសន៍ជាមួយអង្គការលើកលែងទោសអន្តរជាតិ នៅថ្ងៃទី១៧ មីនា ២០១១*


© អង្គការលើកលែងទោសអន្តរជាតិ



“រាល់ថ្ងៃ គេគួរមើលយកចិត្តទុកដាក់ប្រជារាស្ត្រ។ ហេតុអ្វី ពួកគេ បណ្ដោយឲ្យ [ក្រុមហ៊ុន] រំលោភយកដីរបស់ប្រជារាស្ត្រ ដូចនេះ?។”

# សុផល

ពួកគេមកពេលយប់ មករុះរើផ្ទះ។
ខ្ញុំបានសុំអង្វរកុំបំផ្លាញផ្ទះរបស់ខ្ញុំ
និងទុកឲ្យខ្ញុំរើឥវ៉ាន់ចេញក្រៅសិន។
ប៉ុន្តែពួកគេមិនព្រម។ អ្វីដែលខ្ញុំស្រោចស្រង់យកបាន
គឺម៉ាស៊ីនដេរមួយគ្រឿង។




រដ្ឋ សុផល (ឆ្វេង) និងប្អូនជីដូនមួយរបស់គាត់ ឈ្មោះឃុន
នារី នៅផ្ទះថ្មី នៅកន្លែង តាំងទីលំនៅថ្មីដំណាក់ត្រយឹង
ភ្នំពេញ ខែមិថុនា ២០១១។



© អង្គការលើកលែងទោស អន្តរជាតិ

ការមើលពីលើ តំបន់ដីក្រហម ទីក្រុងភ្នំពេញ
រយៈពេលពីរឆ្នាំមុនការបណ្តេញចេញ



នៅព្រឹកមួយ ក្នុងខែមករា ឆ្នាំ២០០៩ ប្រជាពលរដ្ឋចំនួន ៤០០ គ្រួសារ ត្រូវបានបណ្តេញចេញដោយបង្ខំចេញពីផ្ទះរបស់ពួកគាត់ ដែលស្ថិតក្នុងតំបន់ដីក្រហម ចំកណ្តាលទីរាជធានីភ្នំពេញ។ ពួកគាត់ បានទទួលរងការវាយប្រហារកងកម្លាំងជាច្រើនរយនាក់ មានដូចជាកងនគរបាល កម្មករឯកជនស៊ីឈ្នួលរុះរើដែលប្រដាប់ដោយពូថៅ ញញួរ រនុកដែក និងដំបងឆក់អគ្គិសនី។ នៅពេលគ្រឿងចក្រឈូសឆាយ និងពង្រាបដី បានឈូសកកាយពង្រាបផ្ទះរបស់ពួកគាត់ អ្នកភូមិបានព្យាមយាម ស្រោចស្រង់ទ្រព្យសម្បត្តិរបស់ពួកគេទាំងអស់សង្ឃឹម។ ខណៈនោះប៉ូលិសបានបាញ់គ្រាប់ជ័រកៅស៊ូ និងប្រើឧស្ម័នបង្ហូរទឹកភ្នែក និងបាញ់ទឹកដាក់លើពួកគាត់។ ទោះបីប្រជាពលរដ្ឋរាប់រយគ្រួសារ ត្រូវបានគេបំភិតបំភ័យឲ្យចាកចេញអស់ជាច្រើនខែនិងឆ្នាំ មុនការបណ្តេញចេញក៏ដោយបង្ខំក្តី គ្រួសារដែលនៅសេសសល់ បានបន្តទាមទារសុំឲ្យគោរពសិទ្ធិលំនៅឋាន និងសំណងដ៏សមរម្យ។ រាល់ការព្យាយាមចចារដោះស្រាយ ត្រឹមត្រូវ ឬស្វែងរកការដោះស្រាយដែលអាចទទួលយកបាន បានបរាជ័យ។ ក្រុមគ្រួសារជាច្រើន ដែលត្រូវបានបណ្តេញចេញដោយបង្ខំ នៅពេលនេះពួកគេកំពុងរស់នៅតំបន់តាំងទីលំនៅថ្មីមួយកន្លែង ស្ថិតនៅជាយរាជធានីភ្នំពេញ។

សុផល អាយុ ៣១ ឆ្នាំ អង្គុយលើកម្រាលឥដ្ឋនៅក្នុងផ្ទះល្វែងរបស់គាត់ កំពុងបញ្ចុកបាយកូនស្រីតូច ឈ្មោះធីតា។ ផ្ទះនេះជាផ្ទះថ្មសាមញ្ញមួយដែលមានទំហំ ៤ ម៉ែត្រគុណនិង ១០ ម៉ែត្រ ស្ថិតនៅតំបន់តាំងទីលំនៅថ្មី នៅឯដំណាក់ត្រយឹង។ សុផល រៀបរាប់ថាប្តីរបស់គាត់រស់នៅ និងធ្វើការនៅភ្នំពេញ ហើយគ្រួសារដែលមានសមាជិកច្រើនរបស់គាត់ រួមទាំងសហគមន៍គឺបែកបាក់គ្នាអស់ហើយ ដោយសារការបណ្តេញចេញដោយបង្ខំ។ គាត់ប្រើពេលសឹងតែទាំងអស់របស់គាត់ រស់នៅយ៉ាងកណ្តោចកណ្តែងជាមួយនឹងធីតា។

ដំណាក់ត្រយឹង មានចម្ងាយប្រហែល ២០ គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ រចនាសម្ព័ន្ធសំណង់ជាជួរ មានលក្ខណៈដូចយានដ្ឋានជួសជុលរថយន្ត មើលទៅវាផ្ទុយស្រឡះពីតំបន់សហគមន៍ដីក្រហម និងសហគមន៍តន្ត្រីករ និងសិល្បករ ដែលធ្លាប់មាននៅក្នុងសង្កាត់ទន្លេបាសាក់ រាជធានីភ្នំពេញ។ ដីក្រហមមានន័យថាជាដីពណ៌ក្រហមជាភាសារខ្មែរ។ ភូមិឋាននេះកកើត មានជាឈ្មោះក្នុងទសវត្សរ៍ ១៩៨០ ពេលក្រោយពីរបបខ្មែរក្រហម ដែលអ្នកភូមិរស់បានចាក់បំពេញដីក្រហមក្នុងតំបន់ដីលិចទឹក ដើម្បីធ្វើជាគ្រឹះសម្រាប់សាងសង់ផ្ទះពួកគេ។ សិល្បករនិងតន្ត្រីករ ទទួលបានដីឡូក្នុងតំបន់ដីក្រហម ពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ អ្នកផ្សេងទៀត បានមកតាំងទីលំនៅទីនោះ ក្រោយពេលមាតុភូមិនិវត្ត ពីជំរំជនភៀសខ្លួននៅព្រំដែនប្រទេសថៃនៅដើមទសវត្សរ៍ ១៩៩០។ ពីមួយឆ្នាំទៅមួយឆ្នាំ ប្រជាពលរដ្ឋកាន់តែច្រើនគ្រួសារ បានមកទិញដីឡូនៅក្នុងភូមិ ដែលជាតំបន់ផ្តល់អំណោយផល ដោយសារតែជាទីតាំងនៅកណ្តាលរាជធានីផង និងផ្តល់ឱកាសរកការងារផង។

សុផលមានអាយុ ១១ ឆ្នាំ ក្នុងឆ្នាំ១៩៩០។ គ្រួសាររបស់គាត់បានទិញដីមួយឡូ ក្នុងភូមិដីក្រហម ហើយបានសាងសង់ផ្ទះមួយសម្រាប់រស់នៅ។ ប៉ុន្មានឆ្នាំបន្តបន្ទាប់មក ភូមិករនិងរាជធានីភ្នំពេញ បានផ្លាស់ប្តូរយ៉ាងគំហុកនៅជុំវិញគាត់។



កិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលមានបំណងបញ្ចប់ជម្លោះផ្ទៃក្នុងអស់ជាច្រើនទសវត្សរ៍ ត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ១៩៩១ ភ្លាមៗក្រោយពេលការហូរចូលជនបរទេស ដែលបម្រើការ ឲ្យអង្គការសហប្រជាជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនអនេក។ បេះដូងរាជធានីមានកំណើនប្រជាពលរដ្ឋយ៉ាងរហ័ស ព្រោះប្រជាពលរដ្ឋខ្មែរបានស្វះស្វែងរួមចំណែកក្នុងសករាជថ្មី ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច។

សុផលធំដឹងក្តី ដោយសង្ឃឹមជឿជាក់ក្នុងឆាកជីវិត និងមានក្តីស្រម័យចង់ក្លាយជាអ្នកជំនាញកាត់ដេរខោអាវ។ ពេលគាត់មានវ័យធំល្មម គាត់បានចាប់ផ្តើមមុខរបរតូចមួយ ជាអ្នកធ្វើក្រចក និងជាងកាត់ដេរ នៅផ្ទះរបស់គាត់។ អតិថិជនរបស់គាត់គឺអ្នកភូមិនៅជុំវិញនោះ តែងមករកគាត់ជាញឹកញាប់។ គាត់បានរៀបការជាមួយបុរសម្នាក់ក្នុងភូមិ។ គាត់ឈ្មោះសុខា និងមានតែជើងម្ខាង។

គាត់និយាយថា ៖ “មានបុរសជាច្រើនមកស្តីស្នើខ្ញុំ ប៉ុន្តែខ្ញុំមិនពេញចិត្តពួកគាត់ទាល់តែសោះ។ ខ្ញុំគិតថាមនុស្សប្រុសមិនគោរពស្ត្រីទេ។ ប៉ុន្តែប្តីរបស់ខ្ញុំ ខ្ញុំបានជ្រើសរើសគាត់។ គាត់ពិការពិតមែន ប៉ុន្តែមិនដូចបុរសផ្សេងទេ... គាត់មិនខ្ជិលទេ”។ ក្រោយពេលអាពាហ៍ពិពាហ៍ សុខាបានធ្វើការនៅរោងបោះពុម្ពមួយនៅជិតផ្ទះ ហើយវិលត្រឡប់មកផ្ទះវិញនៅពេលល្ងាច ហូបបាយ។ សុផល ព្រមទាំងក្រុមគ្រួសារប្រឹងប្រែងធ្វើការ ហើយចូលចិត្តសហគមន៍ សេវាកម្ម និងទីតាំងគ្រឿងបរិក្ខារ ដែលអាជ្ញាធរក្រុង បាន ផ្តល់ឲ្យ។

នៅពាក់កណ្តាលទសវត្សរ៍២០០០ តំបន់ដីក្រហមបានរងការគំរាមកំហែង។ សាលារាជធានីភ្នំពេញ រួមគ្នាជាមួយក្រុមហ៊ុន បានឈូសឆាយពង្រាបសហគមន៍លំនៅឋានចាស់ៗ ដែលនៅជុំវិញតំបន់ទន្លេបាសាក់ ដើម្បីត្រួសត្រាយផ្លូវសម្រាប់សាងសង់អគារថ្មីទំនើបៗ។ អគាររដ្ឋាភិបាលថ្មី

សណ្ឋាគារដែលមានផ្សារ និងស្ថានទូតរបស់អូស្ត្រាលីថ្មីត្រូវបានគ្រោងឡើង។ គ្រួសាររបស់ពលរដ្ឋដែលបានតាំងទីលំនៅ ឬបានទិញដីក្នុងភូមិដីក្រហម និងភូមិដែលនៅជុំវិញនោះគឺស្ថិតនៅចំទីតាំងអចលទ្រព្យដ៏មានតម្លៃបំផុតក្នុងភ្នំពេញ។ នៅពេលតម្លៃដីបានឡើងថ្លៃកាន់តែខ្លាំងនោះ អ្នកជំនួញ និងមន្ត្រីរាជរដ្ឋាភិបាល បានសម្លឹងមើលឃើញយ៉ាងចាប់អារម្មណ៍មកលើភូមិ “ដែលមិនបានគិតទុកមុន”។ ក្នុងករណីដីក្រហមនេះ តម្លៃរបស់វាខ្ពស់ខ្លាំងណាស់ ៖ ក្នុងឆ្នាំ២០០៧ ទីតាំងទំហំ ៣.៦ ហិកតា មានតម្លៃប្រហែល ៤៤ លានដុល្លារសហរដ្ឋអាមេរិក បើតាមភ្នាក់ងារអចលនទ្រព្យក្នុងស្រុកមួយ។

## ក្បត់ពាក្យសន្យា

ភូមិដីក្រហម គ្មានផ្លូវចាក់ក្រាលកៅស៊ូ ឬផ្ទះស្ថិតនៅជាជួរទេ។ ពុំមានចេញជាកម្មសិទ្ធិជាផ្លូវការ ឲ្យទៅប្រជាពលរដ្ឋប្រហែល៨០០ គ្រួសារទេ ទោះបីមានឯកសារទទួលស្គាល់ ដែលបានចេញដោយអាជ្ញាធរមូលដ្ឋានអស់ជាច្រើនឆ្នាំក៏ដោយ។ ផ្ទះមានសណ្ឋានចាប់ពីផ្ទះដែលធ្វើពីឈើដែលញ៉ូរៗ រហូតដល់រាងសណ្ឋានជាផ្ទះថ្មធ្វើពីឥដ្ឋដែលមានជាន់ថ្នាក់។ ដោយសារក្រុមគ្រួសារជាច្រើនដែលរស់ក្នុងតំបន់ដីក្រហមជាគ្រួសារក្រីក្រ ពួកគាត់បានចូលរួមបង្កបង្កើតផ្នែកសេដ្ឋកិច្ចក្នុងភូមិ និងទីក្រុងនៅជុំវិញភូមិ ជានឹងការខិតខំធ្វើការងារ ពួកគេក៏មានលទ្ធភាពលើកស្ទួយជីវភាពរស់បានកាន់តែប្រសើរបន្តិចម្តងៗ។

យោងតាមច្បាប់ភូមិបាលប្រទេសកម្ពុជា អ្នកភូមិដីក្រហមទាំងឡាយណា ដែលបានរើមកតាំងទីលំនៅបានមុនឆ្នាំ២០០១ និងត្រឹមត្រូវតាមលក្ខខណ្ឌ ដូចបានចែងនៅក្នុងច្បាប់ គឺមានសិទ្ធិកាន់កាប់និងមានសិទ្ធិដាក់ពាក្យសុំកម្មសិទ្ធិ។ ប៉ុន្តែការដាក់ពាក្យសុំបែបនោះ ត្រូវបានគេបដិសេធចោល ឬមិនអើពើ។

សុផលបានពន្យល់ថា ៖ “សហគមន៍ដីក្រហមរបស់យើង នៅពេលដែលយើងបានប្រឈមមុខជាមួយក្រុមហ៊ុន យើងបានយល់ស្របទាំងអស់គ្នា

> “ពួកគេមិនដែលមកសួរខ្ញុំ
> ដែលជាម្ចាស់ផ្ទះផ្ទាល់សោះឡើយ។
> ពុំមានការដោះដូរជាមួយប្រជាពលរដ្ឋទេ”។

ដើម្បីស្នើសុំប័ណ្ណកម្មសិទ្ធិពីអាជ្ញាធរ។ យើងបានដាក់ពាក្យសុំ... យើងបានរង់ចាំហើយរង់ចាំទៀត... មិនដែលបានលទ្ធផលទេ។” ទោះជាយ៉ាងនេះក៏ដោយ សុផលមិនបានដឹងថា ក្រុមហ៊ុនមួយឈ្មោះសេវេនអិនជី (7NG) បានទទួលប័ណ្ណកម្មសិទ្ធិរួចហើយ នៅក្នុងខែធ្នូ ឆ្នាំ២០០៦នោះទេ។

ក្នុងឆ្នាំ២០០៥ ក្រុមហ៊ុនសេវេនអិនជី បានចាប់ផ្តើមចែចូវជាមួយមេសហគមន៍ដីក្រហម ដើម្បីធ្វើការដោះដូរដី យកផ្ទះដែលបានសាងសង់នៅលើដីតម្លៃថោក នៅដំណាក់ត្រយឹង នៅជាយទីក្រុងភ្នំពេញ។ កាលពីពីរឆ្នាំមុននោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាថា ដីក្រហមជាភូមិមួយដែលក្រីក្រជាយក្រុងក្នុងរាជធានីភ្នំពេញ ដែលនឹងត្រូវបានទទួលស្គាល់និងគាំទ្រជាផ្លូវការ សម្រាប់ឲ្យធ្វើការអភិវឌ្ឍន៍នៅនឹងកន្លែង។

នៅពេលដែលអ្នកភូមិដឹងថា ការអភិវឌ្ឍន៍នៅនឹងកន្លែង មិនត្រូវបានដំណើរការទៅមុខតាមការសន្យា ដោយពួកមេៗសហគមន៍ ត្រូវបានគេបញ្ចុះបញ្ចូលឲ្យទទួលយកការដោះដូរដី សម្រាប់តំណាងរបស់ប្រជាពលរដ្ឋ។ អ្នកភូមិខឹងក្រេវក្រោធយ៉ាងខ្លាំង។ ក្រោមច្បាប់ប្រទេសកម្ពុជា មេសហគមន៍ទាំងនោះ គ្មានអំណាចលក់ដីរបស់អ្នកភូមិទេ ហើយកិច្ចសន្យាដែលធ្វើនោះគ្មានសុពលភាពទៅតាមច្បាប់ទេ។ សុផលបានពន្យល់ថា ៖ “ពួកគេមិនដែលមកសួរខ្ញុំ ដែលជាម្ចាស់ផ្ទះផ្ទាល់សោះឡើយ។ ពុំមានការដោះដូរជាមួយប្រជាពលរដ្ឋទេ”។ អ្នកភូមិបានបណ្តេញនិងដាក់ពាក្យប្តឹងមេសហគមន៍នៅឯតុលាការ ពីបទរំលោភលើសេចក្តីទុកចិត្ត និងសុំឲ្យលុបចោលកិច្ចសន្យានោះ។ តុលាការធ្វើមិនដឹងមិនឮនឹងពាក្យបណ្តឹងរបស់សហគមន៍។

អ្នកភូមិដីក្រហមគូរសញ្ញា “សន្តិភាព”ដើម្បីធ្វើការតវ៉ា
មុនការបណ្តេញចេញពួកគេ ខែមករា ២០០៩



## ការតស៊ូចាប់ផ្តើម

ផ្នែកនេះបានកត់សម្គាល់នូវការតស៊ូរយៈពេលបីឆ្នាំ ទោះបីមានយុទ្ធនាការណ៍គួរឲ្យកត់សំគាល់មួយ ដើម្បីការពារសិទ្ធិដីធ្លីរបស់ពួកគាត់ក៏ដោយ ដែលទីបំផុតការតស៊ូនោះត្រូវចប់ ដោយត្រឹមតែធ្វើឲ្យគ្រួសារសុផលនិងសហគមន៍ខូចចិត្ត។ ក្រុមហ៊ុននិងអាជ្ញាធរ បានដាក់សំពាធមកលើអ្នកភូមិ ឲ្យទទួលយកកិច្ចសន្យាមួយ ទៅរស់នៅផ្ទះល្វែងនៅដំណាក់ត្រយឹង ឬទទួលយកសំណងជាទឹកប្រាក់ចំនួន ៨,០០០ ដុល្លារសហរដ្ឋអាមេរិក។ ពេលសំពាធកាន់តែកើនខ្លាំងឡើង ជាច្រើនរយនាក់នៃប្រជាពលរដ្ឋ ៨០០គ្រួសារដំបូង បានរុះរើផ្ទះរបស់ខ្លួនហើយបានចាកចេញ។

ចំពោះក្រុមគ្រួសាររបស់សុផល ការរំពឹងចាកចេញពីផ្ទះនៅដីក្រហមដោយសំណងត្រឹមតែ ៨,០០០ដុល្លារនោះ គឺជារឿងដែលមិនអាចគិតស្មានដល់ទេ។ “ខ្ញុំមិនទទួលយកទេ។ ខ្ញុំមិនយល់ព្រមនឹងតម្លៃ៨,០០០ ដុល្លារទេ ពីព្រោះប្រសិនខ្ញុំចាកចេញនោះខ្ញុំនឹងបាត់បង់ការងារទាំងអស់ ដែលនៅជាប់ផ្ទះរបស់ខ្ញុំ។ វានឹងបាត់បង់ប្រាក់ចំណូល”។ ដោយសារក្រុមគ្រួសារ ដែលដូចគ្នានឹងគ្រួសារសុផល បានសម្រេចចិត្តមិនទទួលយកសំណង ហើយបន្តការស្នាក់នៅ ក្រុមហ៊ុនបានធ្វើការគំរាមកំហែងហើយក៏បានប្រែក្លាយទៅជាអំពើហិង្សា។

សុផលនិយាយរំឭកថា ៖ “ពេលខ្លះក្រុមហ៊ុនមកពេលយប់។ ពួកគេមកពេលយប់ មករុះរើផ្ទះ។ យើងនាំគ្នាការពារ ប៉ុន្តែក្រុមហ៊ុនមានឧបករណ៍ច្រើន។ សម្រាប់ប្រជាពលរដ្ឋ គឺមានតែព្រួតដៃគ្នា... មានទាស់ទែងសម្តីគ្នា រវាងក្រុមហ៊ុននិងប្រជាពលរដ្ឋ។ វាកើតឡើងច្រើនលើកច្រើនសារណាស់ រហូតដល់ក្រុមហ៊ុនបានវាយដំប្រជាពលរដ្ឋ។ ពួកគេដាក់ខ្នោះប្រជាពលរដ្ឋ ធ្វើឲ្យបែកក្បាល... គឺអ្នកដែលពាក់ស្បែកជើងទាហាន បានទាត់ប្រជាពលរដ្ឋ។ ខ្ញុំបានឃើញផ្ទាល់... ពួកខ្ញុំបានព្យាយាមដោះស្រាយបញ្ហាដោយសន្តិវិធី គឺមិនចាំបាច់ប្រើអំពើហិង្សាមកលើប្រជាពលរដ្ឋទេ”។

មេសហគមន៍ខ្លះ ចុះញ៉មដោយសារសំពាធ ហើយបានលក់ដីរបស់គាត់ទៅឲ្យក្រុមហ៊ុន។ អ្នកភូមិដែលនៅសេសសល់ បានប្រយុទ្ធតបវិញ ដោយនាំគ្នាធ្វើសន្និសីទកាសែតនិងពិធីប្រគំតន្ត្រី ដើម្បីបង្ហាញសាធារណជនថា សហគមខ្លួន គឺជាសហគមដែលប្រកបដោយការច្នៃប្រឌិត និងផលចម្រើន។ ពួកគេប្តេជ្ញាប្រយុទ្ធ ដើម្បីសិទ្ធិរក្សាដី ឬសិទ្ធិទទួលសំណងសមរម្យ។

សុផលបានចូលរួមការតវ៉ាជាប្រចាំរបស់សហគមន៍ នៅក្រៅរបងសាលារាជធានីភ្នំពេញ។ “យើងបានទៅជួប [សាលាក្រុង] ដើម្បីស្នើសុំឲ្យមានដំណោះស្រាយ។ ក្រោយមក យើងបានទៅជួបក្រុមហ៊ុន។ ទីបីយើងបានទៅផ្ទះសម្តេចហ៊ុន សែន និងដាក់ឯកសារជាមួយអង្គរក្ស។ ក្រោយមកទៀត យើងរង់ចាំ ស្តាប់ដំណឹង។ យើងបានរងចាំព័ត៏មាន ប៉ុន្តែយើងមិនដែលទទួលបានដំណឹងអ្វីទាំងអស់...។ សុផលនិយាយដោយងឿងឆ្ងល់ថា ”យើងប្រឹងអស់លទ្ធភាពហើយ” ។ ចុងឆ្នាំ២០០៨ ការតស៊ូរបស់សហគមន៍ ទីបំផុតបានចាប់ផ្តើមបង្ហាញនូវលទ្ធផល។ ក្រុមហ៊ុនសេផេន អិនជី ទំនងជាចង់ចចារជាមួយសហគមន៍អំពីចំនួនប្រាក់ដែលត្រូវសងសម្រាប់ផ្ទះពួកគេ។ ទោះជាយ៉ាងណាក្តី នៅពេលជាមួយគ្នានោះ ក៏ចាប់ផ្តើមមានលេចឮពាក្យចចាមអារ៉ាមថានឹងមានការបណ្តេញចេញដ៏ធំមួយក្នុងភូមិទាំងមូលតែម្តង។ អ្នកភូមិបាននាំគ្នាយាមរៀងរាល់យប់ ដោយមិនប្រាកដថា ភូមិរបស់ពួកគាត់ ត្រូវបានឡោមព័ទ្ធនិងវាយប្រហារមុនពេលព្រះអាទិត្យរះឬយ៉ាងណានោះទេ។ សុផល ពន្យល់ថានៅពេលយប់ “យើងផ្លាស់ប្តូរវេនគ្នា។ ម្តងមានបីនាក់... ដើម្បីឃ្លាំមើលសកម្មភាពក្រុមហ៊ុន។”

ក្នុងខែមករា ឆ្នាំ២០០៩ ក្រុមហ៊ុនបានផ្តល់សំណងចំនួន ២០,០០០ ដុល្លារអាមេរិក ដល់គ្រួសារដែលនៅសល់ ដើម្បីឱ្យចាកចេញ។ គ្រួសារជាច្រើនបានទទួលយកសំណងនេះភ្លាមៗ។ ចំណែកគ្រួសារឯទៀតដែលមានផ្ទះនិងដីឡូធំ ដែលមានតម្លៃលើសច្រើនដងបានបដិសេធចោល។ ខ្លះទៀតបានដាក់ពាក្យបដិសេធមិនទទួលយកវិញ ប៉ុន្តែការព្យាយាមនេះ ក្នុងការចចារគ្មានឥតប្រយោជន៍។

ក្រោយពេលពិភាក្សាជាមួយគ្រួសាររួច ម្តាយរបស់សុផលបានសម្រេចចិត្តទទួលយកសំណងនោះ។ សុផលបានផ្តល់កំណើតដល់ធីតា ប្រហែលមួយខែមុនពេល និងមានអារម្មណ៍អន្ទះសារចង់បានភាពប្រាកដនិយមសម្រាប់អនាគតគ្រួសារ។ សុផលនិយាយថា ៖ “សម្រាប់តម្លៃ ២០,០០០ ដុល្លារ ខ្ញុំត្រៀមចិត្តលក់ទៅហើយ។ ខ្ញុំបានគិតថា ខ្ញុំនឹងយកលុយទៅទិញផ្ទះមួយសមរម្យ ប៉ុន្តែចាំបាច់ត្រូវតែស្ថិតនៅរាជធានីភ្នំពេញ នៅជិតកន្លែងធ្វើការរបស់ប្តីខ្ញុំ និងជិតសាលារៀនក្មួយៗរបស់ខ្ញុំ។” ពេលម្តាយរបស់នាងទៅជួបតំណាងក្រុមហ៊ុនសេផនអិនជី គេបានប្រាប់គាត់ឱ្យត្រឡប់មកវិញក្រោយពេលឆ្នាំចិន។ សុផលនិយាយថា ៖ “ប៉ុន្តែមុនថ្ងៃចូលឆ្នាំ ពួកគេបានបណ្តេញយើងចេញ។”

## ឧស្ម័នបង្ហូរទឹកភ្នែក និងគ្រាប់កាំភ្លើងជ័រ

ការបណ្តេញចេញដោយបង្ខំនូវប្រជាពលរដ្ឋប្រហែល ៤០០ គ្រួសារ ពីដីក្រហមបានចាប់ផ្តើមនៅម៉ោង២ ព្រឹកថ្ងៃសៅរ៍ ទី២៤ខែមករា ឆ្នាំ២០០៩ ដែលពេលនោះប៉ូលិសបានបិទច្រកផ្លូវដែលនៅជុំវិញភូមិ។ កម្លាំងប្រដាប់អាវុធរាប់រយនាក់ មានប៉ូលិស កងអាវុធហត្ថ ព្រមទាំងកម្មកររុះរើ បានចូលក្នុងភូមិនៅម៉ោង៦ព្រឹក ចំពេលថ្ងៃរះល្មម។ គ្រឿងចក្រឈូសឆាយនិងពង្រាបដី បានបើករុញចូលមក ហើយចាប់ផ្តើមពុះជ្រៀកកំទេចផ្ទះ។

ក្នុងឆាកសម្តែងចុងក្រោយនៃសាមគ្គីភាពនិងការស៊ូ អ្នកភូមិដែលគេបំភ័យនៅជុំវិញភូមិបានរួមដៃគ្នា។ ប៉ុន្តែមិនមានត្រឹមប៉ុណ្ណោះទេ វត្តមានអ្នកកាសែតនិងមន្ត្រីឃ្លាំមើលសិទ្ធិមនុស្ស បានស្រែកបង្អើលប៉ូលិស ដែលបានបាញ់ឧស្ម័នបង្ហូរទឹកភ្នែកនិងគ្រាប់ជ័រកៅស៊ូ ខណៈពេលដែលក្រុមកម្មកររុះរើ បានប្រើញញួរនិងពូថៅវាយកំទេច បំផ្លាញលំនៅឋាន។ ប្រជាពលរដ្ឋខ្លះបាន ចាក់សោរសម្ងំក្នុងផ្ទះ ប៉ុន្តែផ្ទះត្រូវបានកាប់ចិញ្ច្រាំ កំទេចចោលដោយគ្មានគិតគូរដល់សុវត្ថិភាពមនុស្សសោះ។



**“ពួកគេនិយាយថា ពួកគេមិនទទួលខុសត្រូវរាល់របួស ស្នាម និងថាខ្ញុំត្រូវចេញឱ្យឆ្ងាយ។ ខ្ញុំលើកពកូននិងបានដើរចេញទៅ”។**

សុផលនិយាយទាំងទឹកភ្នែករមៀលលើថ្ពាល់ថា ៖ “ខ្ញុំបានសុំអង្វរកុំបំផ្លាញផ្ទះរបស់ខ្ញុំ និងទុកឱ្យខ្ញុំរើឥវ៉ាន់ចេញក្រៅសិន។ ប៉ុន្តែពួកគេមិនព្រម។ ពួកគេនិយាយថា ពួកគេមិនទទួលខុសត្រូវរាល់របួស ស្នាម និងថាខ្ញុំត្រូវចេញឱ្យឆ្ងាយ។ ខ្ញុំលើកពកូននិងបានដើរចេញទៅ។ ខ្ញុំខំដើររកម្តាយ... តែពួកគេបានបាញ់ផ្សែងពុល (ឧស្ម័នបង្ហូរទឹកភ្នែក)។ គេបានបាញ់ពីគ្រប់ទិសទី... គ្មានអ្នកណាម្នាក់អាចដកដង្ហើមបានទេដោយសារតែផ្សែង... បងស្រីរបស់ខ្ញុំម្នាក់ដែលមានជំងឺតេតានុស

ពីខាងឆ្វេង៖ សុផលពធីដា នៅលើគំនរបាក់បែក។ លំនៅឋាន និងមុខរបររកទទួលទាន ត្រូវបានឈូសឆាយ។ ការបំផ្លិចបំផ្លាញតំបន់ដីក្រហម ខែមករា២០០៩។









ស្ថិតនៅលើផ្ទះពេលគ្រឿងចក្របានទាញផ្ទះទំលាក់។ គាត់បានធ្លាក់និងមុតដែកគោលរបួស។" ផ្ទះរបស់គ្រួសារសុផល និងឥវ៉ាន់ទាំងអស់ត្រូវបានគេ "កំទេចទាំងស្រុង" សុផលនិយាយថា ៖ "អ្វីដែលខ្ញុំស្រោចស្រង់យកបាន គឺម៉ាស៊ីនដេរមួយគ្រឿង"។

មកដល់ពេលថ្ងៃត្រង់ ភូមិដីក្រហមលែងមានតទៅទៀតហើយ។

ឡានរបស់ក្រុមហ៊ុនមួយគ្រឿង បានដឹកបញ្ជូនក្រុមគ្រួសារដែលស្រឡាំងកាំង ទៅកាន់ដំណាក់ត្រយឹង មានចម្ងាយប្រហែល២០គីឡូម៉ែត្រ។ សុផលរៀបរាប់ថា ៖ "គេសួរថាពួកខ្ញុំចង់ឡើងឡានអត់ ពួកខ្ញុំគ្មានជម្រើសទេ"។

គេបានទំលាក់គ្រួសារទាំងនោះនៅចិញ្ចើមផ្លូវដីហុយមួយកន្លែង ត្រង់ច្រកចូលទៅកាន់កន្លែងតាំងលំនៅឋាន។ សុផលរំឮកថា ៖ "វាជាថ្ងៃដំបូងដែលខ្ញុំបានមកដល់ដីដំណាក់ត្រយឹង។ ខ្ញុំបានដើរក្រឡឹងជុំវិញ និងមានអារម្មណ៍ថាហាក់ដូចជាត្រូវគេបញ្ជូនខ្លួនពីភូមិរបស់ខ្ញុំ ជាភូមិដែលតែងតែផ្តល់សេចក្តីសុខដល់គ្រួសារខ្ញុំនិងរូបខ្ញុំ... ខ្ញុំពិតជាមានអារម្មណ៍អស់សង្ឃឹម។ ខ្ញុំខឹង... ខ្ញុំស្អប់ពួកគេ"។

## “ចាប់ឆ្នោតផ្សងសំណាង”

គ្រួសារណាដែលក្រុមហ៊ុនសេផនអិនជី ចាត់ទុកថាជា “ម្ចាស់” ផ្ទះនៅភូមិដីក្រហម នឹងទទួលបានផ្ទះល្វែងនៅទីតាំងលំនៅឋានថ្មី តាមរយៈការ“ចាប់ឆ្នោតផ្សងសំណាង”។ ចំណែកអ្នកជួល និងអាជីវករលក់ដូរតាមតូប ត្រូវគេចាក់ចោលនៅក្បែរផ្លូវដី និងត្រូវឃាំងរបងសម្រាប់ខ្លួនឯង។ ជិតមួយឆ្នាំក្រោយមក គ្រួសារទាំងនោះ ត្រូវបានឲ្យចាកចេញទៅទីកន្លែងដ៏សោះកក្រោះដាច់ស្រយាលមួយកន្លែង ស្ថិតនៅក្នុងខេត្តកណ្តាល ប្រហែល៤០គ.ម នៅទិសពាយព្យរាជធានីភ្នំពេញ ដែលឥឡូវពួកគេរស់ក្នុងភាព ទុគ៌ត។

ម្តាយរបស់សុផលបានទៅរស់នៅក្នុងវត្តមួយ។ គាត់នៅតែមិនទាន់ជាសះស្បើយពីអារម្មណ៍ជាប់ដោយស្លាកស្នាមពីការបណ្តេញចេញនៅឡើយទេ។ បងប្អូនប្រុសនិងស្រីរបស់គាត់ បានបែកបាក់គ្នា។ ខ្លះប្តូរទៅរស់នៅតាមខេត្ត ដើម្បីចាប់ផ្តើមសាងជីវិតជាថ្មីម្តងទៀត ហើយខ្លះទៀតបានជួលបន្ទប់នៅក្បែររាជធានីភ្នំពេញ។ សុផលព្រមទាំងប្តី បានចូលទៅនៅក្នុងផ្ទះល្វែងនៅទីតាំងលំនៅឋាន។

ដំណាក់ត្រយឹង តាមការពិត ជាទីកន្លែងតាំងលំនៅឋានដែលគ្រាន់បើជាងគេនៅជុំវិញភ្នំពេញ។ គ្រួសារជាច្រើនផ្សេងទៀត ដែលត្រូវបណ្តេញចេញពីទីក្រុង មិនបានទទួលអ្វីទាល់តែសោះ ក្រៅតែពីដីដ៏ខ្សោះមួយឡូ នៅតំបន់ដាច់ស្រយាលមួយកន្លែង ដោយគ្មានសំណង់ ឬអាគារអ្វីទាំងអស់។ ទោះបីជាផលប្រយោជន៍យ៉ាងនេះក្តី សុផលយល់ថាមានការពិបាករស់នៅទីនោះណាស់។ នៅពេលចាប់ផ្តើមដំបូង សុផលនិយាយថា ៖ “ខ្ញុំត្រូវដើរបេះត្រកួនចាប់ក្តាមតាមវាលស្រែ... ដើម្បីរស់ពីមួយថ្ងៃទៅមួយថ្ងៃ”។ ពួកគេមិនអាចលៃលករកប្រាក់សម្រាប់តភ្ជាប់បណ្តាញអគ្គីសនី ឬបង់ថ្លៃទឹកបាន។ នាងពន្យល់ថា ៖ “សព្វថ្ងៃ ខ្ញុំអុជចង្កៀងប្រេងកាត ហើយ... ទៅដងទឹកពីស្រះត្រពាំងសម្រាប់ចំអិនអាហារ”។




សុផលនិយាយថា ទោះបីគេផ្តល់ឲ្យគ្រួសារនូវប្រាក់កម្ចី ១,០០០ ដុល្លារក៏ដោយ “សម្រាប់គ្រួសារខ្ញុំ ខ្ញុំបាត់បង់ការងារ [ដូច្នេះ] ពួកខ្ញុំមិនហ៊ានខ្ចីទេ... យើងខ្លាចថាយើងគ្មានលទ្ធភាពសងវិញ... ចំណែកអ្នកផ្សេង ក្រីក្រនិងផទនាសុខចិត្តទទួលយក។ អ្នកខ្លះខ្ចី សម្រាប់តភ្ជាប់ភ្លើងអគ្គីសនី ទឹក...ជាដើម។”

បញ្ហាកាន់តែអាក្រក់នោះគឺ ធីតាដែលពេលនោះមានអាយុទើបតែពីរខែ បានចាប់ផ្តើមមានជំងឺផ្លូវដង្ហើម ក្រោយពេលបណ្តេញចេញ។ តាមការធ្វើរោគវិនិច្ឆ័យ ធីតាមានជំងឺរលាកសួតធ្ងន់ធ្ងរ។ សុផលនិយាយថា ៖ “ខ្ញុំបានបញ្ជូនកូនទៅព្យាបាល ពីព្រោះវាស្គមទៅៗនៅសល់តែស្បែកនិងឆ្អឹង។ គ្មានអ្នកណាម្នាក់គិតថានាងនៅរស់នោះទេ... ខ្ញុំបានខ្ចីលុយពីអ្នកស្រុកប្តីរបស់ខ្ញុំ ដើម្បីបញ្ជូនកូនទៅមន្ទីរពេទ្យ ដើម្បីព្យាបាលកូនស្រីរបស់ខ្ញុំ។ មួយឆ្នាំក្រោយមក កូនបានជាសះស្បើយ។ ប៉ុន្តែខ្ញុំបានបាត់បង់អ្វីៗទាំងអស់”។

*រដ្ឋ សុផល បានផ្តល់បទសម្ភាសន៍ជាមួយអង្គការលើកលែងទោសអន្តរជាតិនៅថ្ងៃទី២៨-២៩ ខែមេសា ឆ្នាំ២០១១។*



ពីខាងឆ្វេង៖ សុផល និងក្រួសារ។ សុផល ធីដា និងប្ដី សុខា
នៅចំពីមុខស្លាកសញ្ញា “ផ្ទះលក់” ដំណាក់ត្រយឹង ភ្នំពេញ មិថុនា ២០១១។



> វាជាថ្ងៃដំបូងដែលខ្ញុំបានមកដល់ដីដំណាក់ត្រយឹង។
> ខ្ញុំបានដើរក្រឡឹងជុំវិញ ខ្ញុំពិតជាមានអារម្មណ៍អស់សង្ឃឹម។
> ខ្ញុំខឹង... ខ្ញុំស្អប់ពួកគេ។

# ហុង

“

ចំពោះរូបខ្ញុំផ្ទាល់
ព្រៃឡង់ជាជម្រករបស់ជនជាតិដើមភាគតិច។
វាប្រៀបដូចជាផ្ទះ ដែលយើងរស់នៅ
ហើយមានសេរីភាពពេញលេញ។
ប្រសិនបើព្រៃឡង់ បាត់បង់ទៅនោះ
យើងមិនអាចរស់នៅបានទេ។

”

ផ្ទូក ហុង នៅក្នុងព្រៃឡង់ ខេត្តព្រះវិហារ
មិថុនា ២០១១





ព្រៃឡង់មានទីតាំងស្ថិតនៅប៉ែកខាងជើងប្រទេសកម្ពុជា ជាតំបន់តភ្ជាប់ដីបម្រើដ៏ធំល្វឹងល្វើយ ដែលជនជាតិដើមភាគតិចនៅក្នុងប្រទេសនេះ ប្រើប្រាស់ដ៏ច្រើនលើសលុប។ ធនធានព្រៃឈើរបស់ព្រៃឡង់ បានទ្រទ្រង់ជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋប្រមាណ ២០០,០០០នាក់ ដែលកំពុងរស់នៅក្នុងភូមិចំនួន ៣៣៩ ភូមិ នៅជុំវិញព្រៃឡង់។ ប្រជាពលរដ្ឋទាំងនោះ ភាគច្រើនជាជនជាតិគួយ។ កន្លងទៅថ្មីៗនេះ ក្រុមហ៊ុនបានទទួលសម្បទានដីសេដ្ឋកិច្ច សម្រាប់ធ្វើចំការដំណាំកសិឧស្សាហកម្ម និងអាជីវកម្មរ៉ែនៅលើផ្ទៃដីព្រៃឡង់ដ៏ធំនេះ។ ក្នុងការរំលោភបំពានលើសន្ធិសញ្ញាសិទ្ធិមនុស្សផ្សេងៗ និងសេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិរបស់ជនជាតិដើមភាគតិច អាជ្ញាធរខកខានមិនបានទទួលការយល់ព្រមជាមុនពីសហគមន៍មូលដ្ឋាន ដោយបានបំផ្លិចបំផ្លាញព្រៃជាប្រពៃណីរបស់ពួកគាត់ និងបានដាក់កម្រិតលើសិទ្ធិចេញចូលដីដូនតារបស់ពួកគាត់ផង។ សកម្មភាពរបស់ក្រុមហ៊ុន កំពុងគំរាមកំហែងសហគមន៍ជនជាតិគួយ និងលទ្ធភាពរបស់ពួកគាត់ ក្នុងការប្រើប្រាស់ ការចាត់ចែង គ្រប់គ្រងដី និងធនធានធម្មជាតិជាប្រពៃណីរបស់ខ្លួន។





ហុងក្នុងវ័យ ៣៨ ឆ្នាំ ជាស្ត្រីជនជាតិដើមភាគតិចគួយម្នាក់ដ៏ក្លៀវក្លា និងជាម្ដាយដែលមានកូនប្រាំនាក់ ដើរឆ្លងកាត់ព្រៃឈើ និងរុក្ខជាតិក្នុងព្រៃឡង់។ ពេលខ្លះគាត់ឈប់មួយកន្លែង ហើយចង្អុលបង្ហាញរុក្ខជាតិ ដែលមានប្រយោជន៍ជាថ្នាំព្យាបាលជំងឺរបស់ជនជាតិគាត់។ គាត់បានពន្យល់ថា ជីតារបស់គាត់ បានបង្រៀនគាត់ឲ្យស្គាល់រុក្ខជាតិព្យាបាល ពេលដែលគាត់កំពុងតែចម្រើនវ័យ។ គាត់និយាយថា ៖ “រុក្ខជាតិទាំងនោះ ជាថ្នាំស័ក្ដិសិទ្ធ។ ថ្នាំខ្លះអាចព្យាបាលអ្នកជំងឺឆាប់ជាជាងថ្នាំនៅមន្ទីរពេទ្យ”។

ហុងនិងប្រជាពលរដ្ឋរស់នៅក្នុងភូមិនៅជុំវិញព្រៃឡង់ ចាត់ទុកព្រៃឈើជាប្រភពដ៏សំខាន់នៃតម្រូវការជាចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ រួមមានចំណីអាហារ ទឹក និងឱសថ។ ភាគច្រើន ប្រជាពលរដ្ឋទាំងនោះជាជនជាតិដើមគួយ ដែលជាជនជាតិដើមច្រើនជាងគេបំផុត ក្នុងចំណោមជនជាតិដើមភាគតិចប្រហែល ២៥ ជនជាតិក្នុងប្រទេសកម្ពុជា។ ហុងបានពន្យល់ថា ៖ “ចំពោះរូបខ្ញុំផ្ទាល់ ព្រៃឡង់ជាជម្រករបស់ជនជាតិដើមភាគតិច។ វាប្រៀបដូចជាផ្ទះ ដែលយើងរស់នៅ ហើយមានសេរីភាពពេញលេញ និងភាពសុខដុមរមនា... វាជាផ្ទះពោរពេញទៅដោយទ្រព្យសម្បត្តិ។” ជនជាតិគួយដូចគ្នានឹងដូនតារបស់ពួកគេដែរ ចាត់ទុកខ្លួនឯងថាជាអ្នកថែរក្សាព្រៃឈើ។ ប្រពៃណីនិងជំនឿអរូបិយរបស់ពួកគាត់ បានដក់ជាប់យ៉ាងជ្រាលជ្រៅជាមួយបរិស្ថានពួកគាត់ ហើយផ្សារភ្ជាប់ជាមួយព្រៃឈើ។ ក្នុងភាសាជនជាតិគួយ ព្រៃឡង់មានន័យថា “ព្រៃយើង” ។

ព្រៃឡង់លាតសន្ធឹងប្រសព្វគ្នាខេត្តចំនួនបួន នៅប៉ែកខាងជើងប្រទេសកម្ពុជា។ ចំណែកឯព្រំប្រទល់ពិតប្រាកដ នៅមិនទាន់បានកំណត់នៅឡើយទេ – ដោយសារមិនទាន់ទទួលស្គាល់ជាផ្លូវការ ថាជាតំបន់ព្រៃការពារ – ផ្ទៃដីរបស់ព្រៃឡង់ ដែលលាតសន្ធឹងចន្លោះដងទន្លេមេគង្គ និងទន្លេស្ទឹងសែន មានប្រហែល ៣,៦០០ គីឡូម៉ែត្រក្រឡាជាព្រៃឈើ រួមទាំងព្រៃឈើបុរាណចំ កណ្ដាលព្រៃទំហំ ៨០,០០០ ហិកតា។ វាសម្បូណ៌ទៅដោយជីវៈចម្រុះ និងដើមឈើដ៏កម្រនិងប្រភេទសត្វព្រៃដែលកំពុងរងគ្រោះ។

ពីខាងលើ៖ ការចោះជ័រទឹក។ ហុង និងប្រជាពលរដ្ឋ ពឹងជ័រទឹកក្នុងព្រៃឡង់សម្រាប់ជាចំហេះ។ ផ្ទៃដីព្រៃឡង់ត្រូវបានឈូសឆាយ រុករករ៉ែ និងគម្រោងផ្សេងៗ ខែមិថុនា ២០១១





ចាប់តាំងពីទសវត្សរ៍១៩៩០ ព្រៃឡង់ទទួលរងការគំរាមកំហែងខ្លាំងឡើងៗពីក្រុមហ៊ុនកាប់ឈើ ហើយថ្មីៗកន្លងទៅនេះ មានអាជីវកម្មរ៉ែដ៏មានសក្តានុពលនៃតំបន់ដែលសម្បូណ៌ធនធានធម្មជាតិ។ កំណើនវត្តមានរបស់ក្រុមហ៊ុន និងការគ្រប់គ្រងមកលើផ្នែកដ៏ធំនៃដីព្រៃ បានបណ្តាលឲ្យជនជាតិគួយធ្វើការតស៊ូថែរក្សាដីធ្លី និងព្រៃឈើឲ្យមាននិរន្តរភាព ទៅតាមទំនៀមទំលាប់របស់ពួកគេ។ ហុងបាននិយាយថា ៖ "ពួកខ្ញុំពឹងលើព្រៃឡង់សម្រាប់ជីវភាពរស់នៅទាំងស្រុង"។ ប្រសិនបើព្រៃឡង់បាត់បង់ទៅនោះ យើងមិនអាចរស់នៅបានទេ"។

ហុងបានធំដឹងក្តីនៅជាប់ជើងព្រៃឡង់។ នាងនិយាយថាសហគមន៍របស់គាត់អាចស្វែងរកបានអ្វីទាំងអស់ពីព្រៃតាមតម្រូវការ។ គាត់ពន្យល់ដូច្នេះថា ៖ "យើងគ្រាន់តែដើរចូលព្រៃទាំងអស់គ្នា ដែលគ្មានដែនកំណត់។ ប្រសិនយើងចង់បានបន្លែមកហូប យើងចូលព្រៃ... នៅពេលខ្លះ ឆ្កែពួកខ្ញុំដេញចាប់បានជ្រូកព្រៃសម្រាប់ធ្វើម្ហូបនៅផ្ទះ។ ពួកខ្ញុំទៅស្រះត្រពាំងចាប់ត្រីផងដែរ។"

គេអាចរកឃើញត្រពាំងទឹក ដែលជាចរន្តទឹកហូរពីធម្មជាតិ នៅពាសពេញក្នុងព្រៃឡង់ ហើយវាជាប្រភពទឹកយ៉ាងសំខាន់។ ហុងពន្យល់ថា ឥន្ធនៈសម្រាប់ប្រើប្រាស់ក្នុងគ្រួសារក៏បានប្រមូលមកពីព្រៃផងដែរ។ "ព្រៃឡង់ ដែលខ្ញុំរស់នៅ ខ្ញុំប្រើចង្កៀងដុតដោយចន្លុះជ័រទឹក។ ខ្ញុំចូលព្រៃទៅដងជ័រទឹក និងកាត់ស្លឹកព្រាល ហើយជ្រលក់ផ្អាប់នឹងជ័រទឹក ធ្វើចន្លុះសម្រាប់ដុត។ ពេលខ្ញុំចំអិនម្ហូប ខ្ញុំប្រើស្លឹកជ្រលក់ក្នុងជ័រសម្រាប់ដុត និងបន្ថែមឧសសម្រាប់ដាំបាយនិងធ្វើម្ហូប"។

ការចោះយកជ័រទឹក មិនត្រឹមតែជាប្រភពថាមពលសម្រាប់អ្នកស្រុកប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាប្រភពដ៏សំខាន់ និងមានផលចំណេញខ្ពស់ សម្រាប់ជីវភាពប្រជាពលរដ្ឋរាប់សែននាក់។ ការចោះប្រហោងគល់ឈើ និងការដុតភ្លើង មិនបង្កអន្តរាយដល់ដើមឈើទេ។ សហគមន៍របស់ហុង ក៏នាំគ្នាដើរបោចផ្តៅ វល្លិជាតិ និងអនុផលព្រៃឈើផ្សេងៗសម្រាប់លក់។ គាត់និយាយថាប្រាក់ចំណូលបន្តិចបន្តួច គឺប្រើសម្រាប់ទិញអំបិល គ្រឿងទេសនិងសម្ភារប្រើក្នុងផ្ទះ ចំណែកធនធានស្ទើរតែទាំងអស់

ពីខាងលើឆ្វេងដៃ៖ ផូក ហុង និងប្ដី យ៉ាន់ ទី អង្គុយលើកាំជណ្ដើរផ្ទះ របស់គាត់ ក្នុងភូមិភ្នឹករលឹក ស្រុកជ័យសែន ខេត្តព្រះវិហារ ខែមិថុនា ២០១១។ ហុង និងគ្រួសារ។ ហុងដឹកនាំការតវ៉ា ក្នុងរាជធានីភ្នំពេញ កម្ពុជា ២៥ ឧសភា ២០១១។









គេអាចរកបាន ក្នុងព្រៃឬអាចដាំដុះបាននៅលើដីដ៏មានជីជាតិ។ ធនធានទាំងនេះត្រូវបានចែកចាយក្នុងសហគមន៍ ឬសម្រាប់ដោះដូរនឹងទំនិញផ្សេងៗទៀត។ “យើងរស់នៅក្នុងតំបន់នេះ ទៅតាមទំនៀមទំលាប់ប្រពៃណីរបស់យើង ដែលចេះជួយគ្នាទៅវិញទៅមក។ ប្រសិនយើងចាប់ត្រី ឬបានសាច់សត្វ យើងចែករំលែកគ្នា។ យើងមិនលក់ដូរច្រើនទេ។”

ជនជាតិគួយប្រើប្រាស់ប្រព័ន្ធធ្វើកសិកម្មពនេចរផ្លាស់គ្នា ទៅតាមមគ្គុទ្ទេសក៏ជំនឿរបស់ខ្លួនលើព្រលឹងអារក្សអ្នកតារបស់ពួកគេ។ ហុងពន្យល់ថា ៖ “ក្នុងខែវិច្ឆិកា យើងបន់ស្រន់ព្រលឹងអារក្សអ្នកតា ដែលពិធីនេះហៅថាបញ្ជាន់អារក្ស។ ធ្វើដូច្នេះ ព្រលឹងអ្នកតាអាចប្រាប់ថាតើយើងត្រូវចូលទៅព្រៃណា សម្រាប់ឆ្នាំនោះ។ យើងត្រូវធ្វើតាមសម្ដីរបស់គាត់… នៅឆ្នាំក្រោយ យើងចូលព្រៃផ្សេងទៀត ដោយបន់ស្រន់សុំ អ្នកតាដដែលនោះទៀត។ បីឆ្នាំ[ក្រោយមក]ទៀត យើងវិលត្រឡប់មកព្រៃមុនដំបូង។ នោះជាប្រពៃណីរបស់យើង”។

ដោយព្រៃឈើបំពេញតួនាទីស្នូល សម្រាប់ទ្រទ្រង់ជីវភាពរស់នៅរបស់សហគមន៍ ជំនឿ និងតម្រូវការប្រចាំថ្ងៃ ហុងបានចាត់ទុកថា ការថែរក្សាព្រៃឈើសម្រាប់កូននិងចៅរបស់គាត់ គឺជាកិច្ចការដ៏សំខាន់បំផុត។ “ខ្ញុំចង់ថែរក្សាព្រៃឡង់សម្រាប់ក្មេងជំនាន់ក្រោយ… ដើម្បីពួកគេបានសេចក្ដីសុខដូចខ្ញុំសព្វថ្ងៃ។”

## ក្រុមហ៊ុនចូលមក

អ្នកនយោបាយ ពាណិជ្ជករ និងពួកទាហានដែលមានអំណាច មានចំណាប់អារម្មណ៍នឹងធនធានក្នុងព្រៃបានកេងប្រវ័ញ្ចធនធានធម្មជាតិរបស់ព្រៃឡង់នេះ។ ទោះបីមានការស្រែករិះគន់ពីសហគមន៍មូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលក៏ដោយ ពួកគេនៅបន្តទាត់ចោលតួនាទីដ៏សំខាន់របស់ព្រៃនេះ ដែលផ្ដល់ជាប្រភពសម្រាប់ទ្រទ្រង់ជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋខ្មែរចំនួន ២០០,០០០ នាក់ និងជាអត្តសញ្ញាណខាងជំនឿនិងវប្បធម៌របស់ជនជាតិគួយ។ លើសពីនេះទៀត មានភស្តុតាងកាន់តែច្រើន ដែលបង្ហាញអំពីគុណតម្លៃខាងបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីរបស់ព្រៃឡង់ ដូចជាទីជម្រាលដ៏សំខាន់ ទាំងក្នុងការបង្ការទឹកជំនន់នៅរដូវវស្សា និងការបញ្ចេញទឹកទៅវិញនៅរដូវប្រាំង។

ក្នុងឆ្នាំ២០០២ ដោយទទួលរងកៀបសង្កត់ខ្លាំងពីសហគមន៍អន្តរជាតិ រាជរដ្ឋាភិបាលបានបញ្ឈប់ការចេញអាជ្ញាប័ណ្ណថ្មី ដើម្បីកាប់ព្រៃឈើនៅទូទៅប្រទេសកម្ពុជា។ ព្រៃសម្បទានកាប់ឈើបានបញ្ឈប់សកម្មភាព តែទោះបីយ៉ាងណា ការកាប់ឈើខុសច្បាប់ចេះតែបន្ត ទោះការកាប់បំផ្លិចបំផ្លាញព្រៃឈើ បានថយក៏ដោយ។ ទោះជាយ៉ាងណាក្ដី ភ្លាមៗនោះអ្នកកាប់ឈើដ៏មានអំណាច បានរិះរកវិធីថ្មីដោយយកច្បាប់មកបំបិទបំបាំងសកម្មភាពរបស់ខ្លួន។

ការគ្រប់គ្រងដីដ៏ធំក្នុងតំបន់ព្រៃឡង់ គឺធ្វើឡើងតាមរយៈការទទួលបានសម្បទានដីសេដ្ឋកិច្ច សម្រាប់ធ្វើចំការដំណាំកសិឧស្សាហកម្ម ដូចជាដំណាំកៅស៊ូ សម្បទានរ៉ែមានដូចជាដែក ទង់ដែង មាស និងធនធានដទៃទៀត។ អ្នកសង្កេតការណ៍មានប្រសាសន៍ថា ការផ្ដល់សម្បទានទាំងនេះ គឺជាការត្រួសត្រាយផ្លូវ ដែលនាំឲ្យមានការបំផ្លិចបំផ្លាញគំរាមកំហែងព្រៃឡង់។ ការបង្វែរព្រៃឈើឲ្យទៅជាចំការដាំដំណាំ ពាក់ព័ន្ធនឹងការកាប់ឈើដ៏មានតម្លៃដ៏ច្រើនលើសលុប។ បន្ទាប់មក គេបានឈូសឆាយដីព្រៃនោះ ធ្វើឲ្យផ្ទៃដីព្រៃប្រែប្រួល ដែលជាហេតុធ្វើឲ្យព្រៃឈើមិនអាចដុះឡើងវិញបាន។

ព័ត៌មានជាក់លាក់អំពីកិច្ចសន្យាសម្បទានដីដ៏អាថ៌កំបាំង ដែលផ្ដល់ប្រយោជន៍ទៅក្រុមហ៊ុនឯកជន គឺ មិនងាយរកទេ ឬពិបាកនឹងផ្ទៀងផ្ទាត់ព័ត៌មាននោះណាស់ គឺជារឿងលំបាកនឹងរក ព្រោះតែកិច្ចសន្យាទាំងនោះ ត្រូវបានធ្វើឡើងដោយខ្វះតម្លាភាព។ នៅឆ្នាំ២០១០ យ៉ាងហោចណាស់ មានក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចនិងក្រុមហ៊ុនរករ៉ែចំនួន២៧ បានទទួលអាជ្ញាប័ណ្ណ។ គេដឹងថារដ្ឋាភិបាល បានធ្វើសម្បទានឲ្យក្រុមហ៊ុនទាំងនោះ នៅក្នុងតំបន់ដ៏ច្រើនលើសលុបនៃព្រៃឡង់។ ក្នុងករណីខ្លះ ក្រុមហ៊ុនសម្បទានដីទាំងនេះ ទទួលបានកិច្ចការពារពីអង្គភាពយោធា ឬប៉ូលិស ដែលស៊ីឈ្នួលឯកជន។ កងកម្លាំងទាំងនោះ បានរារាំងប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន មិនឲ្យចូលក្នុងតំបន់សម្បទានដី រួមទាំងធនធានព្រៃ ដែលពួកគាត់ធ្លាប់រកស៊ីពឹងអាស្រ័យផង។



ក្រុមហ៊ុនអាជីវកម្មរ៉ែមួយរបស់កូរ៉េ ឈ្មោះខេននើថិករីសស៌ ទទួលបានសម្បទានក្នុងឆ្នាំ២០០៧ បានទទួលអាជ្ញាប័ណ្ណរុករករ៉ែនៅជុំវិញភូមិរបស់ហុង ឈ្មោះភូមិភ្នំករលើកនិងប៉ែកខាងជើងព្រៃឡង់ រួមទាំងដីស័ក្តិសិទ្ធិផងដែរ នេះបើតាមប្រសាសន៍ហុង។ ហុងនិយាយថា គាត់មិនសូវដឹងអំពីប្រតិបត្តិការរុករករ៉ែ អំពីក្រុមហ៊ុន ឬអំពីព្រំប្រទល់សម្បទានដីទេ។ គាត់ក៏មិនដឹងអំពីផែនការអនាគតរបស់ក្រុមហ៊ុន និងមិនដឹងថាសកម្មភាពទាំងនោះប៉ះពាល់លើភូមិរបស់គាត់ ឬប៉ះពាល់ការចេញចូលព្រៃ និងជីវភាពរស់នៅរបស់សហគមន៍យ៉ាងណានោះទេ។ គាត់និយាយថា ប្រជាពលរដ្ឋដែលរស់ក្នុងភូមិ មិនត្រូវបាន ពិគ្រោះយោបល់ទេ។ “គ្រប់ពេលដែលក្រុមហ៊ុនចូលមកវិនិយោគ គេមិនដែលស្វែងយល់អំពីសហគមន៍មូលដ្ឋាន យល់ដឹងអំពីប្រជាពលរដ្ឋ ឬពិភាក្សាជាមួយពួកគាត់ទេ។ គេនិយាយជាមួយប្រធានភូមិ ឬអាជ្ញាធរថ្នាក់ឃុំតែប៉ុណ្ណោះ”។

ហុងភ័យខ្លាចថា វត្តមានរបស់ក្រុមរុករករ៉ែ នឹងបង្កការគំរាមកំហែងធ្ងន់ធ្ងរលើសមត្ថភាពសហគមន៍របស់គាត់ ក្នុងបន្តការប្រើប្រាស់ដីធ្លីនិងព្រៃតាមប្រពៃណី។ គាត់និយាយ ថាក្រុមហ៊ុនខ្លះ “មានទាហានយាមទាំងយប់ទាំងថ្ងៃ... ប្រសិនអ្នកស្រុកក្នុងសហគមន៍ចូលក្នុងដីក្រុមហ៊ុនរ៉ែ នឹងមានបញ្ហាហើយ។ គេគំរាមកំហែងពួកខ្ញុំ។ គេមានកាំភ្លើង... អ្នកស្រុកខ្លះបានសួរថាហេតុអ្វីពួកគាត់មិនអាចចូលបាន ត្បិតអីដីនេះជារបស់សហគមន៍សោះនោះ។ ពួកគេនិយាយថា ដីនេះជារបស់ក្រុមហ៊ុន ពីព្រោះ រដ្ឋាភិបាលបានបោះត្រាឲ្យដីពួកគេទៅក្រុមហ៊ុនរួចទៅហើយ”។

គាត់ក៏ព្រួយបារម្ភដែរថា ទៅថ្ងៃក្រោយ សហគមន៍របស់គាត់និងអ្នកផ្សេងៗ នឹងត្រូវចាកចេញដោយគ្មានជម្រើស ឬថាក្រុមហ៊ុននឹងបណ្តេញពួកគាត់ចេញ ឬថាពួកគាត់នឹងបាត់បង់សិទ្ធិចេញចូលប្រមូលផលធនធាននៅក្នុងតំបន់សម្រាប់ជីវភាពរស់នៅ។ “ពេលខ្លះខ្ញុំគិតថា ប្រាកដជាត្រូវបណ្តេញចេញ។ ប្រសិនគេនៅតែចូលជ្រៅទៅៗ នឹងមានការបណ្តេញចេញដូចនៅខេត្តផ្សេងៗជាមិនខាន”។

ហុងបានដឹងជាលើកដំបូងក្នុងឆ្នាំ២០០២ថា ផ្នែកខ្លះរបស់ព្រៃឡង់ ដែលនៅជិតភូមិរបស់គាត់ បានរងការបំផ្លិចបំផ្លាញយ៉ាងលឿន។ គាត់ពន្យល់ថា ៖ “ដំបូង ខ្ញុំបានឃើញតំណាងក្រុមហ៊ុនម្នាក់ មកនិយាយជាមួយប្រធានភូមិ ប៉ុន្តែខ្ញុំមិនបានដឹងថាមានកិច្ចព្រមព្រៀងគ្នាទេ។ កាលពីមុន ប្រជាពលរដ្ឋមិនសូវដឹងរឿងច្រើន។ អ្នកស្រុកបានឮថា គេនឹងផ្តល់ការងារឲ្យពួកគាត់ធ្វើជាកម្មករ ពេលក្រុមហ៊ុនចូល... កន្លះឆ្នាំក្រោយមក ពួកគាត់បានឃើញក្រុមហ៊ុនកាប់ដើមចំបក់ និងដើមជ័រច្បោះដែលជាកម្មសិទ្ធិរបស់ប្រជាពលរដ្ឋ... ក្រុមហ៊ុនមិនអនុញ្ញាតឲ្យប្រជាពលរដ្ឋចូលក្នុងព្រៃ ដើម្បីប្រមូលអនុផលព្រៃឈើទេ។ ពេលនោះទើបពួកគាត់បានដឹងថា ពួកគាត់បានបាត់បង់ការងារ មុខរបរ និងអនុផលព្រៃឈើ និងពួកគេ [មានមន្ទិលសង្ស័យ]ថាតើគេថែរក្សាព្រៃរបស់គាត់តាមរបៀបនោះឬ។”

ហុងដឹកនាំការតវ៉ា ក្នុងរាជធានីភ្នំពេញ កម្ពុជា នៅថ្ងៃទី២៥ ឧសភា ២០១១។

## “វាជាសិទ្ធិរបស់ខ្ញុំ”

ហុង បានរៀបរាប់ថា អង្គការក្រៅរដ្ឋាភិបាលខ្មែរមួយ
“បានមកបណ្តុះបណ្តាលនិងជំរុញលើកទឹកចិត្តអ្នកស្រុកអំពីយុទ្ធសាស្រ្តយកឈ្នះ។
ពួកគេបានបង្រៀនអំពីសកម្មភាពអហិង្សា និងវិធីស្វែងរកការគាំទ្រ។”
ហុងជឿងឆ្ងល់ចង់ដឹងណាស់។ គាត់មិនមានការអប់រំទេកាលនៅកុមារី
ដោយសារកង្វះខាតសាលាអប់រំប្រកបដោយគុណភាពនៅក្បែរនោះ
និងគ្រួសារគាត់គិតថាទុកគាត់គឺជាអ្នកថែទាំម្តាយឈឺ និងជួយរកម្ហូបអាហារ។

គាត់និយាយរំឭកថា ៖ “សម្រាប់រូបខ្ញុំ ក្នុងឆ្នាំ២០០២
ខ្ញុំមិនយល់ថា សហគមន៍មានន័យដូចម្តេចទេ។ កាលនោះ
ខ្ញុំគិតថាខ្លួនឯងល្ងង់ខ្លាំងណាស់”។
នៅពេលអង្គការបានមកដល់ គាត់និយាយដូច្នេះថា ៖
“ខ្ញុំមានការជំរុញទឹកចិត្តតែម្តង”។ ហុងបាននិយាយប្រាប់គ្រូបណ្តុះបណ្តាលអង្គការថា
មានទាហានម្នាក់ បានបដិសេធមិនឲ្យគាត់លក់ជ័រទឹក។
“ខ្ញុំបាននិយាយថាវាជាសិទ្ធិរបស់ខ្ញុំ ចង់លក់ឲ្យអ្នកណាដែលខ្ញុំចង់។
ខ្ញុំសឹងតែមិនជឿថាខ្ញុំហ៊ាននិយាយថា “វាជាសិទ្ធិរបស់ខ្ញុំ”។ ពីមុន
ខ្ញុំមិនដែលរៀនសូត្រអំពីសិទ្ធិអ្វីទេ។”

សកម្មភាពដំបូងដែលហុងបានធ្វើដើម្បីការពារព្រៃឡង់ គឺផ្តិតស្នាមមេដៃលើញត្តិបណ្តឹងមួយ
និងលើកទឹកចិត្តអ្នកឯទៀតឲ្យធ្វើតាម។ គាត់បានចូលរួមក្នុងក្រុមសកម្មជនសហគមន៍ចំនួន
២៤០នាក់ ដែលបានធ្វើដំណើរមកភ្នំពេញ ដើម្បីលើកឡើងអំពីកង្វល់ពួកគេ
អំពីសកម្មភាពកាប់ឈើរបស់ក្រុមហ៊ុន ទៅរាជរដ្ឋាភិបាល
និងបានដាក់ញត្តិថ្វាយព្រះមហាក្សត្រ។

ចាប់ពីពេលនោះមក ហុងបានក្លាយជាសកម្មជនដឹកនាំរបស់សហគមន៍។
គាត់មិនសូវបាននៅជួបជុំក្រុមគ្រួសារ ត្បិតអីគាត់រវល់ខ្លាំង។
“ការងារការពារព្រៃឡង់… គឺត្រូវធ្វើដំណើរពីភូមិមួយ
ទៅភូមិមួយទៀត” ត្រូវចាត់ចែងញត្តិ ការតវ៉ា
និងចូលរួមល្បាតព្រៃសហគមន៍។

គាត់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាច្រើនស្តីពីសិទ្ធិមនុស្ស ច្បាប់ប្រទេសកម្ពុជា
និងវិធីស្វែងរកការគាំទ្រ។ វាជាលើកដំបូងក្នុងឆាកជីវិតរបស់គាត់
ដែលបានចូលរួមក្នុងថ្នាក់រៀនសូត្រ។ សព្វថ្ងៃ ហុងបង្រៀនអ្នកដទៃ។
“ខ្ញុំបាន បង្រៀនសហគមន៍ជាច្រើន។ ពេលខ្លះខ្ញុំបង្រៀនក្នុងវត្ត
ខ្លះទៀតតាមសាលារៀន
និងខ្លះទៀតនៅតាមផ្ទះពេលស្រ្តីនិយាយគ្នាលេងពីនេះពីនោះ”។

ឱកាសទាំងនេះបានធ្វើឲ្យជីវិតហុង ដែលជាស្រ្តីជនជាតិគួយមួយរូប
មិនធ្លាប់រៀនអក្សរជាផ្លូវការ ទទួលបាននូវជីវិតផ្លាស់ប្តូរ។ គាត់ពន្យល់ថា ៖
“ជនជាតិគួយភាគច្រើន មិនចេះអាននិងសរសេរអក្សរ ទេ។ ធម្មតា
នៅតាមជនបទ ប្រសិនបើយើងមិនចេះអក្សរ គេនឹងមើលងាយ។
ដូចជាខ្ញុំអញ្ចឹង អ្នកណាក៏មើលងាយខ្ញុំដែរ… ធ្វើជាក្មេងជនជាតិដើមភាគតិច
គឺពិបាកដោយសារតែមិនចេះអក្សរ។ ពេលយើងទៅផ្សារ គេនិយាយថា “ជនជាតិគួយ
ជាជនជាតិល្ងង់ខ្លៅ សូម្បីតែអក្សរក៏មិនចេះអានដែរ”។ ខ្ញុំឈឺចាប់ណាស់ ខ្ញុំព្រួយចិត្ត
ពេលកូនខ្ញុំមិនចេះអក្សរ។”

ហុងនិយាយថា ៖ “យើងត្រូវតែរៀនសូត្រ កុំឲ្យគេមើលងាយយើង
រំលោភសិទ្ធិរបស់យើង។ ខ្ញុំបានរៀនបណ្តើរ ធ្វើការបណ្តើរ”។
គាត់មើលឃើញការអប់រំជារឿងសំខាន់ ដើម្បីការពារព្រៃឡង់ ក្នុងរយៈពេលយូរអង្វែង។
“ខ្ញុំចង់ឲ្យកូនរៀនអំពីច្បាប់ការពារព្រៃឈើ… ពេលដែលយើងចេះដឹងច្បាប់
គ្មានអ្នកណាអាចរំលោភ លើសិទ្ធិយើងបានទេ។”

## “មេដឹកនាំជាស្ត្រី”

ក្នុងនាមជាស្ត្រីមួយរូប ហុងបានជំនះលើមតិយល់ឃើញទូទៅ នៅក្នុងសហគមន៍របស់ខ្លួន អំពីតួនាទី និងសមត្ថភាពស្ត្រី។ គាត់ពន្យល់ថា ៖ “ក្នុងសង្គម ស្ត្រីភេទមិនទាន់ស្មើភាពនឹងបុរសនៅឡើយ ដោយសារស្ត្រីខ្លះឲ្យតម្លៃខ្លួនឯងទាប ដោយបានគិតថា ពួកគាត់មិនអាចប្រៀបផ្ទឹមជាមួយបុរសបាន។ ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំគិតថាខ្ញុំអាច។” គាត់និយាយដូច្នេះទាំងញញឹម។

ហុងនិយាយថាកាលពីមុន “ខ្ញុំមានអារម្មណ៍ថាខ្លួនគ្មានសមត្ថភាពធ្វើការអ្វីទេ... តាំងពីបានចាប់ផ្តើមធ្វើការងារសហគមន៍ ខ្ញុំបានប្តេជ្ញាថានឹងព្យាយាមរៀនសូត្រឲ្យអស់សមត្ថភាព ពីព្រោះខ្ញុំបានគិតថា យ៉ាងហោចណាស់ការដឹងរឿង ក៏អាចបញ្ឈប់បុរសកុំឲ្យមើលងាយខ្ញុំដែរ... ឥឡូវ ខ្ញុំបាននិងកំពុងធ្វើការបម្រើភូមិខ្ញុំ អស់ពីរឆ្នាំហើយ។ ខ្ញុំជាអនុប្រធានភូមិ។ ខ្ញុំដឹងខ្លួនថា “អស្ចារ្យមែន ខ្ញុំអាចធ្វើការងារខ្លះបានមែន ទោះបីខ្ញុំជាស្ត្រីភេទ។ ពេលនេះ ខ្ញុំមានមោទនភាពខ្លួនឯង... ខ្ញុំបានធ្វើឲ្យលទ្ធផលកើតឡើង ហើយខ្ញុំជាអ្នកដឹកនាំជាស្ត្រី។”

## “ខ្ញុំចង់រក្សាទុកព្រៃឈើ ដើម្បីរកស៊ីចិញ្ចឹមជីវិតតាមប្រពៃណីបន្តិចម្តងៗ”។

ទោះបីហុងសម្រេចបានសមិទ្ធិផលនិងមានចំណេះដឹងផ្ទាល់ខ្លួនកើនឡើង ព្រមទាំងការចាត់ចែងកើនឡើង ក្នុងចំណោមសហគមន៍ដែលរងផលប៉ះពាល់ក៏ដោយ ការគំរាមកំហែងមកលើព្រៃឡង់ កាន់តែអាក្រក់ខ្លាំងឡើងៗ។ ក្រុមហ៊ុនថ្មី បានទទួលសម្បទានដីសម្រាប់ចំការដំណាំលើផ្ទៃដីធំៗ ដែលមានប្រជាពលរដ្ឋរស់នៅ ឬពឹងអាស្រ័យ។ ក្រុមហ៊ុនរបស់វៀតណាមមួយឈ្មោះស៊ីអរស៊ីខេ អភិវឌ្ឍន៍ ដំណាំកៅស៊ូ (CRCK Rubber Development ) បានទទួលសម្បទានដីទំហំ ៦,០០០ ហិកតា កាលពីឆ្នាំ ២០១០។ ក្នុងខែកុម្ភៈ ២០១១ ប្រជាពលរដ្ឋ ៤០០ នាក់ បានព្យាយាមតវ៉ា នៅការិយាល័យរបស់ក្រុមហ៊ុនស៊ីអរស៊ីខេ កុំឲ្យឈូសឆាយដីព្រៃ។ ប៉ុន្តែពួកគាត់ត្រូវបានរារាំង ដោយយោធានិងប៉ូលិសខេត្ត ដែលបានបាញ់គ្រាប់កាំភ្លើងឡើងលើ ហើយបានយកកាំភ្លើងមកភ្ជង់អ្នកតវ៉ា។

ហុងបានចូលរួមសកម្មភាពមួយនៅខែបន្ទាប់ ពេលអ្នកស្រុកបានស្នើសុំព័ត៌មានពីក្រុមហ៊ុនភីអិនធីខូ អិលធីឌី ដែលជាក្រុមហ៊ុនសម្បទានដាំដំណាំចំការកៅស៊ូមួយនៅក្បែរនោះ។ ហុងបានពន្យល់ថា ៖ “ប្រជាពលរដ្ឋបានទៅស្វែងរកការគាំទ្រ។ ពួកគាត់សុំឲ្យក្រុមហ៊ុនបង្ហាញអាជ្ញាប័ណ្ណ និងចង់ដឹងថាក្រសួងណាផ្តល់អាជ្ញាប័ណ្ណ ឲ្យក្រុមហ៊ុនដើម្បីមករកស៊ី។ ក្រុមហ៊ុន បានដេញប្រជាពលរដ្ឋឲ្យចេញ និងគំរាមកំហែងប្រជាពលរដ្ឋ និងមិនឲ្យពួកគាត់មើលអាជ្ញាប័ណ្ណទេ។”

គ្មានសាលារៀន គ្មានមណ្ឌលសុខភាព គ្មានភ្លើងអគ្គិសនី និងគ្មានផ្លូវរឹងមាំ នៅក្នុងភូមិរបស់ហុងទេ។ ប៉ុន្តែហុងនិយាយថា ៖ “សម្រាប់ពួកខ្ញុំ ដែលជាជនជាតិដើមភាគតិច ទោះបីផ្លូវអាក្រក់យ៉ាងម៉េចក៏ដោយ យើងមិនខ្វល់ទេ ពីព្រោះយើងចង់រស់នៅដោយមានសេរីភាព។ ប្រសិនផ្លូវល្អ យើងនឹងមានបញ្ហាក្នុងការបាត់បង់ដីធ្លី ហើយងាយស្រួលក្រុមហ៊ុនចូលដល់... យើងមិនត្រេកត្រអាលឃើញក្រុមហ៊ុនចូលមកទេ”។

ហុងមានទស្សនយល់ឃើញថា ៖ “ការអភិវឌ្ឍន៍អាចផ្តល់លុយសម្រាប់មួយរយៈខ្លីប៉ុណ្ណោះ ...នៅពេលអស់លុយ អ្នកស្រុកបានបាត់បង់ដី និងធនធានធម្មជាតិស្រេចទៅហើយ។ ខ្ញុំបានឃើញបែបនេះ នៅក្នុងភូមិផ្សេងៗ។ ដូច្នេះហើយ ខ្ញុំមិនចង់បានបែបនោះទេ។ ខ្ញុំសប្បាយចិត្តដោយមានដីទុកសម្រាប់ឲ្យកូនចៅរបស់ខ្ញុំ ឬឲ្យអ្នកណាដែលគ្មានទីជម្រក... ខ្ញុំចង់រក្សាទុកព្រៃឈើ ដើម្បីរកស៊ីចិញ្ចឹមជីវិតតាមប្រពៃណីបន្តិចម្តងៗ។”

*ផូក ហុង ផ្តល់បទសម្ភាសន៍ជាមួយអង្គការលើកលែងទោសអន្តរជាតិ នៅថ្ងៃទី ២៦ ឧសភា ២០១១*



© អង្គការលើកលែងទោស អន្តរជាតិ

ហុង ព្រមទាំងប្តី យ៉ាន់ ទី និងកូនៗ យ៉ាន់ ផាណា និងយ៉ាន់ វណ្ណា
ខែមិថុនា ២០១១។



ពេលនេះ ខ្ញុំមានមោទនភាពខ្លួនឯង...
ខ្ញុំបានធ្វើឲ្យលទ្ធផលកើតឡើង ហើយខ្ញុំជាអ្នកដឹកនាំជាស្ត្រី។

# ហៀប

“ពេលខ្ញុំមានអង្ករមួយឬពីរគីឡូ
ខ្ញុំចែករំលែកឲ្យអ្នកផ្សេង។ ប្រសិនកូនពួកគេឈឺ
ខ្ញុំជួយយកពួកគេទៅមន្ទីរពេទ្យ
ជាមួយម៉ូតូរបស់ខ្ញុំ។ តើពួកខ្ញុំអាចធ្វើអ្វីខ្លះទៀត
ពេលយើងជួបបញ្ហាដូចគ្នានេះ?
យើងប្រឈមមុខនឹងការលំបាកទាំងអស់គ្នា”

ទិន ហៀប នៅក្នុងភូមិ ភ្និត ឃុំជីក្រែង ខេត្តសៀមរាប
ខែមីនា ២០១១





នៅថ្ងៃទី២២ មីនា ២០០៩ ប្រជាពលរដ្ឋ ១៧៥ គ្រួសាររស់នៅឃុំជីក្រែង ខេត្តសៀមរាប ត្រូវបានបណ្តេញចេញដោយបង្ខំពីដីស្រែដែលពួកគាត់ពឹងអាស្រ័យ ដើម្បីម្ហូបអាហារនិងការចិញ្ចឹមជីវិត ចាប់តាំងពីចុងទសវត្សរ៍១៩៨០មកម្លេះ។ កសិករប្រមាណ ៨០ នាក់មកពីជីក្រែង បានទៅច្រូតកាត់ប្រមូលស្រូវនៅលើដីមានជម្លោះ ហើយត្រូវប៉ូលិសនិងកងអាវុធហត្ថធ្វើការឡោមព័ទ្ធ ដោយមានអាជ្ញាធររដ្ឋាភិបាលនៅអមជាមួយ។ ពួកគេបានទាមទារឲ្យក្រុមកសិករទាំងនោះ ចាកចេញពីដី។ ពេលកសិករបដិសេធមិនព្រមចាកចេញ ប៉ូលិសបានបាញ់កាំភ្លើង និងធ្វើឲ្យអ្នកភូមិបួននាក់រងរបួស។ អ្នកភូមិ ១២ នាក់ទៀត ត្រូវបានចាប់ខ្លួន និងមានទោសពីបទឧក្រិដ្ឋផ្សេងៗគ្នា។ ពួកគាត់ត្រូវជាប់ពន្ធនាគារ ក្រោយពេលការកាត់ក្តីអយុត្តិធម៌មួយ ទោះបីពួកគាត់ទាំងអស់គ្នា ត្រូវដោះលែងនៅត្រឹមខែកក្កដា ២០១១ ក៏ដោយ។ ប៉ុន្តែ ក្រុមគ្រួសារនៅជីក្រែងគ្មានសិទ្ធិចូលដីស្រែរបស់ពួកគាត់នៅឡើយ។

ខែមីនា ឆ្នាំ២០០៩ ជាខែចាប់ផ្តើមរដូវច្រូតកាត់ប្រមូលផលនៅជីក្រែង។ ប្តីរបស់ហៀបឈ្មោះសាវឿន ស្ថិតក្នុងចំណោមអ្នកភូមិជាច្រើននាក់ ដែលបាននាំគ្នាទៅច្រូតកាត់ផលស្រូវនៅវាលស្រែរបស់ពួកគេ។ ខណៈពេលដែលហៀបនិយាយលាប្តី ពេលដែលប្តីទៅស្រែប្រមូលស្រូវ នាងមិនបានដឹងសោះថា ត្រឹមតែពីរបីម៉ោងក្រោយមកប៉ុណ្ណោះ ប្តីនិងកសិករចំនួន ៨០ នាក់ បានទទួលរងការគំរាមកំហែងនិងបាញ់ប្រហារពីសំណាក់ប៉ូលិស។ គាត់ក៏មិនដឹងថាសាវឿន ត្រូវបានចាប់ខ្លួនដែរ។

ជាក់ស្តែង វាជាព្រឹកចុងក្រោយដែលកសិករ បានចេញដំណើរទៅច្រូតកាត់ស្រូវ ពីព្រោះនៅពេលថ្ងៃជ្រេបន្តិច កងកម្លាំងសន្តិសុខត្រូវកាត់ផ្តាច់ផ្លូវចេញចូលទៅកាន់ដីស្រែ។ ពេលព្រឹក គឺជាចំណុចកំពូលនៃការផ្ទុះឡើងអំពើហិង្សាពីជម្លោះដីធ្លី។ វាជាជម្លោះរវាងប្រជាពលរដ្ឋ ១៧៥ គ្រួសារនៅជីក្រែង និងពាណិជ្ជករដែលមានខ្សែការពារ ដែលពួកគេបានអះអាងថាបានទិញដីពីអ្នកផ្សេងទៀត។

កាលនោះ ហៀបមានអាយុ ២៥ ឆ្នាំ កំពុងធ្វើការការងារផ្ទះប្រចាំថ្ងៃនៅក្នុងក្រុមគ្រួសាររបស់គាត់ ខណៈពេលដែលអ្នកភូមិដែលភ័យស្លន់ស្លោ បានរត់គេចពីអំពើហិង្សា បានសំរុកចូលផ្ទះរបស់គាត់។ ពួកគាត់ស្រែកប្រាប់ថា គេបានចាប់ប្តីរបស់គាត់ ហើយកំពុងនៅជាប់ឃុំខ្លួននៅសាលាស្រុក។ ហៀបបានរត់ទៅរកសាវឿន។ គាត់បានពន្យល់រឿងដែលបានកើតឡើង។ ពេលគាត់និងក្រុមកសិករឯទៀត បានច្រូតកាត់ស្រូវនៅក្នុងវាលស្រែ មានកំលាំងប៉ូលិសនិងអាវុធហត្ថប្រហែល១០០នាក់ បានឡោមព័ទ្ធពួកគាត់ ដោយមានព្រះរាជអាជ្ញាតុលាការខេត្តសៀមរាប អភិបាលរងខេត្តម្នាក់និងចៅហ្វាយស្រុក បានដឹកនាំ។ ពួកគាត់បានទាមទារឲ្យក្រុមកសិករចាកចេញពីតំបន់វាលស្រែ។ ពេលសាវឿន និងអ្នកភូមិផ្សេងទៀត មិនព្រមចាកចេញ ប៉ូលិសបានបាញ់កាំភ្លើង។

កសិករបួននាក់ បានរងរបួសធ្ងន់ធ្ងរ ដោយត្រូវគ្រាប់កាំភ្លើងនៅត្រង់ជើង។ ចំណែកកសិករដទៃទៀត ត្រូវបានវាយដំយ៉ាងខ្លាំង ក្រោយមកត្រូវចាប់ចងនឹងខ្សែ។ អស់ពេលជាច្រើនម៉ោង គេមិនអនុញ្ញាតឲ្យពួកគាត់ទទួលការព្យាបាលនៅពេទ្យទេ អ្នកភូមិ ៤៣ នាក់ ត្រូវបានឃុំឃាំង ដែលភាគច្រើន ត្រូវបានដោះវិញ ក្រោយពេលពួកគាត់បានចុះហត្ថលេខាលើឯកសារមួយឈប់ទាមទារដីនោះទៀត។ តែទោះជាយ៉ាងណាក្តី អ្នកភូមិចំនួន ៩ នាក់ រួមទាំងសាវឿនផង





ហៀប អង្គុយលើ កាំជណ្ដើរផ្ទះរបស់គាត់ជាមួយកូនបួននាក់ ខែ មីនា ២០១១។
ពីឆ្វេង៖ វឿន ឡាយហួរ វឿន សារង្ស ទិនហៀប វឿន សាវ៉ាន់ វឿន គីម ហ៊ួង

មិនព្រមចុះហត្ថលេខាបោះបង់ចោលសិទ្ធិ នោះទេ។
ពួកគាត់ត្រូវបានចោទថាជាមេខ្លោង ហើយត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋផ្សេងៗគ្នា
ដូចជាបទលួចស្រូវជាដើម។ សាវឿនត្រូវបានផ្ទេរមកកាន់ពន្ធនាគារខេត្តសៀមរាប
ដែលមានចម្ងាយប្រហែល ១០០ គីឡូម៉ែត្រពីផ្ទះ។ ប៉ុន្មានខែក្រោយមកទៀត
គេបានចាប់ខ្លួនអ្នកភូមិនៅជីក្រែងចំនួនបីនាក់ទៀត
និងដាក់ឃុំឃាំងពួកគាត់ដែលទាក់ទងក្នុងរឿងជម្លោះដីធ្លី។

ខណៈពេលភ្លាមៗនោះ ហៀបបានបាត់បង់ដីស្រែ
ហើយប្ដីរបស់គាត់ត្រូវគេយកចេញទៅពីរូបគាត់។ គាត់ត្រូវមើលថែកូនបួននាក់
និងត្រូវរកស៊ីចិញ្ចឹមខ្លួនដោយខ្លួនឯង។

ហៀបនិងសាវឿន បានប្រឹងប្រែងធ្វើការនិងមានជីវភាពយ៉ាងសាមញ្ញនៅក្នុងភូមិភ្និត។
គូរភរិយាស្វាមីនេះ មានផ្ទះឈើមួយខ្នង
សម្បីតែបង្គន់អនាម័យនិងទឹកប្រើប្រាស់គ្រប់គ្រាន់ក៏គ្មានដែរ។
ពួកគេមានស្រូវគ្រាប់គ្រាន់និងមានដីស្រែ។ ប្រជាពលរដ្ឋកម្ពុជា៨៥ភាគរយ
ពឹងផ្អែកលើមុខរបរកសិកម្ម សម្រាប់ចិញ្ចឹមជីវិត។

គ្រួសារភាគច្រើនពឹងលើដីស្រែចំការយ៉ាងតិចដីមួយហិកតា សម្រាប់ដាំដុះស្រូវ ឬដំណាំផ្សេងៗ។

សាផឿនគឺជាកម្មករសំណង់ និងជាអ្នករត់ម៉ូតូឌុប ក្រោយពេលធ្វើការសាបព្រោះស្រូវនិងរដូវច្រូតកាត់ប្រមូលផលរួច។ ពេលទំនេរ ហៀបជាអ្នកត្បាញក្រមាខ្មែរនិងរបស់របរផ្សេងៗ សម្រាប់រកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ។ ហៀបនិងសាផឿន គ្មានជំពាក់បំណុលគេទេ។ ពួកគាត់ខុសពីក្រុមគ្រួសារដទៃទៀតទៀត ដែលបានបង្ខំចិត្តខ្ចីប្រាក់មកទិញស្រូវពូជនិងជី។ គ្រួសារណាដែលប្រមូលផលស្រូវមិនសូវបានផល អាចត្រូវលក់ដី ដើម្បីសងបំណុលឲ្យទៅម្ចាស់បំណុលវិញ។ នេះគឺជាហេតុផលមួយដ៏ងាយយល់ អំពីមូលហេតុធ្វើឲ្យបាត់បង់ដីធ្លី។

## “សព្វថ្ងៃ ខ្ញុំត្រូវធ្វើការទ្វេឡើង ដើម្បីចិញ្ចឹមកូន ឲ្យកូនបានទៅសាលារៀន។ ពួកយើងគ្មានអង្ករច្រើន [ឬ] ទឹកគ្រប់គ្រាន់សម្រាប់ហូបទេ”។

ប្រាថ្នាចង់បានជីវិតល្អប្រសើរសម្រាប់កូនៗទាំងបួននាក់ និងដោយដឹងថាគុណវិបត្តិដែលពួកគេប្រឈមអាស្រ័យដោយកង្វះការអប់រំផ្ទាល់ខ្លួន ហៀបនិងសាផឿនបានដាក់ការសិក្សារៀនសូត្រគឺជាអាទិភាពខ្ពស់។ ហៀបពន្យល់ថា “កូនរបស់ខ្ញុំចូលចិត្តទៅសាលារៀន ពីព្រោះប្តីរបស់ខ្ញុំតែងតែនិយាយទៅពួកវាថា ៖ “កូនសម្លាញ់ ត្រូវខិតខំរៀនសូត្រណា។ ប៉ាមិនចេះអក្សរ អញ្ចឹងហើយបានជាជីវិតប៉ាជួបការលំបាក”។

ហៀបមានសេចក្តីត្រេកអរពេញចិត្ត ជាមួយអ្វីដែលរូបគាត់ និងសាផឿនបានសាងជីវិតជាមួយគ្នា។ ក្នុងឆ្នាំ២០០៥ ជម្លោះដីបានចាប់ផ្តើម។

## ជម្លោះដីធ្លី

ដំបូងឡើយ ជម្លោះកើតមានរវាងអ្នកភូមិក្នុងឃុំជីក្រែង រួមទាំងគ្រួសាររបស់ហៀបផង ដែលបានអះអាងថាបានដាំដុះលើផ្ទៃដីមានជីជាតិ ៤៧៥ ហិកតា ចាប់តាំងពីចុងទសវត្សរ៍១៩៨០មម្លេះ ជាមួយនឹងអ្នកភូមិនៅឃុំអន្លង់ដំណរ ៤៤ គ្រួសារ ដែលនៅជាប់ឃុំជាមួយគ្នា ក៏បានអះអាងថាជាដីរបស់ខ្លួនដែរ។ ពេលក្រុមគ្រួសារក្នុងឃុំជីក្រែង បានព្យាយាមជួសជុលប្រព័ន្ធប្រឡាយទឹកនៅលើដីនោះ អ្នកស្រុកក្នុងឃុំអន្លង់ដំណរ បានបញ្ឈប់ពួកគេដោយសុំអាជ្ញាធរខេត្តជួយធ្វើអន្តរាគមន៍។ នៅឆ្នាំបន្ទាប់មកទៀត ក្រុមគ្រួសារអន្លង់ដំណរ បានលក់ដីមួយផ្នែកឲ្យឈ្មួញ ហើយឈ្មួញបានលក់ដីនោះបន្តទៅឲ្យអ្នកផ្សេងទៀតដែលមកពីស្រុកផ្សេង។ ដូច្នេះ ប្រជាពលរដ្ឋឃុំជីក្រែង ដឹងថាខ្លួនឯងកំពុងមានជម្លោះតទល់ជាមួយបុគ្គល ដែលមានខ្នងការពារដោយអាជ្ញាធរស្រុកនិងខេត្តដ៏មានអំណាច។

ភាពតានតឹងចេះតែកើនឡើង។ នៅចុងឆ្នាំ២០០៨ អ្នកស្រុកជីក្រែងបីនាក់ តាមដែលហៀបរៀបរាប់មកថា ៖ “ដឹកនាំប្រជាពលរដ្ឋទាមទារដីមកវិញ” ត្រូវបានចាប់ខ្លួននិងចោទប្រកាន់ពីបទញុះញង់ និងបង្ករបួសស្នាម។ ការចាប់ចងមេដឹកនាំសហគមន៍ ដែលប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ បានក្លាយជាឧបករណ៍ដែលគេដឹងឮជាទូទៅច្រើនឡើងៗ សម្រាប់ការកៀបសង្កត់និងបំភិតបំភ័យ ដោយ ឈ្មួញមានអំណាច រួមគំនិតជាមួយអាជ្ញាធរ ប្រើដើម្បីបំបិទការតស៊ូ។ ក្នុងពេលធ្វើការតវ៉ាប្រឆាំងនឹងការចោទប្រកាន់ អ្នកភូមិប្រហែល២០០នាក់ បានដុតកង់ឡាននៅមុខតុលាការខេត្តសៀមរាប ហើយអំពាវនាវឲ្យមានការដោះលែងបុរសទាំងនោះ ដែលត្រូវបានគេដោះលែងដោយបង់ប្រាក់ធានាភ្លាមៗក្រោយមក។

ទោះបីមានកលល្បិចបំភិតបំភ័យរបស់អាជ្ញាធរយ៉ាងណាក៏ដោយ សហគមន៍ជីក្រែងបដិសេធមិនព្រមចុះញ៉ម។ ពួកគាត់មិនចុះចាញ់ចំពោះផលប្រយោជន៍របស់មនុស្ស ដែលពួកគាត់ចាត់ទុកថា កំពុងតែព្យាយាមលួចដីស្រែរបស់ពួកគាត់ ដែលគាត់ពឹងពាក់សម្រាប់ចិញ្ចឹមជីវិត។ នៅព្រឹកថ្ងៃទី២២ ខែមីនា ២០០៩ ប្រុសៗបានប្តេជ្ញា ពេលដែលពួកគេចេញទៅច្រូតកាត់ស្រូវរបស់ខ្លួន។ គេអាចយល់បានថា

អ្នកខ្លះសុខចិត្តចុះចាញ់នឹងការកៀបសង្កត់ ដើម្បីជៀសផុតពីការចាប់ខ្លួន។ ទោះជាក្រោយពេលដែលសាផឿន ត្រូវបានគេឃុំឃាំងនិងដាក់គុក ដោយគ្មានសវនាការដ៏យុត្តិធម៌ក្តី ក៏គាត់នៅតែជំនះនឹងភាពអយុត្តិធម៌។ ទោះបីយ៉ាងណាក្តី គាត់ព្រួយបារម្ភខ្លាំងចំពោះប្រពន្ធ ដោយសារហៀបមានបន្ទុកធ្ងន់ក្នុងការរកប្រាក់ឲ្យគ្រាប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារ។

## “បក្សីបាត់បង់សម្បុក”

ដោយនៅថែទាំកូនផ្ទាល់ដៃ ហៀបនិយាយថាគាត់មានអារម្មណ៍បាត់បង់។ ដោយឥតមានប្តីនៅផ្ទះ និងបាត់បង់មាតាបិតាទាំងពីរ។ ម្តាយរបស់គាត់បានស្លាប់បីខែក្រោយពេលចាប់ខ្លួនសាផឿន។ ហៀបចាត់ទុកខ្លួនឯងជា “បក្សីបាត់បង់សម្បុក”។

ហៀបនិយាយថ្លែងថា ៖ “សព្វថ្ងៃ ខ្ញុំត្រូវធ្វើការទ្វេឡើង ដើម្បីចិញ្ចឹមកូន ឲ្យកូនបានទៅសាលារៀន។ ពួកយើងគ្មានអង្ករច្រើន [ឬ]ទឹកគ្រប់គ្រាន់សម្រាប់ហូបទេ”។ ហៀបនិងអ្នកភូមិដទៃទៀតទៀត ដែលបានបាត់បង់ដីធ្លី ត្រូវតែរកការងារជាកម្មករស៊ីឈ្នួលលក់ពលកម្ម ដូចជាដកស្ទូង ច្រូតកាត់ស្រូវរបស់កសិករឯទៀត។ កម្រៃដែលពួកគាត់ទទួលបានគឺជាអង្ករ ឬជាលុយ។ ប៉ុន្តែ ឈ្នួលការងារទោះជាអង្ករ ឬលុយក្តី មិនមែនជារង្វាន់ជាទីគាប់ចិត្តទេ។

ហៀបពិពណ៌នាអំពីស្ថានភាពថ្មីរបស់គាត់ថា “ឃោរឃៅ។” គាត់បានសារភាពថា “ក្នុងនាមជាស្ត្រីម្នាក់ដែលប្រឈមមុខនឹងបញ្ហាដ៏ច្រើន ដូចជារស់នៅម្នាក់ឯង និងត្រូវរកប្រាក់ចិញ្ចឹមកូន ពេលខ្លះ[ខ្ញុំ]ចង់រត់ចោលផ្ទះ”។ គាត់និយាយថា ៖ “ខ្ញុំនិយាយប្រាប់ខ្លួនឯង កុំឲ្យគិតច្រើនពេក បើទុកជាគ្មានប្តីក៏ដោយ បើមិនគិតអញ្ចឹងទេឬ ខ្ញុំនឹងឆ្កួតមិនខាន... [ខ្ញុំ]ក៏ចាប់គិតអំពីអ្វីដែលត្រូវធ្វើនៅថ្ងៃស្អែកដើម្បីរកប្រាក់... និងគិតរកអាហារអ្វីខ្លះសម្រាប់ឲ្យកូនហូប។”

សាផឿន ដែលជាប្តី របស់ហៀប នៅ ពន្ធនាគារ ខេត្តសៀមរាប។ ហៀបសួរសុខទុក្ខប្តីជាញឹកញាប់ ពេលគាត់អាចរកប្រាក់ធ្វើសោហ៊ុយធ្វើដំណើរចំនួន ២៥ដុល្លារ




គាត់និយាយថា ៖ “ប្រុសជាច្រើនមើលងាយខ្ញុំ ដោយសារខ្ញុំរស់នៅតែម្នាក់ឯង។ ពួកគេនិយាយថា ៖ “មិនចង់យកប្តីថ្មីទេអី?។ បើមិនយកប្តី តើបានអ្នកណាជួយ បើប្តីកំពុងជាប់គុក?”។ វាជាស្ថានភាពដ៏ពិបាកសម្រាប់កូនៗរបស់ហៀប ដែលពួកវានៅជាមួយឪពុករបស់ខ្លួនក្នុងពន្ធនាគារដែរ។ ហៀបនិយាយថា ពេលកូនរបស់គាត់ត្រឡប់មកពីសាលារៀនវិញ ពួកវាថ្លែងថាត្រូវសិស្សសាលានិងគ្រូ និយាយចំអកឲ្យពួកវាថា ៖ “បើឪពុកឯងជាអ្នកទោស ជាចោរលួចដី តើមានអ្នកណាហ៊ានជួយឯង?”... ពួកវាមិនចង់ទៅរៀនទេ។ ពួកវាខ្មាស់គេ... ប៉ុន្តែពេលពួកវាទៅសួរសុខទុក្ខឪពុកក្នុងគុក គាត់បានប្រាប់ឲ្យពួកវាខិតខំរៀនសូត្រ”។

ហៀប(រូបទីបីពីខាង ឆ្វេង) នៅជាមួយនិង ញាត្តិ របស់អ្នកភូមិ
ដីក្រែងជាប់ពន្ធនាគារ



© អង្គការលើកលែងទោស អន្តរជាតិ



## ការជួយគ្នាទៅវិញទៅមក

ទោះបីបញ្ហារបស់គាត់មានទម្ងន់ធ្ងន់ក៏ដោយ ហៀបបានព្យាយាមអស់លទ្ធភាព
ដើម្បីជួយស្ត្រីផ្សេងទៀតក្នុងភូមិរបស់គាត់។ “ពេលខ្ញុំមានអង្ករមួយឬពីរគីឡូ
ខ្ញុំចែករំលែកឲ្យអ្នកផ្សេង។ ប្រសិនកូនពួកគេឈឺ ខ្ញុំជួយយកពួកគេទៅមន្ទីរពេទ្យ
ជាមួយម៉ូតូរបស់ខ្ញុំ។ តើពួកខ្ញុំអាចធ្វើអ្វីខ្លះទៀតពេលយើងជួបបញ្ហាដូចគ្នានេះ?
យើងប្រឈមមុខនឹងការលំបាកទាំងអស់គ្នា។ ហេតុដែលយើងស្រឡាញ់រាប់អានគ្នា
គឺដោយសារយើងមានរឿងដូចគ្នា បញ្ហាដូចគ្នា...
ស្ត្រីខ្លះទៀតនៅពេលដែលប្តីត្រូវគេចាប់ខ្លួន ពួកគេមានផ្ទៃពោះនិងមានកូនតូចៗទៀតផង
អញ្ចឹងហើយបានជាខ្ញុំចង់ជួយ... ពួកគាត់ត្រូវចិញ្ចឹមកូនដូចខ្ញុំដែរ។
ពួកគេឯកោដូចខ្ញុំដែរ... ពេលណានឹកឃើញរឿងហ្នឹង ខ្ញុំយំ។”

ហៀបរំឭកឡើងថា ៖ “ខ្ញុំរឹងមាំជាងមុន ពីព្រោះខ្ញុំបានបាត់បង់អ្នកដែលខ្ញុំបានពឹង
ដូចនេះខ្ញុំត្រូវតែជួយខ្លួនឯង។
ស្ត្រីឯទៀតបានលើកទឹកចិត្តខ្ញុំនិងជួយផ្តល់ជាគំនិតថាត្រូវធ្វើអ្វី...
ពីមុនខ្ញុំធ្លាប់តែជាមេផ្ទះម្នាក់ តែឥឡូវ ខ្ញុំអាចធ្វើងារដូចប្រុសដែរ។
ខ្ញុំអាចធ្វើការរកលុយសម្រាប់កូនខ្ញុំ”។ គាត់និយាយថានៅក្នុងភូមិ
គេចាត់ទុកស្ត្រីជាមនុស្សទន់ខ្សោយជាងបុរស ទាំងកំលាំងកាយនិងប្រាជ្ញា។
ហៀបនិយាយថា ៖ “ខ្ញុំ យល់ថាទស្សនៈនេះខុសហើយ
ពីព្រោះស្ត្រីក៏មានគំនិតនិងយោបល់ដូចប្រុសដែរ។ ការពិត
ស្ត្រីអាចធ្វើការបានច្រើនជាងបុរសផង។ បុរសចេញទៅធ្វើការរកលុយ
ចំណែកស្ត្រីត្រូវធ្វើការងារផ្ទះយ៉ាងច្រើន ដូចជាបាកខោអាវ ដាំបាយ មើលកូន
រែកទឹក បង្កាត់ភ្លើង ស្រិតអង្ករ។ ខ្ញុំធ្លាប់ឮបុរសនិយាយថា ស្រីៗនៅតែផ្ទះមើលកូន
និងមិនអាចលួងកូនឲ្យឈប់យំផង។ ខ្ញុំខឹងណាស់។ ប្រសិនបុរសអាចបំបៅកូន
ខ្ញុំឲ្យគេធ្វើ ហើយខ្ញុំនឹងចេញទៅរកលុយ”។ ហៀបនិយាយសើច។
“ធ្វើជាប្រុសពិតជាស្រួលខ្លួន ពេលយើងត្រឡប់មកផ្ទះវិញ អាហារឆ្អិនស្រាប់។
យើងមុជទឹកហើយចូលមុងដេក”។

ហៀបជញ្ជឹងគិតថា ៖ “សព្វថ្ងៃខ្ញុំមើលទូរទស្សន៍ ឃើញថាប្រធានភូមិខ្លះជាស្ត្រីភេទ។
តំណាងរាស្ត្រម្នាក់នៅក្នុងគណបក្សសមរង្ស៊ី [គណបក្សប្រឆាំង] គឺជាស្ត្រី លោកជំទាវ
មូ សុខហួរ... ខ្ញុំចង់ធ្វើដូចពួកគាត់ដែរ ប៉ុន្តែខ្ញុំគ្មានលទ្ធភាពទេ។
វាគ្រាន់តែជាគំនិតរវើរវាយប៉ុណ្ណោះ។ ព្រោះឥឡូវខ្ញុំចាស់ហើយ
ខ្ញុំមិនអាចចូលរៀនសូត្របានទេ។ ខ្ញុំតែងសួរព្រះតេជព្រះគុណថា
ខ្ញុំអាចទៅរៀនបានទេ ព្រះអង្គសួរវិញថា “តើអង្គុយរៀនជាមួយកូនបានទេ? ខ្ញុំថា
“ករុណាមិនខ្វល់ទេ មិនខ្មាស់គេទេ បើសិនអាចទៅ[សិក្សា]បាន។”

ភាពឯករាជ្យម្ចាស់ការរបស់គាត់ដែលទើបតែមានថ្មីៗ គឺការលួងលោមចិត្តបន្តិចបន្តួច
សម្រាប់ទុក្ខវេទនាដែលបានចាក់ស្រេះមកលើរូបគាត់។
ហៀបទៅសួរសុខទុក្ខប្តីនៅក្នុងពន្ធនាគារជារឿយៗ ពេលគាត់មានប្រាក់ ១០០,០០០
រៀល សម្រាប់សោហ៊ុយធ្វើដំណើរ ទិញអាហារជូនគាត់ ថ្នាំសង្កូវ សាប៊ូ
និងរបស់ចាំបាច់ផ្សេងៗ និងទិញសំបុត្រចូលទៅកន្លែងរង់ចាំរបស់អ្នកសួរសុខទុក្ខ
ដែលគាត់អាចនិយាយឆ្លើយឆ្លងជាមួយប្តី តាមចម្រឹងដែក។

ពន្ធនាគារខេត្តសៀមរាប អាចដាក់អ្នកទោសបាន ១,០០០
នាក់ប៉ុណ្ណោះ ប៉ុន្តែក្នុងពេលបច្ចុប្បន្ន មានអ្នកទោសដល់ទៅជាង
១,៥០០ នាក់ កំពុងរស់នៅក្នុងនោះ។ ស្ថានភាពគុកមិនសូវល្អទេ។
ហៀបនិយាយថាសារឿនទទួលរបបបាយមួយចាន ពីរដងក្នុងមួយថ្ងៃ។
ទោះយ៉ាងណាក្តី នាងមិនប្រាកដទេថាអាហារនិងរបស់ដែលគាត់ផ្ញើរ
បានដល់ដៃសារឿនឬយ៉ាងណា។
នាងនិយាយថារបស់ទាំងនោះនាងបានផ្ញើរតាមឆ្មាំគុក
ដែលគេបានកាត់យកមួយចំណែកសម្រាប់ខ្លួនឯង។

ហៀបមិនដឹងប្រាកដថាតើសារឿននឹងនៅមានទោសជាប់ពន្ធនាគារ
ដោយសារគាត់ត្រូវជាប់ពីបទឧក្រិដ្ឋជាមួយចំនួន រួមមានអំពើបង្ករបួសស្នាម លួចស្រូវ
ដែលករណីនីមួយៗត្រូវបានគេសវនាការដាច់ដោយឡែកពីគ្នា។ នាងខូចចិត្តយ៉ាងខ្លាំង
ដោយដំណើរការកាត់ក្តីរបស់តុលាការមានភាពយឺតគ្មានប្រសិទ្ធភាពនិងអយុត្តិធម៌
ដែលនាងរ៉ាយរ៉ាប់ជាច្រើនដងថា “នៅពេលដែលសហគមន៍ជីក្រែង
មកលើកទឹកចិត្តដល់ជនជាប់ចោទ” តាមថ្ងៃកំណត់កាត់ទោសរបស់តុលាការ
ពួកគេបែជាពន្យាពេលសវនាការកាត់ទោស... ពេលខ្លះទៀត
ការកាត់ទោសបានប្រព្រឹត្តទៅមិនបានជូនដំណឹង ហើយគ្មានវត្តមានមេធាវី។

ហៀបសោកស្តាយពន់ពេកចំពោះកង្វះខាតយុត្តធម៌។ គាត់និយាយថា ៖ “ប្រព័ន្ធតុលាការកម្ពុជា តែងតែលំអៀង... សប្រែជាខ្មៅ ត្រូវប្រែជាខុស។ អ្នកដែលមានអំណាចនិងលុយ ធ្វើអ្វីក៏ត្រូវដែរ។ រដ្ឋាភិបាលមិនបានជួយប្រជាពលរដ្ឋឲ្យមានបានទេ។ រដ្ឋាភិបាលជួយតែអ្នកមាន ដើម្បីជិះជាន់លើអ្នកក្រ ប៉ុណ្ណោះ”។

> “ពពួកជនពុករលួយនៅតែពុករលួយ។ មន្ត្រីរដ្ឋាភិបាលនៅតែមានខ្សែ។ តើអ្នកក្រមាន ឱកាស បានរៀនសូត្រយ៉ាងម៉េចទៅ?”

ហៀបនិយាយថាគាត់ចង់ឃើញរដ្ឋាភិបាលអភិវឌ្ឍន៍ ប៉ុន្តែចំពោះគាត់ ការអភិវឌ្ឍន៍គឺមានន័យថាយុត្តិធម៌ សិទ្ធិស្មើគ្នា និងតំណាងត្រឹមត្រូវឲ្យអ្នកក្រ ៖ “ពាក្យថា ‘អភិវឌ្ឍន៍’ ខ្ញុំចង់និយាយថាអ្នកដែលមានកំហុសក្នុង[បទឧក្រិដ្ឋ] ដូចជាជនបាញ់ប្រហារនៅជីក្រែង ត្រូវតែរកកំហុសពួកគេ ហើយអ្នកដែលគ្មានកំហុស ត្រូវតែដោះលែង... [សព្វថ្ងៃ] អ្នកទាំងឡាយដែលកំពុងតែស្ថិតនៅក្នុងប្រព័ន្ធយុត្តិធម៌ គឺជាអ្នកដែលមានលុយទិញមុខតំណែង។ អញ្ចឹង តើអ្នកក្រមានឱកាសអីទៀត?” គាត់ចោទសួរថា “ហេតុអ្វីរដ្ឋាភិបាលមិនរវល់នឹងប្រជាពលរដ្ឋ? ពេលនៅលើកញ្ចក់ទូរទស្សន៍ ពួកគេតែងតែនិយាយថាជួយប្រជាពលរដ្ឋក្រីក្រ។ តើជួយអ្នកក្រីក្រមែនទេ? ជួយបែបណាខ្លះហើយ? ពពួកជនពុករលួយនៅតែពុករលួយ។ មន្ត្រីរដ្ឋាភិបាលនៅតែមានខ្សែ។ តើអ្នកក្រមានឱកាស បានរៀនសូត្រយ៉ាងម៉េចទៅ?”

ហៀបសង្ឃឹមថានៅថ្ងៃណាមួយ ប្រទេសរបស់គាត់នឹងមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ហើយអ្នកក្រ មុខជាត្រូវបានគេប្រព្រឹត្តជាប្រជារាស្ត្រដែលមានសិទ្ធិស្មើគ្នា។ គាត់និយាយថា ៖ “ខ្ញុំចង់ឲ្យរដ្ឋាភិបាលមើលឃើញអ្នកក្រផ្ទាល់ភ្នែក និងយកចិត្តទុកដាក់អ្នកក្រ... កុំគិតតែអំណាចនិងលុយពេក។ អ្នកក្រក៏មានបេះដូង និងសិទ្ធិដែរ”។

## សេចក្តីបន្ថែម ៖ សារឿនត្រូវបានដោះលែង

ក្នុងខែមេសា ឆ្នាំ២០១១ រយៈពេលពីរឆ្នាំបន្ទាប់ពីចាប់ខ្លួន សារឿនត្រូវបានដោះលែង។ យោងតាមសំដីហៀប គេបានបង្ខំសារឿនឲ្យចុះហត្ថលេខាលើពាក្យសន្យាមួយ ថាខ្លួននឹងមិនប្រកាសទាមទារសិទ្ធិលើដីស្រែរបស់ខ្លួន ឬព្យាយាមចេញចូលដីនោះទៀតទេ។ ប្រសិនគាត់ក្បត់ពាក្យសន្យា គាត់នឹងត្រូវចាប់ខ្លួន។ បន្ទាប់មកទៀត ហៀបនិងសារឿនបានបែកគ្នា។ ហៀបបានទៅរស់នៅប្រទេសថៃ។

*ទិន ហៀប បានធ្វើសម្ភាសន៍ជាមួយអង្គការលើកលែងទោសអន្តរជាតិ នៅថ្ងៃទី១៣ មីនា ២០១១*


© អង្គការលើកលែងទោស អន្តរជាតិ

ហៀប និងកូនៗ កំពុងមើលរូបថតចាស់



“អ្នកដែលមានអំណាចនិងលុយ ធ្វើអ្វីក៏ត្រូវដែរ។
រដ្ឋាភិបាលមិនបានជួយប្រជាពលរដ្ឋ ឲ្យមានបានទេ។
រដ្ឋាភិបាលជួយតែអ្នកមាន ដើម្បីជិះជាន់លើអ្នកក្រ ប៉ុណ្ណោះ។”

# វ៉ាន់នី

“នៅទីបញ្ចប់ ទោះឈ្នះឬចាញ់ ខ្ញុំនៅតែសប្បាយចិត្ត ដោយបានតស៊ូជាមួយអ្នកដទៃ។ ខ្ញុំនឹងតស៊ូ ដើម្បីបានរស់នៅក្នុងសំបុកចាស់របស់ខ្ញុំ។ ខ្ញុំនឹងតស៊ូរហូតដល់ទឹកចុង ក្រោយ។”

ទេព វ៉ាន់នី បឹងកក់ ភ្នំពេញ ខែមេសា ២០១១។




© អង្គការលើកលែងទោស អន្តរជាតិ

ក្នុងឆ្នាំ២០០៧ ក្រុមហ៊ុនមួយបានទទួលសម្បទានដីដែលជួលរយៈពេល៩៩ឆ្នាំ ក្នុងតំបន់បឹងកក់ ក្នុងរាជធានីភ្នំពេញ។ មួយឆ្នាំបន្ទាប់មក អ្នកភូមិចំនួន ២០,០០០ នាក់ ដែលរស់នៅក្នុងតំបន់នោះ ត្រូវបានគំរាមកំហែងពីការបណ្តេញចេញ។ ក្រុមគ្រួសារស្ទើរទាំងអស់និយាយថា ការផ្តល់សំណងជាប្រាក់ចំនួន ៨,៥០០ ដុល្លារអាមេរិកក្តី ឬជាផ្ទះល្វែងនៅកន្លែងតាំងទីលំនៅថានថ្មីខាងក្រៅរាជធានីភ្នំពេញក្តី មិនគ្រប់គ្រាន់សម្រាប់ពួកគាត់ ដើម្បីស្វែងរកទិញលំនៅឋានថ្មី ឬសម្រាប់ការងារទេ។ គ្រួសារជាច្រើនដែលបានទទួលយកសំណងនោះ មានការលំបាកយ៉ាងខ្លាំង។ ការជូនដំណឹងស្តីពីគម្រោងអភិវឌ្ឍន៍ដល់ប្រជាពលរដ្ឋ មិនបានសមស្របទេ ហើយក៏មិនបានធ្វើការពិគ្រោះយោបល់ជាមួយពួកគាត់ ដើម្បីកំណត់ជម្រើសក្រៅពីការបណ្តេញចេញ ឬការតាំងទីលំនៅថ្មី និងផ្តល់ជាសំណងទេ។ ការព្យាយាមដោះស្រាយតាមផ្លូវតុលាការ រហូតដល់ពេលនេះគឺបរាជ័យ។ ក្រុមគ្រួសារដែលនៅតស៊ូ ប្រឆាំងការបណ្តេញចេញដោយបង្ខំ បានស្នើសុំរស់នៅនឹងកន្លែង ទោះបីនៅផ្ទះរបស់ខ្លួន ឬផ្ទះដែលត្រូវសាងសង់ក្នុងតំបន់អភិវឌ្ឍន៍ក៏ដោយ។ ក្នុងខែសីហា ២០១១ លោកនាយករដ្ឋមន្ត្រី បាន អនុញ្ញាតឲ្យទុកបម្រុងដីមួយផ្នែករបស់បឹងកក់ សម្រាប់ឲ្យអ្នកភូមិដែលនៅសេសសល់ សម្រាប់ធ្វើ ការអភិវឌ្ឍន៍ លំនៅឋាននៅនឹងកន្លែង។


© អង្គការលីកាដូ

នៅលើជញ្ជាំងផ្ទះរបស់វ៉ាន់នី មានព្យួររូបថតរបស់គាត់កាលពីនៅវ័យ២០ឆ្នាំ។ ឥឡូវគាត់អាយុ៣១ឆ្នាំ។ វ៉ាន់នីបានមើលរូបថត ហើយសើចលាយលំនឹងទុក្ខសោក។ គាត់ជញ្ជឹងគិតថា ៖ "កាលនោះ ខ្ញុំស្អាត ឡើងមូលក្លំ។ ឥឡូវខ្ញុំឡើងកញ្ចាស់ និងហត់នឿយ ដោយសារភ័យខ្លាចពីការបណ្តេញចេញ"។

វ៉ាន់នីនិងគ្រួសារ បានរស់នៅប្រឈមនឹងការគំរាមកំហែងជាប្រចាំ ពីការបណ្តេញចេញដោយបង្ខំ ចាប់តាំងពីឆ្នាំ២០០៧មក។ នៅពេលរាជរដ្ឋាភិបាលកម្ពុជាបានជួលដីចំនួន ១៣៣ ហិកតា ដែលជាទីតាំងដ៏ល្អបំផុតក្នុងរាជធានីភ្នំពេញ ទៅឲ្យក្រុមហ៊ុនឯកជនមួយ។ ទន្ទឹមពេលនោះដែរ តំបន់ដែលជួលគឺរួមមានដីបឹងរាប់ហិកតា ដែលជាលំនៅឋានរបស់ប្រជាពលរដ្ឋក្រីក្រនិងមានជីវភាពមធ្យមចំនួន ៤,០០០គ្រួសារ រួមទាំងផ្ទះរបស់វ៉ាន់នីផងដែរ។ គ្រួសារជាច្រើនដែលរស់នៅក្នុងតំបន់ជួលដីនោះ មានការបញ្ជាក់ច្បាស់លាស់អំពីកម្មសិទ្ធដីលំនៅឋាន បើយោងតាមច្បាប់ភូមិបាលប្រទេសកម្ពុជា។ ប៉ុន្តែការប្រកាសអះអាង ត្រូវបានអើពើទេ នៅពេលរដ្ឋាភិបាលបានផ្តល់សម្បទានដីឲ្យក្រុមហ៊ុនស៊ុកាកុអ៊ីន។

ដីឡូនៅក្នុងភូមិ២២ គឺជាចំណងដៃអាពាហ៍ពិពាហ៍ ឲ្យវ៉ាន់នីនិងប្តីរបស់នាងឈ្មោះជា ពីឪពុកម្តាយក្មេករបស់នាង ដែលពួកគាត់បានទិញដីនោះក្នុងឆ្នាំ១៩៩៣។ វ៉ាន់នីបានរុះរើផ្ទះដែលបាក់បែក ហើយបានយកប្រាក់សន្សំមកសាងសង់ផ្ទះសុបិន្តរបស់ខ្លួន ដោយធ្វើរោងតូចមួយទុកសម្រាប់វ៉ាន់នី ប្រកបមុខរបរលក់ដូរឥវ៉ាន់ និងគ្រឿងសំអាង។

វ៉ាន់នីអាចមើលថែទាំកូនតូចទាំងពីរនាក់ ហើយគ្រប់គ្រងតូបលក់ឥវ៉ាន់ សម្រាប់បំពេញបន្ថែមប្រាក់ខែតិចតួចរបស់ប្តីដែលធ្វើការជាទាហាន។ ពួកគេរីករាយទទួលយកសេវានិងគ្រឿងបរិក្ខារ ដែលបានផ្តល់ឲ្យដោយសាលាក្រុង ៖ ដូចជាការតភ្ជាប់ប្រព័ន្ធចែកចាយទឹក និងភ្លើងអគ្គិសនីក្នុងតម្លៃសមស្រប សាលារៀនល្អដែលអាចដើរទៅរៀនបាន និងមន្ទីរពេទ្យ។

ការមើលពីលើបឹងកក់ភ្នំពេញ ខែកក្កដា ២០១១





វ៉ាន់នីមិនចង់ចាកចេញទៅណាឆ្ងាយទេ។ គាត់និយាយថា ៖ “រស់នៅទីនេះធ្វើឲ្យយើងអាចមានអនាគតល្អ”។

វ៉ាន់នី បានកើត និងធំដឹងក្តីនៅក្នុងតំបន់ជនបទមួយក្នុងខេត្តកំពតភាគខាងត្បូងប្រទេសកម្ពុជា។ គាត់បាននិយាយថា ៖ “តាំងពីខ្ញុំនៅតូចខ្ញុំមិនដែលស្រមៃថា ខ្ញុំមានផ្ទះដូចអញ្ចឹងទេ”។ ឪពុកម្តាយរបស់នាង ក្រីក្រ។ កាលនៅតូច វ៉ាន់នីត្រូវធ្វើការរកប្រាក់ចំណូលជួយគ្រួសារ ដោយដើររើសអេតចាយ។ គាត់បានបោះបង់សាលារៀននៅត្រឹមថ្នាក់ទី៩ ដើម្បីជួយគ្រួសារ។ វ៉ាន់នីបានសម្រេចចិត្តថាត្រូវរៀនភាសាអង់គ្លេសដែលជារឿងសំខាន់។ គាត់បានរកឃើញគ្រូបង្រៀនម្នាក់ ហើយបានចូលរៀនក្នុងថ្នាក់។ សូម្បីតែថ្លៃថ្នាក់ត្រឹមតែ១០០រៀលមួយម៉ោង គាត់សឹងតែមិនអាចរកប្រាក់បង់ឲ្យគ្រូបានផង។ ពីរបីឆ្នាំកន្លងមក វ៉ាន់នីបានមករាជធានីភ្នំពេញ ដើម្បីស្វែងរកការងារធ្វើ។ គាត់បានរកការងារ ហើយបានធ្វើជាអ្នកទទួលភ្ញៀវ និងអ្នកគិតប្រាក់នៅភោជនីយដ្ឋានមួយ។

វ៉ាននី មានមោទនភាពចំពោះអ្វីដែលនាងសម្រេចបានរយៈការប្រឹងធ្វើការ ការតាំងចិត្ត និងការទំនុកបម្រុងពីគ្រួសារសាច់ថ្លៃរបស់នាង។ ប៉ុន្តែ ជីវិតសប្បាយរីករាយក្នុងនាមជាមេផ្ទះ និងជាម្ចាស់មុខរបរតូចតាចនៃគ្រួសារមធ្យមនេះ បានក្រឡាប់ចាក់ ដោយសារការជួលដីបឹងកក់ និងការគំរាមកំហែងពីការបណ្តេញចេញដោយបង្ខំ។ នាងបានពន្យល់ថា ៖ “ការអភិវឌ្ឍន៍ បានមកដល់ក្នុងឆ្នាំ២០០៨។ រដ្ឋាភិបាលមិនបានប្រកាសឲ្យដឹងជាសាធារណៈ ថាខ្លួនបានឲ្យតំបន់បឹងកក់ទៅឲ្យក្រុមហ៊ុនស៊ីកាកុអ៊ីនសម្រាប់អភិវឌ្ឍន៍ទេ។ ពួកខ្ញុំដឹងពេលក្រុមហ៊ុនបានមកដាក់ការិយាល័យរបស់ខ្លួននៅទីនេះ”។

## សំណងសមរម្យ

សាលារាជធានីភ្នំពេញ បានផ្តល់សំណងដល់គ្រួសារចំនួន ៨.៥០០ ដុល្លារអាមេរិក សម្រាប់ដីរបស់ពួកគាត់ក្នុងមួយគ្រួសារ ដោយមិនគិតពីទំហំដីឡូ ឬគុណភាពផ្ទះ និងសំណង់ផ្សេងៗទៀត ឬត្រូវជ្រើសរើសរើទៅតាំងទីលំនៅឯដំណាក់ត្រយឹង ដែលមានចម្ងាយ២០គីឡូម៉ែត្រ ក្រៅរាជធានីភ្នំពេញនោះទេ។ វ៉ាន់នី និយាយថា គ្មានអ្នកណាម្នាក់ចង់ទទួលយកសំណងទេ ប៉ុន្តែនិយាយថាប្រជាពលរដ្ឋបានទទួលយកដោយបង្ខិតបង្ខំ។

គាត់សួរថា ៖ "តើពួកអ្នកស្រុកអាចឆ្លើយថាមិនយកដោយរបៀបណាទៅ? បើអាជ្ញាធរបានប្រាប់អ្នកស្រុកថា បើមិនព្រមយកទេ នឹងមានភ្លើងឆេះ ឬទឹកជំនន់ជនលិចផ្ទះ ហើយមួយរៀលក៏មិនបានផង"។ គាត់បាននិយាយពណ៌នាអំពីប៉ូលិសប្រដាប់ដោយអាវុធ និងកម្មករក្រុមហ៊ុន ដែលបានដើរ ឬជិះម៉ូតូជុំវិញភូមិ ដើម្បីបំភិតបំភ័យនិងគំរាមកំហែងប្រជាពលរដ្ឋ។

សម្រាប់អ្នកដែលព្រមទទួលយកសំណង អាចរកទិញដីតែនៅក្រៅទីក្រុងភ្នំពេញប៉ុណ្ណោះ។ វានៅឆ្ងាយពីកន្លែងការងារ និងសេវាកម្មផ្សេងៗ។ វ៉ាន់នីពន្យល់ថា ៖ "អ្នកខ្លះចាយអស់លុយមុនពេលពួកគាត់រកទិញកន្លែងថ្មីបាន ហើយបានត្រឡប់មកបឹងកក់វិញ ដើម្បីជួលបន្ទប់នៅ។ អ្នកដទៃទៀត បានរកឃើញកន្លែងដែលមានតម្លៃ ៤,០០០ ទៅ ៥,០០០ដុល្លារអាមេរិក ប៉ុន្តែជាកន្លែងត្រូវប្រឈមនឹងការបណ្តេញចេញ។ អ្នកទាំងនោះ ត្រូវគេបណ្តេញចេញម្តងទៀត"។

ជម្រើសផ្សេងទៀតលើសំណងសម្រាប់អ្នកភូមិ គឺត្រូវរើទៅតាំងទីលំនៅឋាន នៅឯដំណាក់ត្រយឹង។ វ៉ាន់នីនិយាយថា ជម្រើសផ្លូវណាក៏ដោយគឺនៅតែចេញក្រៅទីក្រុងដែរ។ គាត់ងឿងឆ្ងល់ថាតើប្រជាពលរដ្ឋ ធ្វើការរកស៊ីអ្វីបាននៅទីនោះ ឬគាត់មានលទ្ធភាពឯណាបង់ថ្លៃធ្វើដំណើរមកទីក្រុងធ្វើការ។ អតីតអ្នកជិតខាង ដែលបានចេញទៅនៅរួចហើយនោះ បាននិយាយប្រាប់គាត់ថា ជីវភាពកាន់តែពិបាក ខ្លាំងឡើង។ វ៉ាន់នីនិយាយថា ៖ "មានការលំបាកគ្រប់យ៉ាង ប្រសិនយើងរើចេញទៅ។ គ្រួសាររបស់យើងលែងមានសុភមង្គលទៀតហើយ។"



ផ្ទះមួយនេះ រងការបាក់បែក ប៉ុន្តែ អាចរស់នៅបាន។
វានៅជិតផ្ទះរបស់វ៉ាន់នីតំបន់បឹងកក់



ក្រុមគ្រួសារដែលរស់នៅជុំវិញតំបន់បឹងកក់ ចាប់ផ្ដើមប្រឈមមុខនឹងការគំរាមកំហែងបំភិតបំភ័យ ក្នុងខែសីហា ឆ្នាំ២០០៨ នៅពេលដែលក្រុមហ៊ុនស៊ុកាកុអ៊ីនបានចាប់ផ្ដើមបំពេញដីក្នុងបឹង។ ជាផ្លូវការ គម្រោងអភិវឌ្ឍន៍តំបន់នេះគឺបង្កើតជាមណ្ឌលទេសចរណ៍ វប្បធម៌និងពាណិជ្ជកម្ម។ ប៉ុន្តែគេជឿថា អ្នកធ្វើអភិវឌ្ឍន៍ នឹងពុះចែក តំបន់ទាំងនោះលក់ដើម្បីប្រាក់ចំណេញដ៏ច្រើនសន្ធឹក។

នៅពេលវ៉ាន់នីដើរតាមផ្លូវនៅក្បែរផ្ទះរបស់គាត់ គាត់សង្កេតឃើញថា គេចាក់ខ្សាច់បំពេញបឹងស្ទើរតែបំពេញទៅហើយ រយៈពេលពីរឆ្នាំកន្លះចាប់តាំងពីមានការបូមដីខ្សាច់ចូលក្នុងបឹងមក។ បឹងកក់គឺជាអាងស្តុកទឹកយ៉ាងសំខាន់ នៅក្នុងរាជធានី ហើយវាក្លាយជាដីគោក បណ្ដាលឲ្យមានទឹកជំនន់នៅរដូវមូសុងវស្សានៅតំបន់អ្នករស់នៅជុំវិញបឹង។

នៅតាមភូមិ ស្ថិតតាមមាត់បឹង ប្រព័ន្ធបង្ហូរទឹកស្អុយនិងអនាម័យត្រូវបានកកស្ទះ ដែលបង្កគ្រោះថ្នាក់ដល់សុខភាពជាច្រើន។ អំឡុងរដូវមូសុងវស្សា ប្រជាពលរដ្ឋត្រូវដើរលុយទឹកស្អុយ។ ក្នុងករណីខ្លះទៀត កម្រិតទឹកបានឡើងចូលដល់កម្រាលផ្ទះ ធ្វើឲ្យគ្រួសារមិនអាចដេកបាន។ ម៉ាស៊ីនដែលបានបូមដីខ្សាច់ បានបាញ់ចំត្រង់ៗលើផ្ទះមួយចំនួន ដែលធ្វើបណ្ដាលឲ្យកប់លិចក្នុងភក់ល្បប់ បង្ខំឲ្យគ្រួសារពលរដ្ឋទាំងនោះត្រូវចាកចេញពីផ្ទះដោយសារគ្មានជម្រើស។

ផ្ទះដែលនៅសេសសល់នៅក្នុងបុក ទល់មុខនិងនៅជាប់ផ្ទះរបស់វ៉ាន់នី គឺជាផ្ទះអ្នកជិតខាងរបស់គាត់ កំពុងរស់នៅទីនោះ។ គ្រួសារប្រជាពលរដ្ឋចំនួនពាក់កណ្ដាលដែលរស់នៅក្នុងភូមិវ៉ាន់នី បានរើចេញដោយធ្វើតាមការកៀបសង្កត់ និងស្ថានភាពមិនអាចស៊ូទ្រាំរស់នៅទៀតបាន។ ដោយសារក្នុងភូមិ កាន់តែស្ងប់ស្ងាត់ វ៉ាន់នីបានឈប់មុខរបរលក់ដូរដែលធ្លាប់ចម្រុងចម្រើន ធ្វើឲ្យជីវភាពប្រចាំថ្ងៃរបស់គាត់កាន់តែពិបាកខ្វះមុខខ្វះក្រោយ។

ខាងក្រោម៖ វ៉ាន់នី និយាយទៅកាន់ ប្រព័ន្ធសារព័ត៌មាន នៅថ្ងៃតវ៉ា ខែមីនា ២០១១

## ការតស៊ូរបស់សហគមន៍

ការរៀបចំការតស៊ូនឹងការបណ្តេញចេញដោយបង្ខំ បានចាប់ផ្តើមក្នុងខែកញ្ញា ឆ្នាំ២០០៨។ តំណាងរបស់សហគមន៍បឹងកក់ ដោយទទួលបានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល និងមេធាវីខ្មែរម្នាក់ បានដាក់ញត្តិបញ្ជាប្រញាប់ មកតុលាការរាជធានីភ្នំពេញ ដើម្បីបញ្ឈប់ការបំពេញបឹង រហូតដល់ពេលធ្វើការកំណត់អំពីភាពស្របច្បាប់នៃកិច្ចព្រមព្រៀងជួល។ ចៅក្រមបានទាត់ចោលពាក្យបណ្តឹង ដោយសំអាងថា តុលាការគ្មានយុត្តាធិការបើកសវនាការករណីនេះទេ ដោយចាត់ទុកថាជាជម្លោះដី ដែលជាដីគ្មានប្លង់កម្មសិទ្ធិ ហើយស្ថិតក្រោមការទទួលខុសត្រូវរបស់គណកម្មាធិការសុរិយោដី។



អ្នកភូមិបានឧទ្ធរណ៍ជំទាស់សេចក្តីសម្រេចរបស់តុលាការ ប៉ុន្តែមិនបានជោគជ័យ ដោយប្រកែកគ្នាថា អណត្តិរបស់គណកម្មាធិការសុរិយោដី គឺគ្រាន់តែសម្រេចវិនិច្ឆ័យអំពីជម្លោះដីធ្លីប៉ុណ្ណោះ ចំពោះដី ដែលមិនបានចុះបញ្ជី។ ពួកគាត់នៅតែប្រកាន់យកថា តុលាការពិតជាមានយុត្តាធិការទៅលើញត្តិបណ្តឹងប្រញាប់ និងអាចអង្កេតបញ្ហាស្តីពីភាពស្របច្បាប់អំពីការជួល និងបទរំលោភលើច្បាប់ភូមិបាល។ ពាក្យបណ្តឹងមួយទៀត ដែលបានធ្វើក្នុងបំណងលុបចោលកិច្ចព្រមព្រៀងត្រូវស្ងៀន តុលាការរាំងខ្ទប់ ដោយបានសម្រេចថា យោងតាមក្រមរដ្ឋប្បវេណី ថ្លៃសម្រាប់ដាក់ពាក្យបណ្តឹង នឹងតុលាការគឺត្រូវបង់ប្រាក់៤០,០០០ដុល្លារអាមេរិក។

ស្រដៀងគ្នានេះដែរ ពាក្យបណ្តឹងផ្ញើរទៅកាន់គណកម្មាធិការសុរិយោដី សាលារាជធានីភ្នំពេញ រដ្ឋសភា និងក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវបានបដិសេធឬមិនរវល់អើពើ។ វ៉ាន់នីបានសង្កេតឃើញថា ៖ “គឺមានប្រព័ន្ធ។ ប៉ុន្តែពេលដែលប្រជាពលរដ្ឋផ្ញើរឯកសារ សំណើរសុំ រដ្ឋាភិបាលនៅស្ងៀម... ដូចនេះប្រជាពលរដ្ឋគិតថាគ្មានអ្នកណាធ្វើការឲ្យប្រជាពលរដ្ឋ និងប្រទេសកម្ពុជាទេ”។

## “ខ្ញុំបន្តប្រមូលគ្នាក្នុងសហគមន៍ ដើម្បីពង្រឹងស្មារតីរបស់សហគមន៍ឲ្យនៅរឹងមាំ និង ជំរុញឲ្យរដ្ឋាភិបាលផ្លាស់ប្តូរ”។

វ៉ាន់នីបានសម្រេចចិត្តចូលរួមការតស៊ូនៅឆ្នាំ២០០៩។ សព្វថ្ងៃគាត់ជាអ្នករិះគន់ដែលឥតសំចៃម្នាក់ តំណាងឲ្យសហគមន៍។ គាត់បានប្រមូលអ្នកភូមិដែលនៅសល់មកពីភូមិទាំងអស់នៅជុំវិញបឹង ដើម្បីចូលរួមការតវ៉ា ដែលនៅក្រៅរបងសាលារាធានីភ្នំពេញនិងការិយាល័យក្រុមហ៊ុន។ វ៉ាន់នីពន្យល់ថា ដោយសារការគាំទ្រពីអង្គការក្រៅរដ្ឋភិបាល គាត់បានរៀនពីសិទ្ធិរបស់ខ្លួននិងច្បាប់ ដែលធ្វើឲ្យគាត់ និងសហគមន៍កាន់តែ “ក្លាហាន”។ គាត់និយាយថា ៖ “ខ្ញុំបន្តប្រមូលគ្នាក្នុងសហគមន៍ ដើម្បីពង្រឹងស្មារតីរបស់សហគមន៍ឲ្យនៅរឹងមាំ និងឯករាជ្យ ដើម្បីជំរុញឲ្យរដ្ឋាភិបាលផ្លាស់ប្តូរចិត្ត និងគោរពចំពោះកាតព្វកិច្ចរបស់ខ្លួនក្នុងការបម្រើប្រជាពលរដ្ឋស្លូតត្រង់ ដែលជាជនរងគ្រោះដ៏ពិតប្រាកដ ដូចជាអ្នកបឹងកក់ជាដើម”។

## ស្ត្រីឈរនៅសមរភូមិមុខ

អ្នករស់នៅជុំវិញបឹងកក់បានមកពឹងពាក់វ៉ាន់នី សុំជាយោបល់និងការគាំទ្រ។ ទីធ្លាមុខផ្ទះរបស់គាត់ បានក្លាយជាការិយាល័យបណ្ដោះអាសន្នសម្រាប់តស៊ូមតិ។ ក្រុមស្ត្រី ដែលបានដឹកនាំការតស៊ូបានជួបប្រជុំរៀងរាល់ថ្ងៃ នៅផ្ទះរបស់វ៉ាន់នី។ ពួកគាត់ពិភាក្សាគ្នាអំពីអំពីករណីបំភិតបំភ័យចុងក្រោយ ពីសំណាក់អាជ្ញាធរ និងអំពីយុទ្ធសាស្ត្រសម្រាប់ពេលបន្តខាងមុខ។

ស្ត្រី គួរជាទីមោទនៈ ដោយពួកគាត់ "ធ្វើការរួមគ្នា ទាំងគ្រាលំបាកនិងសប្បាយរីករាយ"។ វ៉ាន់នីគិតថា ស្ត្រីអាចតស៊ូមតិ "បានប្រសើរជាងបុរស។" ប៉ុន្តែ ទោះបីសិទ្ធិស្មើគ្នាមានចែងនៅក្នុងច្បាប់កម្ពុជាក៏ដោយ នាងសម្គាល់ឃើញថា តាមការអនុវត្តន៍ជាក់ស្ដែង ស្ត្រីមិនត្រូវបានប្រព្រឹត្តមកលើខ្លួនដោយស្មើគ្នានោះទេ ហើយ "គេមិនសូវគោរព លើកកម្ពស់ស្ត្រីឲ្យខ្ពង់ខ្ពស់ទេ"។ "នៅពេលខ្លះ ស្ត្រីទៅសាលារៀន ប៉ុន្តែក្រោយពេលរៀបការ ពួកគេនៅធ្វើការក្នុងចង្ក្រានបាយ ឬលក់ដូរមុខរបរតូចតាចនៅផ្ទះ។ ពួកគេគិតថា ស្ត្រីមិនអាចធ្វើការងារសំខាន់បានទេ... ប៉ុន្តែសម្រាប់ស្ត្រីនៅតំបន់បឹងកក់វិញ ចាប់តាំងពីក្រុមហ៊ុនស៊ុកាគុអ៊ីនចូលមក ស្ត្រីព្យាយាមយកឈ្នះពាក្យទាំងអស់... បុរសធ្វើការងារធម្មតា ទុកឲ្យស្ត្រីជាអ្នកចេញទៅតស៊ូវិញ"។

វ៉ាន់នីពន្យល់ថា ហេតុផលដែលស្ត្រីឈរនៅសមរភូមិតស៊ូជួរមុខ គឺមកពីខ្លាចបុរសបាត់បង់ការងារ ប្រសិនបើពួកគេមានសកម្មភាពនយោបាយ។ "ក្នុងប្រទេសកម្ពុជា ប្រសិនយើងទុកឲ្យបុរសទៅចចារតស៊ូមតិ និងមានការងារធ្វើនោះ គាត់នឹងទទួលរងការកៀបសង្កត់ជាច្រើននៅឯកន្លែងការងាររបស់គាត់ ឬត្រូវទំលាក់បុណ្យស័ក្តិមិនខាន។" ស្ត្រីព្យាយាមបញ្ចៀសអំពីហិង្សា ប៉ុន្តែ"ប៉ូលិស... នៅតែវាយដំយើងជាស្ត្រីដដែល"។

វ៉ាន់នីពិពណ៌នាអំពីការប្រឈមមុខដាក់គ្នា ជាមួយបុរសប្រដាប់អាវុធជិត ១០០ នាក់ ដែលក្រុមហ៊ុនបានបញ្ជូនមកកំទេចចោលផ្ទះរបស់អ្នកភូមិម្នាក់។ បុរសនោះមិនបានយល់ព្រមទទួលយកសំណង ហើយបានរើចេញ។

"ប៉ុន្តែគេបានបញ្ជូនមនុស្សទាំងនោះមកផ្ទះបុរសនោះ... ពួកគេឃោរឃៅព្រៃផ្សៃដាក់ប្រជាពលរដ្ឋខ្លាំងណាស់ យ៉ាងអយុត្តិធម៌។ ពួកគេបានប្រើអំណាច និងអាវុធដើម្បីបន្លាចប្រជាពលរដ្ឋ ប៉ុន្តែយើងបានតស៊ូទាំងអស់គ្នា។ បុរសក៏ចូលរួមដែរ ប៉ុន្តែស្ត្រីឈរនៅជួរមុខ ពីព្រោះយើងខ្លាចថា បើបុរសនៅជួរមុខ ហើយមានរឿងនោះ គេនឹងមានការប្រយុទ្ធគ្នាហើយ។ អញ្ចឹងហើយ ស្ត្រីឈរនៅខ្សែជួរមុខ"។

សកម្មភាពរបស់វ៉ាន់នីបានក្លាយជាកិច្ចការធ្វើពេញម៉ោង។ គាត់និយាយថា ៖ "ក្រុមហ៊ុនគេមិនដែលឈប់សម្រាក ដូចនេះយើងត្រូវត្រៀមប្រុងប្រយ័ត្នជានិច្ច"។ វ៉ាន់នី មានទឹកចិត្តចង់បន្តការតស៊ូទៅទៀត ប៉ុន្តែគាត់សារភាពថា គាត់ពិបាកដោះស្រាយជាមួយនឹងតួនាទីក្នុងផ្ទះរបស់គាត់ណាស់។ គាត់ត្រូវបញ្ជូនកូនទៅរស់នៅជាមួយឪពុកម្ដាយក្មេក និងជូនកូនទៅសាលារៀនដែលនៅជិត ដោយសារជាប់រវល់មើលថែពួកវាឲ្យបានល្អ។ "ខ្ញុំព្រួយបារម្ភខ្លះដែរ អំពីភាពជិតស្និទ្ធជាមួយកូនខ្ញុំ។ ខ្ញុំ[ខ្លាច]ថាពួកយើងនៅបែកពីគ្នាឆ្ងាយពេក ដោយសារគម្រោងអភិវឌ្ឍន៍បឹងកក់"។

មិនដូចជាប្ដីផ្សេងៗ ដែលមិនសប្បាយចិត្តដោយឃើញប្រពន្ធរវល់ធ្វើការតស៊ូមតិ និងមិនរវល់រៀបចំម្ហូបអាហារ និងនៅមើលផ្ទះសម្បែង ប្ដីរបស់វ៉ាន់នីនិងកូនៗគាំទ្រដល់កិច្ចការរបស់វ៉ាន់នី។ កូនៗរបស់វ៉ាន់និយាយប្រាប់វ៉ាន់នីថា ៖ "ម៉ែ ត្រូវប្រយ័ត្ន ពេលម៉ែចេញទៅក្រៅ។ ត្រូវមើលថែទាំខ្លួនផង។"

ការព្រួយបារម្ភរបស់កូនៗពិតជាមិនខុសទេ។ មានព្រឹត្តិការណ៍ពីរលើកដែលបានកើតឡើងនៅក្នុងខែមេសា និងខែកក្កដា ឆ្នាំ២០១១ វ៉ាន់នីព្រមគ្នាជាមួយស្ត្រីនៅបឹងកក់ឯទៀត ត្រូវបានចាប់ខ្លួនឃុំឃាំង ដោយសារធ្វើការតវ៉ាដោយអហិង្សា។ ស្ត្រីទាំងនោះ ត្រូវបានដោះលែងទាំងពីរលើក ដោយមិនទទួលការចោទប្រកាន់អ្វីឡើយ។ ការចាប់ខ្លួនទាំងនេះ មិនបំភិតបំភ័យដល់វ៉ាន់នីទេ ទោះបីក្នុងនាមជាអ្នកការពារសិទ្ធិមនុស្សម្នាក់នៅក្នុងប្រទេស ដែលលទ្ធិប្រជាធិបតេយ្យកំពុងរួញតូចក៏ដោយចុះ នាងមិនខ្លាចអំពីសុវត្ថិភាពផ្ទាល់ខ្លួនទេ។ នាងនិយាយថា ៖ "ពេលខ្ញុំចាកចេញពីផ្ទះ ខ្ញុំមិនដឹងថាតើខ្ញុំអាចមានសង្ឃឹមនឹងវិលត្រឡប់មកផ្ទះវិញ ឬយ៉ាងណានោះទេ។"

## ដំណោះស្រាយឈ្នះៗ

វ៉ាន់នីនិងមេដឹកនាំសហគមន៍ឯទៀត ធ្វើតំណាងឱ្យទស្សនរបស់សហគមន៍និងទាមទារ នៅក្នុងសន្និសីទកាសែត និងកិច្ចប្រជុំជាមួយធនាគារពិភពលោក និងម្ចាស់ជំនួយទ្វេភាគីរបស់ប្រទេសកម្ពុជា។ សហគមន៍ដែលមានជំនួយពីអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក បានបង្កើតផែនការមួយ សម្រាប់លំនៅឋានដែលអាចរកទិញបានសម្រាប់អ្នកភូមិដែលចង់រស់នៅក្នុងតំបន់បឹងកក់។ ពួកគាត់បានស្នើសុំដីតំបន់តូចមួយកន្លែង ដែលជួលឱ្យក្រុមហ៊ុនស៊ូកាកុអ៊ីនសម្រាប់សាងសង់លំនៅឋាន ទុកឱ្យប្រជាពលរដ្ឋ ជាជាងបណ្តេញពួកគាត់ចេញពីដីនៅជិតនោះ។ វ៉ាន់នីដែលជាអ្នកតស៊ូមតិដ៏ខ្លាំងម្នាក់ ក្នុងផែនការសហគមន៍នេះ បានមើលឃើញថាជាដំណោះស្រាយឈ្នះៗមួយដើម្បីបញ្ចប់ជម្លោះ ទោះបីគម្រោងនោះ មានទំហំផ្ទះតូចជាងផ្ទះរបស់ខ្លួននៅសព្វថ្ងៃក្តី។

## "ពេលខ្ញុំចាកចេញពីផ្ទះ ខ្ញុំមិនដឹងថាតើខ្ញុំអាចមានសង្ឃឹមនឹងវិលត្រឡប់មកផ្ទះវិញ ឬយ៉ាងណានោះទេ។"

ការសាងសង់លំនៅឋាននៅនឹងកន្លែង ជាការពិតគឺជាជម្រើសទីបី ដែលជាគំនិតផ្តួចផ្តើមឡើងដោយសាលាក្រុងភ្នំពេញ។ ក៏ប៉ុន្តែគ្មានអ្នកណាម្នាក់បានចាត់ទុកជម្រើសនោះថាពិតទេ ដោយសាររយៈពេលប្រាំឆ្នាំនេះ គេបានប្រាប់ពួកគាត់ឱ្យរុះរើចេញទៅដំបន់តាំងទីលំនៅឋានថ្មីដែលគ្មានអ្វីបិទបាំង ឆ្ងាយពីរាជធានីភ្នំពេញ ខណៈដែលផ្ទះរបស់ពួកគាត់កំពុងត្រូវបានសាងសង់។

នៅថ្ងៃទី១១ សីហា ឆ្នាំ២០១១ លោកនាយករដ្ឋមន្ត្រី បានចេញបញ្ញោផ្តល់ដី ១២.៤៤ ហិកតានៅបឹងកក់ ឱ្យទៅ ៨០០គ្រួសារដែលនៅសេសសល់ សម្រាប់ការអភិវឌ្ឍន៍លំនៅឋាននៅនឹងកន្លែង។

វ៉ាន់នីនិយាយថា ៖ "មនុស្សជាច្រើន គិតថាវាជាជោគជ័យជាលើកដំបូង ដែលបានមកពីការធ្វើបាតុកម្មរបស់ប្រជាពលរដ្ឋ។ ហើយវាជាបទពិសោធន៍និងឧទាហរណ៍ដ៏ធំ សម្រាប់សហគមន៍ផ្សេងៗនៅទូទាំងប្រទេសកម្ពុជាដែរ។ ពេលយើងសម្រេចធ្វើការប្រយុទ្ធ ដើម្បីដីធ្លីនិងផ្ទះរបស់យើង យើងមិនគិតថាវាជាល្បែងមួយទេ។ យើងបានខិតខំប្រឹងប្រែងខ្លាំងណាស់ ពីព្រោះថាប្រសិនយើងចាញ់ វានឹងជះឥទ្ធិពលដ៏អាក្រក់មកលើស្មារតីតស៊ូរបស់សហគមន៍យើង។ តែផ្ទុយទៅវិញ ប្រសិនយើងឈ្នះ វានឹងនាំឱ្យមានមោទនភាព និងការលើកទឹកចិត្តដល់សហគមន៍ដទៃទៀត"។

ផ្ទុយទៅវិញ ចំពោះជោគជ័យដ៏ធំសម្រាប់សហគមន៍ ផែនការនោះមិនផ្តល់ផលប្រយោជន៍សម្រាប់ជនគ្រប់រូបឡើយ។ គម្រោងអភិវឌ្ឍន៍លំអិត នៅមិនទាន់ចេញជាសាច់ការអ្វីនៅឡើយ ហើយក្រុមគ្រួសារខ្លះត្រូវបានកាត់ចេញពីផែនការនេះ។ វ៉ាន់នីនិយាយថា ៖ "ខ្ញុំនៅតែព្រួយបារម្ភ ថាតើយើងនឹងការពារដីមួយដុំនោះ និងប្រជាពលរដ្ឋរបស់យើងដោយរបៀបណា ដើម្បីធានាថា ម្នាក់ៗដែលបានចូលរួមក្នុងការតស៊ូជាមួយគ្នា នឹងទទួលបានផលប្រយោជន៍ដី ១២,៤៤ ហិកតានេះ។"

ចាប់តាំងពីការចូលរួមតស៊ូ វ៉ាន់នីបានរៀនសូត្រយ៉ាងច្រើនអំពីសង្គម និងសិទ្ធិរបស់គាត់ និងបានដឹងអំពីស្មារតីសាមគ្គីភាពរបស់សហគមន៍។ "ខ្ញុំចែករំលែកការទទួលខុសត្រូវក្នុងការងារតស៊ូមតិជាមួយអ្នកផ្សេង។ យើងមានទំនាក់ទំនងគ្នាដ៏ជិតស្និទ្ធ។ យើងសហការគ្នា ដើម្បីគោលបំណងដូចគ្នាសម្រាប់លំនៅឋានរបស់យើង... នៅទីបញ្ចប់ ទោះឈ្នះឬចាញ់ ខ្ញុំនៅតែសប្បាយចិត្ត ដោយបាន តស៊ូជាមួយអ្នកដទៃ។"

វ៉ាន់នីទទូចថាគាត់មិនចុះចាញ់ទេ ៖ "ខ្ញុំនឹងតស៊ូដើម្បីបានរស់នៅក្នុងសំបុកចាស់របស់ខ្ញុំ។ ខ្ញុំនឹងតស៊ូរហូតដល់ទីកចុងក្រោយ។"

*ទេព វ៉ាន់នី បានផ្តល់សម្ភាសន៍ដល់អង្គការលើកលែងទោសអន្តរជាតិនៅ ថ្ងៃទី ១៦-១៧ កុម្ភៈ ឆ្នាំ២០១១ និងថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១១។*


© អង្គការលើកលែងទោស អន្តរជាតិ

វ៉ាន់នី និងកូនស្រី អ៊ូ គង់បញ្ញា កូនប្រុស អ៊ូ សុវណ្ណនាគរាជ និងប្តី អ៊ូ គង់ជា នៅផ្ទះ



“ខ្ញុំនៅតែព្រួយបារម្ភ ថាតើយើងនឹងការពារដីមួយដុំនោះ និងប្រជាពលរដ្ឋរបស់យើង ដោយរបៀបណា ដើម្បីធានាថា ម្នាក់ៗដែលបានចូលរួមក្នុងការតស៊ូជាមួយគ្នា នឹងទទួលបានផលប្រយោជន៍ដី ១២,៤៤ ហិកតានេះ។”

# កំណត់សំគាល់ចុងក្រោយ

ស្ត្រីដែលបានរៀបរាប់ក្នុងរឿងខាងដើមនេះ គឺគ្រាន់តែជាផ្នែកតូចមួយប៉ុណ្ណោះនៃប្រជាពលរដ្ឋរាប់សែននាក់ដែលជួបប្រទះស្ថានភាពស្រដៀងគ្នា នៅជុំវិញប្រទេសកម្ពុជា។ ក្នុងចន្លោះឆ្នាំ១៩៩០ និង២០១១ ចំពោះតែរាជធានីភ្នំពេញមួយប៉ុណ្ណោះ មានប្រជាពលរដ្ឋក្នុងរាជធានីប្រហែលដប់ភាគរយ ត្រូវបានបណ្តេញចេញ។ គម្រោងអភិវឌ្ឍន៍ និងជម្លោះដីធ្លី គឺជាដើមហេតុនៃការបណ្តេញចេញ ដែលទីបំផុតសុខមាលភាពរបស់សហគមន៍ ត្រូវទទួលរងនូវផលប៉ះពាល់ ដោយសារតែតម្រូវការរបស់ក្រុមហ៊ុនពាណិជ្ជកម្មធំៗ។

លំនៅឋាន និងមុខរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋរាប់ពាន់គ្រួសារ កំពុងតែទទួលរងនូវការគំរាមកំហែងផងដែរ ដោយសារការកាប់បំផ្លិចបំផ្លាញយ៉ាងឆាប់រហ័សនៃព្រៃឈើ និងធនធានធម្មជាតិដទៃទៀតរបស់ប្រទេសកម្ពុជា។ នៅពេលធនធានទាំងនេះទទួលរងមហន្តរាយ ក្រុមគ្រួសារដែលពឹងលើធនធានទាំងនោះសម្រាប់ចិញ្ចឹមជីវិត ត្រូវបានបង្ខិតបង្ខំឱ្យចាកចេញឆ្ងាយ ដើម្បីរកមធ្យោបាយផ្សេងសម្រាប់ចិញ្ចឹមជីវិត។ អ្នកដែលងាយរងគ្រោះជាពិសេស នោះគឺជនជាតិដើមភាគតិចមួយចំនួនរបស់ប្រទេសកម្ពុជា ដែលជីវភាពសេដ្ឋកិច្ច សង្គម និងជំនឿរបស់ពួកគេ ផ្សារភ្ជាប់ទៅនឹងព្រៃឈើដែលមិនអាចកាត់ផ្តាច់ពីគ្នាបាន។

ក្នុងអំឡុងពីរទសវត្សរ៍កន្លងមកនេះ ការបណ្តេញចេញដោយបង្ខំ ការរំលោភច្បាមយកដីធ្លី និងការកេងប្រវ័ញ្ចលើធនធានធម្មជាតិ មិនបានជួយផ្តល់ផលចំណេញអ្វីឱ្យដល់ប្រទេសកម្ពុជានេះ ក្នុងការកាត់បន្ថយភាពក្រីក្រនោះទេ។ អំពើទាំងនេះ ផ្គើននៅចំពោះមុខការប្តេជ្ញាចិត្តច្រំដែលៗរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ និងក្នុងការលើកកម្ពស់ការគោរពនីតិរដ្ឋនិងសិទ្ធិមនុស្ស ដែលរាជរដ្ឋាភិបាលកម្ពុជា បានធ្វើនៅចំពោះមុខដៃគូរអភិវឌ្ឍន៍របស់ខ្លួនជាឧបតោភាគីនិងពហុភាគី។ ម្ចាស់ ជំនួយទាំងនេះ បានផ្តល់ទឹកប្រាក់ជាជំនួយរាប់រយកោដិដុល្លារ ចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងទីក្រុងបារីសពីឆ្នាំ១៩៩១មក។

## ការការពារតាមផ្លូវច្បាប់ ប្រឆាំងនឹងការបណ្តេញចេញដោយបង្ខំ

ប្រទេសកម្ពុជា ជាប់កាតព្វកិច្ចក្រោមសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សផ្សេងៗ មានជាអាទិ៍កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងកតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីទប់ស្កាត់និងការពារប្រជាពលរដ្ឋ ពីការបណ្តេញចេញដោយបង្ខំ។ ជាផ្នែកមួយនៃកាតព្វកិច្ចរបស់ខ្លួន ក្នុងការគោរពនិងការពារសិទ្ធិមានលំនៅឋានសមរម្យ អាជ្ញាធរកម្ពុជាត្រូវតែធានាថា មានវិធានការការពារតាមនីតិវិធី មុននឹងអនុវត្តរាល់ការបណ្តេញចេញណាមួយ។ វិធានការទាំង នោះ រួមមានការពិគ្រោះយោបល់ដោយស្មោះត្រង់ជាមួយសហគមន៍ដែលរងការប៉ះពាល់ ដើម្បីស្រាវជ្រាវរកលទ្ធភាពជាជម្រើសក្រៅពីការបណ្តេញចេញ ដោយត្រូវជូនដំណឹងនិងផ្តល់ដំណោះស្រាយផ្លូវច្បាប់ឱ្យបានគ្រប់គ្រាន់ និងផ្តល់សំណងសម្រាប់ការបាត់បង់ និងផ្តល់លំនៅឋានសមរម្យចំពោះអ្នកទាំងឡាយដែលមិនអាចផ្គត់ផ្គង់ខ្លួនឯងបាន។

ក៏ប៉ុន្តែភាពទន់ខ្សោយនៃស្ថាប័នតុលាការ និងរដ្ឋបាលប្រទេសកម្ពុជា ជាញឹកញយខកខានមិនបានលើកកម្ពស់សិទ្ធិគ្រួសារ និងសហគមន៍ដែលបានប្រឈមមុខ នឹងការបណ្តេញចេញដោយបង្ខំ ដោយសារអ្នករំលោភច្បាមយកដីធ្លីនិងអ្នកដែល ទទួលផលពីសម្បទានដីសេដ្ឋកិច្ចនោះ មានភ្ជាប់ទំនាក់ទំនងល្អ។ លើសពីនេះទៀត អ្នកប្រព្រឹត្តបទល្មើស កម្រត្រូវបាននាំខ្លួនឡើងតុលាការកាត់ទោសចំពោះបទរំលោភសិទ្ធិមនុស្សដែលពួកគេបានប្រព្រឹត្តណាស់។

ទោះបីច្បាប់ភូមិបាលឆ្នាំ២០០១ និងច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០ មានការការពារសិទ្ធិខាងផ្លូវច្បាប់ខ្លះៗក៏ដោយ ក៏ច្បាប់ទាំងនេះខកខានមិនបានការពារក្រុមប្រជាពលរដ្ឋទាំងអស់ពីការបណ្តេញ ចេញដោយបង្ខំដែរ។

ប្រជាពលរដ្ឋដែលមានការកាន់កាប់ដីដែលគ្មានប័ណ្ណកម្មសិទ្ធិ (ដូចជាប្រជាពលរដ្ឋដែលកំពុងរស់ក្នុងទីលំនៅមិនស្របច្បាប់លើដីសាធារណៈ) បានទទួលការការពារតិចតួចណាស់ក្រោមច្បាប់ទាំងនេះ។ ការការពារតាមផ្លូវច្បាប់ដែលមានស្រាប់ក៏អនុវត្តមិនល្អផងដែរ។

## ជនជាតិដើមភាគតិច

ច្បាប់ភូមិបាល ផ្តល់សិទ្ធិអំណាចឲ្យរដ្ឋ ដើម្បីផ្តល់កម្មសិទ្ធិដីសមូហភាពដល់សហគមន៍ជនជាតិដើមភាគតិច។ កម្មសិទ្ធិសមូលហភាព រាប់បញ្ចូលសិទ្ធិនិងការការពារទាំងអស់នៃកម្មសិទ្ធិឯកជន។ ស្ថិតក្រោមច្បាប់នេះ សហគមន៍ជនជាតិដើមភាគតិច មានសិទ្ធិគ្រប់គ្រងចាត់ចែងដីធ្លីរបស់ខ្លួនតាមប្រពៃណីរបស់ពួកគេ ដែលជាវិធានការការពារបណ្តោះអាសន្ន មុនពេលធ្វើការចុះបញ្ជីសហគមន៍ជាផ្លូវការ។ ទោះជាយ៉ាងណាក៏ដោយ តាមការអនុវត្តជាក់ស្តែង នីតិបញ្ញត្តិទាំងនេះ មិនត្រូវបានគេអើពើដដែលៗ។

សិទ្ធិរបស់ជនជាតិដើមភាគតិចក្នុងប្រទេសកម្ពុជា ត្រូវបានការពារក្រោមសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សផ្សេងៗ ដែលប្រទេសកម្ពុជាបានឲ្យសច្ចាប័ន។ សិទ្ធិទាំងនោះក៏ត្រូវបានការពារក្រោមសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលប្រទេសកម្ពុជាបានអនុម័តយក រួមជាមួយបណ្តារដ្ឋចំនួន ១៤៣ ផ្សេងទៀតនៅក្នុងឆ្នាំ២០០៧។ សេចក្តីប្រកាសបានគូសបញ្ជាក់អំពីសិទ្ធិជនជាតិដើមភាគតិច ដើម្បីទទួលបានដីជាប្រពៃណីរបស់ពួកគេ និងសិទ្ធិរបស់ពួកគេក្នុងការផ្តល់ការយល់ព្រម ឬមិនយល់ព្រមចំពោះការអភិវឌ្ឍន៍លើដីទាំងនោះ។

## ការពារសិទ្ធិស្ត្រី

ស្ត្រីទាំងអស់នៅក្នុងរបាយការណ៍នេះ ប្រឈមមុខចំពោះបញ្ហាដែលបង្កឡើងដោយភាពខកខានទាំងស្រុងរបស់រដ្ឋក្នុងការផ្តល់ការរៀបចំរដ្ឋនិងរចនាសម្ព័ន្ធរបស់រដ្ឋ ដែលមានសមត្ថភាពគោរពនិងអនុវត្តសិទ្ធិរបស់ពួកគេទេ។ បន្ថែមពីលើភាពខកខានរបស់អាជ្ញាធរប្រទេសកម្ពុជា ក្នុងការគោរពនិងការពារសិទ្ធិលំនៅឋានគ្រប់គ្រាន់សម្រាប់ស្ត្រី សក្ខីកម្មរបស់ពួកគេចង្អុលបង្ហាញអំពីភាពខាកខានរបស់ប៉ូលិស អាជ្ញាធរតុលាការ និងស្ថាប័ននីតិប្រតិបត្តិរបស់រដ្ឋាភិបាល ក្នុងការគោរពសិទ្ធិរបស់ពួកគាត់ ចំពោះបូរណភាពរាងកាយនិងផ្លូវចិត្ត។ នៅក្នុងបរិបទការបណ្តេញចេញដោយបង្ខំ ស្ត្រីភេទព្រមទាំងគ្រួសាររបស់ខ្លួន ត្រូវបានបំពាន ចាប់ខ្លួន បង្ខាំងនិងទទួលរងការកាត់ទោសដ៏អយុត្តិធម៌។

ក្នុងឆ្នាំ១៩៩២ ប្រទេសកម្ពុជា បានឲ្យសច្ចាប័នលើអនុសញ្ញាសហប្រជាជាតិស្តីពី ការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ហៅកាត់ថា ស៊ីដរ) ព្រមគ្នានឹងកតិកាសញ្ញា អន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលធានានូវសិទ្ធិមនុស្សរបស់ស្ត្រី រួមមានសិទ្ធិលំនៅឋាន។ អនុសញ្ញានេះ ដាក់កាតព្វឲ្យ រដ្ឋាភិបាលគោរពសិទ្ធិលំនៅឋាន ឲ្យផ្តល់នីតិវិធីពិគ្រោះ យោបល់ប្រកបដោយប្រសិទ្ធភាព និងសិទ្ធិទទួលបានដំណោះស្រាយ នៅពេលដែលសិទ្ធិស្ត្រីទទួលរងនូវការរំលោភបំពាន។

ក្រោមអនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី  ប្រទេសកម្ពុជាតម្រូវឲ្យ "លុបបំបាត់ការរើសអើង ប្រឆាំងនឹងស្ត្រី ទោះប្រព្រឹត្តដោយបុគ្គលណាម្នាក់ អង្គការណាមួយ ឬសហគ្រាសណាមួយក៏ដោយ"។ ចំណុចនេះរាប់បញ្ចូលទាំងការប្រឈមយ៉ាងខ្លាំង ទៅនឹង ការអនុវត្តជាទម្លាប់ ដែលគាំទ្រដល់គំនិតខុសឆ្គងមិនចេះផ្លាស់ប្តូរទាក់ទងនឹងយ៉េនឌ័ និងគំនិតខុសឆ្គងដែលថាភេទមួយទន់ខ្សោយជាងភេទមួយទៀត។

ស្ត្រីឈរនៅជួរមុខតស៊ូនឹងការរីករាលដាលនៃការបាត់បង់លំនៅឋាន និងព្រៃឈើក្នុងប្រទេសកម្ពុជា។ ពួកគេក៏ទទួលរងការលំបាកវេទនាដ៏ធំធេងផ្ទាល់ខ្លួនឯងផងដែរ ប្រសិនការតស៊ូរបស់ខ្លួនទទួលបរាជ័យ គួបជាមួយនឹងផលប៉ះពាល់ដ៏អាក្រក់លើស្ថានភាពលំនៅឋាន មុខរបរចិញ្ចឹមជីវិត និងសុខមាលភាពផ្លូវកាយនិងចិត្តផ្ទាល់ខ្លួនឯងនិងក្រុមគ្រួសារ។ ស្ត្រីប្រឈមមុខនឹងរបាំងដ៏ធំធេងក្នុងការព្យាយាមទទួលយកបានយុត្តិធម៌តាមរយៈស្ថាប័នតុលាការនិងរដ្ឋបាលរបស់រដ្ឋ ដែលស្ថាប័នទាំងនេះគួរតែការពារនិងលើកកម្ពស់សិទ្ធិស្ត្រីទៅតាមច្បាប់ ប៉ុន្តែស្ថាប័នទាំងនេះកម្រធ្វើណាស់។ ផ្ទុយទៅវិញ ច្បាប់និងតុលាការ ត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់កៀបសង្កត់ បំបិទមាត់ជនទាំងឡាយណា ដែលហ៊ានចេញមុខការពារសិទ្ធិរបស់ខ្លួន។

# សម្ដីចុងក្រោយ

“សម្ដេច [នាយករដ្ឋមន្ត្រីហ៊ុន សែន] គ្រប់ស្ថាប័នរដ្ឋាភិបាលទាំងអស់ដោយគ្មានការលើកលែង អង្គការទាំងអស់ [គួរ] ដឹង [រឿងដែលកើតឡើង] និងត្រូវជួយខ្ញុំ... ដើម្បីឲ្យខ្ញុំបានជួបជុំជាកូនកូនចៅ និងដើម្បីខ្ញុំមានលទ្ធភាពរស់នៅ... ខ្ញុំចង់បានដី និងផ្ទះរបស់ខ្ញុំមកវិញ។”

*មៃ, ខែមីនា ឆ្នាំ២០១១*

“...មានអ្នកគំរាមកំហែង និងធ្វើការបណ្ដេញចេញ ដោយគ្មានសងសំណងអ្វីទាំងអស់ ខ្ញុំចង់ស្នើឲ្យរាជរដ្ឋាភិបាលជួយអន្តរាគមន៍ ដើម្បីឲ្យប្រជាពលរដ្ឋទាំងអស់ដែលមានបញ្ហានេះ ដែលត្រូវគេបណ្ដេញចេញដោយគ្មានទទួលសំណង។ ប្រជាពលរដ្ឋខ្លះបានតស៊ូ ត្រូវគេចោទប្រកាន់និងជាប់ចោទ ខ្លះទៀតបានរត់គេចពីភូមិកំណើតពីការតាមការចាប់ខ្លួន ខ្ញុំចង់ស្នើសុំរាជរដ្ឋាភិបាលមេត្តាជួយអ្នកទាំងនោះ ជួយដោះស្រាយបញ្ហាដោយគ្មានអំពើហិង្សា។ សូមកុំទុកឲ្យ [ជនល្មើស] រំលោភបំពានប្រជាពលរដ្ឋតទៅទៀត។”

*សុផល, ខែឧសភា ឆ្នាំ២០១១*

“ក្នុងនាមប្រជាពលរដ្ឋដែលជាជនជាតិដើមភាគតិច
ដែលកំពុងរស់នៅក្នុងតំបន់ភ្នំនិងព្រៃឈើ
ខ្ញុំចង់ផ្ញើសារដល់ប្រជាពលរដ្ឋជនរួមជាតិនិងអន្តរជាតិ អង្គការនានា
ព្រមទាំងម្ចាស់ជំនួយ...ខ្ញុំចង់បានការចូលរួមពីសហគមន៍ ដើម្បីយល់ដឹង
និងទទួលស្គាល់ពីគម្រោងអ្វីមួយ។
នេះគ្រាន់តែជាមតិស្នើសុំឲ្យគោរពសិទ្ធិស្មើគ្នា។”

*ហុង ម៉ៃ, ខែឧសភា ឆ្នាំ២០១១*

“ប្រសិនរដ្ឋាភិបាលគឺជារដ្ឋាភិបាលល្អ ស្អាតស្អំ
គួរជួយអ្នកក្រីក្រឲ្យបានច្រើន។
វាមិនមែនអ្នកក្រគ្មានគំនិតរកស៊ីចិញ្ចឹមជីវិតទេ។
ពួកគាត់ពិតជាចេះរកស៊ី។ ប៉ុន្តែ ខ្ញុំចង់ឲ្យរដ្ឋាភិបាលមើលឃើញផ្ទាល់ភ្នែក
និងយកចិត្តទុកដាក់អ្នកក្រឲ្យបានច្រើនជាងនេះ។
ពួកគាត់មិនគួរគិតតែអំពីអំណាចរបស់ខ្លួន និងប្រាក់
និងកេងប្រវ័ញ្ចអ្នកក្រទេ។ អ្នកក្រក៏មានបេះដូង និងសិទ្ធិដែរ។”

*ហៀប,ខែមីនា ឆ្នាំ២០១១*

“យើងសង្ឃឹមថាម្ចាស់ជំនួយនឹងជួយយើង
ពីព្រោះពួកគេមកពីប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ។
ពួកគេនឹងគោរពសិទ្ធិមនុស្ស។ ពួកគេមិនចង់ឲ្យមូលនិធិរបស់ខ្លួន
ធ្វើឲ្យប្រជាពលរដ្ឋធ្លាក់ខ្លួនផទនាទេ។ ដូច្នេះ ខ្ញុំប្រាកដថា
ពួកគេនឹងជួយពលរដ្ឋខ្មែរ និងជំរុញរដ្ឋាភិបាលឲ្យដោះស្រាយបញ្ហា”។

*វ៉ាន់នី, ខែកុម្ភៈ ២០១១*

**amnesty.org/demand-dignity**

បោះពុម្ពផ្សព្វផ្សាយជាលើកដំបូងក្នុងឆ្នាំ២០១១ ដោយ
អង្គការលើកលែងទោសអន្តរជាតិ
អគ្គលេខាធិការដ្ឋានអន្តរជាតិ
Peter Benenson House
1 Easton Street
London WC1X 0DW
United Kingdom

© Amnesty International 2011

លិបិក្រម: ASA 23/006/2011 Khmer
ភាសាដើម៖ អង់គ្លេស
បោះពុម្ពដោយអង្គការលើកលែងទោសអន្តរជាតិ
អគ្គលេខាធិការដ្ឋានអន្តរជាតិ
ចក្រភពអង់គ្លេស

រក្សាសិទ្ធិគ្រប់យ៉ាង។ របាយការណ៍នេះ ត្រូវរក្សាសិទ្ធិគ្រប់យ៉ាង។
ប៉ុន្តែរបាយការណ៍អាចត្រូវបានបោះពុម្ពផ្សាយ
ជាថ្មីតាមវិធីដោយគ្មានការបង់ថ្លៃ សម្រាប់បំណង
ការតស៊ូមតិ យុទ្ធនាការណ៍ និងការបង្រៀន
តែមិនមែនសម្រាប់ការលក់ដូរទេ។ ម្ចាស់កម្មសិទ្ធិ
ស្នើអោយមានការទាក់ទងសម្រាប់ការប្រើប្រាស់
ទាំងអស់ ដើម្បីការវាយតំលៃអំពីផលប៉ះពាល់។
រាល់ការចំលង ក្នុងកាលទេសៈ ផ្សេងៗ ការបោះពុម្ព
ផ្សាយ ឬការយកលំនាំតាមនៃការបកប្រែត្រូវតែសុំ
ការអនុញ្ញាតជាមុនពីបណ្ណាធិការ ហើយអាចត្រូវ
ទាមទារអោយបង់ថ្លៃ។ ដើម្បីស្នើសុំការអនុញ្ញាត
ឬមានសំណួរផ្សេងៗ សូមទាក់ទងតាមអ៊ីម៉ែល
copyright@amnesty.org



*របាយការណ៍ការបណ្តេញចេញ និងការតស៊ូក្នុងប្រទេសកម្ពុជា* និយាយរឿងរ៉ាវរបស់ស្ត្រីប្រាំនាក់ ដែលបានទទួលរងគ្រោះដោយសោកនាដកម្មមកលើប្រជាពលរដ្ឋរាប់រយពាន់នាក់ នៅជុំវិញ ប្រទេសកម្ពុជា។ មែ សុផល និងហៀប បានរងផលប៉ះពាល់ទង្គិចផ្លូវចិត្ត ដែលបណ្តាលមកពីការបណ្តេញចេញ។ ចំណែក ហុង និងវ៉ាន់នី កំពុងធ្វើតស៊ូ ប្រឆាំងនឹងសកម្មភាពរបស់ក្រុមហ៊ុនឯកជន ដ៏មានឥទ្ធិពល ដែលបាននិងកំពុងគំរាមកំហែងលំនៅឋាន និងជីវភាពរស់នៅរបស់ពួកគាត់ ដោយមិនបានគិតគូរអំពីសិទ្ធិរបស់ពួកគាត់ឡើយ។ ទោះបីត្រូវបណ្តេញចេញ ឬ នៅនឹងមួយកន្លែងក្តី ស្ត្រីទាំងនេះបានបង្ហាញវីរភាព ភាពវៃឆ្លាត និងដំណោះស្រាយដ៏ស្ទៀមស្ទាត់។

amnesty.org/demand-dignity

AMNESTY INTERNATIONAL

